៨

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ឆ្នាំទី ៣៣ លេខ ៨ ខែសីហា

ព.ស. ២៥០៤ គ.ស. ១៩៦១

- ភ្នំពេញ -

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE

ឆ្នាំទី ៣៣ លេខ ៨ ខែសីហា

ព.ស. ២៥០៤ គ.ស. ១៩៦១

ភ្នំពេញ

# គណៈប្រតិភូខ្មែរ

# ខាងពុទ្ធសាសនាដែលទៅប្រជុំនៅប្រទេសជប៉ុន
# បានអញ្ជើញត្រឡប់មកវិញហើយ

---

នៅពេលរសៀល ថ្ងៃទី ១៣ សីហា ១៩៦១ នេះ នៅចំណត អាកាសយានពោធិចិនតុង មានការរង់ចាំទទួលគណៈប្រតិភូខ្មែរ ដែលមានសហជីវិន ស៊ុន-ប៊ុនឆោ រដ្ឋលេខាធិការក្រសួងធម្មការជាប្រធាន សហជីវិន ប៉ាយ-ល្មុត នឹងសហជីវិន គួច-គីឡេង ជាសមាជិក ដែលត្រូវអញ្ជើញត្រឡប់មកពីប្រទេសជប៉ុន ។

ក្នុងចំណោមអស់លោកដែលទៅរង់ចាំទទួល យើងសង្កេតឃើញជាអាទិ៍ លោក ច័ន្ទ-សុខ នាយកការិយាល័យ, លោក លឹម-ផ្លូងសេង នាយខុទ្ទកាល័យក្រសួងធម្មការ, លោក តែ-ម៉េងឃាប់ អគ្គលេខាធិការនៃពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ លោក យៀង-ចិម អគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ព្រមទាំងបុគ្គលិកក្រសួងធម្មការ នឹងក្រុមគ្រួសារជាច្រើនទៀត ។

នៅវេលាម៉ោង ៣ រសៀល អាកាសយានប្រតិកម្មបានដឹកនាំដំណើរគណៈប្រតិភូមកដល់ចំណតអាកាសយានពោធិចិនតុង ។

តាមព័ត៌មាន ដែលគណៈប្រតិភូបានឲ្យការណ៍ថា ដំណើរដែលទៅកាន់ប្រទេសជប៉ុននេះ ដើម្បីទៅរួមប្រជុំខាងផ្នែកអ្នកកាន់សាសនាទូទៅ

ឆ្លងទៅប្រាប់ម្ខាង . . .

P.K - 1
1961 - 8

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ
ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

*ផ្នែកសាសនា*    **បញ្ជីរឿង**    *ទំព័រ*


- វិបារណកថា អំពីគោលសំខាន់នៃព្រះពុទ្ធសាសនា (ត) លោក ផល-ទិត្យ រៀបរៀង ៨៣៧
- ពុទ្ធចរិតៈ ថ្លែងអំពីព្រះជីវប្រវត្តិ នៃព្រះគោតម (តចប់) លោក គួច-គីឡេង ប្រែ . ៨៤៦
- លោកុត្តរាភិសម័យ (ត) អ្នកឧកញ៉ា ទា-សាន អតីតរដ្ឋមន្ត្រី រៀបរៀង . . ៨៥១
- ព្រះអភិធម្មបិដក គម្ពីរព្រះយមក (ត) លោក ប៊ូ-ប៉ូ រៀបរៀង . . . ៨៦២
- មធុរសវាហិណី(ត)សម្ដេចព្រះធម្មលិខិតល្វី-ឯម ប្រែ ព្រះ ញ.ឈឹង ពិនិត្យ . . ៨៧៣
- មហោសថជាតក(ត)លោកអ៊ុម-ភានបម្រួងពីសាស្ត្រាស្លឹករឹតព្រះពុទ្ធវង្សកឹម-ទូរពិនិត្យ. ៨៧៩


*ផ្នែកអក្សរសាស្ត្រ*


- វប្បធម៌ខ្មែរ (ត) លោក លី-ធាមតេង រៀបរៀង . . . ៨៩២
- ពាក្យខ្មែរប្រែពីបរទេស (ត) ដោយគណៈកម្មការវប្បធម៌ . . . . . ៨៩៧
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (ត) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . ៨៩៨
- រឿងសាមកុក (ត) ឧកញ៉ា នូ-កន ប្រែ . . . . ៨៩៩
- រឿងមនុស្សចិត្តប្រែប្រួល (តចប់) លោក ប៊ូ-ប៉ូ រៀបរៀង . . ៩១០
- រឿងព្រេងបិទ លោកវ៉ៃ-ភ៊ុក រៀបរៀង . . . . . . . . . . ៩២១
- ភូមិសាស្ត្រសេដ្ឋកិច្ចប្រទេសជប៉ុន(ត)លោកវ៉ូហ្សែមប៊ែរត៍ រៀបរៀង លោកញ៉ែមទឹមប្រែ ៩២៤
- អនាគតសមាជទី ៦ នៃពុទ្ធិកសមាគមពិភពលោក សហជីវិន ស្វរ ណៃ រៀបរៀង ៩៣១
- វប្បជាតិស្ពានសំគអំពៅ ដោយភិក្ខុ ឋាប់-គឹល ប្រឡងជាប់លេខ ២ ខាងទំរៀងទម្លាប់ ៩៤៣


*ផ្នែកកំណត់ទិនប្បវត្តិការណ៍*


- សេចក្ដីរាយការណ៍សង្ខេបអំពីសន្និសីទនៅប្រទេសជប៉ុន លោកញ៉ែម-ទឹម ប្រែ . ៩៤៩


មួយឆ្នាំ មាន ១២ សៀវភៅ ជាថ្លៃជាវ ២៣០ រ០០

33e Année — No 8 — Août 1961

# KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire
publiée par l'Institut Bouddhique de Phnom-Penh

## Sommaire

### Partie religieuse

Page

— Editorial " Les principes du Bouddhisme " ( suite ) par *M. PHAL-TITH* . . . 837
— Buddha carita (suite et fin) traduit par *M. KUOCH-KY LENG* 846
— Lokkuttara Bhisamaya par l'Oknha *TEA - SAN* . . . . . 851
— Prah Abhidhamma pitaka (Kampi Prah Yámaka) (suite) par *M. BOU - PO* . . . . . 862
— Madhurasavahini (suite) traduit par Samdech Prah Dhammalikhita *LOUIS - EM*, revu et corrigé par Vèn. *NHÉAN - CHHOEUN* . . . . 873
— Mahosatha Jataka (suite) relevé du manuscrit sur feuilles de latanier par *M. IM - PHON*, revu et corrigé par Vèn. *KEM - TO* . . . . 879

### Partie littéraire

— La Culture Khmère (suite) par *M. LY - THEAM - TENG* . . 892
— Activités de la Commission Culturelle (suite) . . . . . . . . . . 897
— Dictionnaire Sanscrit-Khmèr (suite) par Vèn. *PANG-KHAT* . . 898
— Histoire de Sam-Kok (suite) traduite par l'Oknha *NOU - KAN* . . . . . . 899
— L'homme au coeur changeant (suite et fin) par *M.BOU-PO* . . 910
— Légendes populaires de la Chine par *M. RAY - BUC* . . . . 920
— Géographie économique du Japon (suite) par *M. ROSEMBERT* traduite par *M. NHEM - KHEM* . 924
— Le 6 ème Congrès de l'Association Mondiale des Bouddhistes par *M. SO - NEM* . . . 931
— Le Papayier et la canne à sucre par le bonze *THAC - NGEL* (texte primé par la Commission des Mœurs et Coutumes) . . . 943

### Notes et chroniques

— Rapport succinct de la Conférence religieuse au Japon . . 949

Prix d'abonnement annuel (comprenant 12 numéros): 23o|oo

វិចារណកថា

# អំពីគោលសំខាន់នៃពុទ្ធសាសនា

លោក ផល-ទិត្យ នៅពុទ្ធសាសនបណ្ឌិត្យ រៀបរៀង

ព្រះមុនីកោសល សួរ-ហាយ ពិនិត្យ

(តមក)

---

ពោលទៀត គឺហាត់ពត់តាមវិធីបត្តិសាស្ត្រ ដើម្បីលះពោលទូវកម្មល្អនោះ ឲ្យអស់ពីសន្តានទៅទៀត ៗ លុះលះពោលបានទាំងកម្មល្អ ទាំងកម្មអាក្រក់ (បុញ្ញបាបប្បហីនៈ) យ៉ាងនេះហើយ លោកក៏បាននាមថ្មីឡើងថា អរិយបុគ្គលទីណា គ្រប់ ៗ សូមបញ្ជាក់ថា អ្នកដែលលះ កម្មល្អ នឹង កម្ម អាក្រក់បាននេះ មិនមែនអស់ការកំរើកខ្លួន (កាយវិញ្ញត្តិ) កំរើកវាចា (វចីវិញ្ញត្តិ) កំរើកចិត្ត (មនោវិញ្ញត្តិ) ទេ ទាំងការកំរើក (វិញ្ញត្តិ) របស់លោកនោះ ក៏មានវិញ្ញាណ (មនោ-ចិត្ត) នៅបង្គាប់បញ្ជាដែរ, ប៉ុន្តែ បានជាលោកមិនមាន កម្ម ទៅវិញនោះ ព្រោះ វិញ្ញាណ (មនោ-ចិត្ត) របស់លោកជាធម្មជាតបរិសុទ្ធលែងត្រូវការជាប់ប្រទាក់ដោយ កម្មល្អ នឹង អាក្រក់ ទៀតហើយ, ប្រៀបដូចជាស្លឹកឈូក ដែលមិនជាប់ប្រទាក់ទឹកណាក់ទេ ឬដូចគ្រាប់ពេជ្រមិនជាប់លើចុងដែកយ៉ាងស្រួចបាន ដូច្នោះ ៗ ការប្រតិបត្តិហ្វឹកហ្វឺន

ចិត្តឲ្យលែងប្រឡាក់ដោយ កម្ម ល្អនឹង កម្ម អាក្រក់ ដែលខ្ញុំពណ៌នាមកនេះ គ្រាន់តែជាការពប់តាមជំហានទេ ឯការប្រឹងឈានវិញ មិនមែនស្រួលដូចនិយាយឡើយ ត្រូវចាយពេល អស់ការនឿយហត់ច្រើន ហើយលំបាកក្រៃលែងលំបាកផង ។ កន្លែងនេះ ខ្ញុំមិនបានរៀបរាប់តាមកម្មវិធីហ្វឹកហាត់ចិត្តឲ្យគ្រប់សព្វទេ ខ្ញុំសូមពណ៌នាចំពោះតែចិត្តដែលថាពមិនជាប់ប្រឡាក់ដោយ កម្ម ប៉ុណ្ណោះ ដើម្បីបញ្ជាក់ឲ្យឃើញថា ចិត្តដូចម្ដេច ដែលមិនជាប់ប្រឡាក់ដោយ កម្ម ល្អនឹង កម្ម អាក្រក់?

ពួកបុថុជ្ជន គឺមនុស្សធម្មតាទូទៅដូចជាយើងគ្រប់គ្នានេះ កាលនឹងធ្វើអ្វីមួយ តែងតែធ្វើដោយចិត្ត ២ យ៉ាងគឺ :

១– ដោយចិត្តល្អ (ចិត្តបុណ្យ- កុសលចិត្ត) ដែលជាឈ្មោះនៃកម្មល្អ,

២– ដោយចិត្តអាក្រក់ (ចិត្តបាប- អកុសលចិត្ត) ដែលជាឈ្មោះនៃកម្មអាក្រក់ ។ ឯអរិយបុគ្គលជាខីណាស្រពវិញ លោកធ្វើដោយចិត្តតែមួយប៉ុណ្ណោះគឺ កិរិយាចិត្ត ។ ចិត្តល្អ ជាហេតុឲ្យកើតការកំរើកល្អ, ការកំរើកល្អ ជាហេតុឲ្យកើតកម្មល្អ, កម្មល្អជាហេតុឲ្យកើតផលល្អ ។ ចិត្តអាក្រក់ ជាហេតុឲ្យកើតការកំរើកអាក្រក់, ការកំរើកអាក្រក់ជាហេតុឲ្យកើតកម្មអាក្រក់, កម្មអាក្រក់ជាហេតុឲ្យកើតផលអាក្រក់ ។ ឯ កិរិយាចិត្ត វិញ ក៏ជាហេតុឲ្យកើតការកំរើកគ្រាន់តែជា កិរិយា គឺគ្រាន់តែ

ធ្វើធ្វើទៅប៉ុណ្ណោះ ហើយក៏មិនអាចឲ្យកើតទៅជាកម្មឡើយ កាលបើក៏មិនកើតទៅជា កម្ម ហើយ, ផល គ្រប់បែបក៏គ្មានដែរ ។

ចុះហេតុអ្វី បានជាការគំរើកដែលប្រកបដោយ កិរិយាចិត្ត មិនអាចឲ្យកើតទៅជា កម្ម ?

បានជាមិនអាចឲ្យកើតទៅជា កម្ម ព្រោះថា កិរិយាចិត្ត នេះក៏ជាចិត្តអស់សេចក្ដីត្រូវការ ដោយល្អទីដ៏អាក្រក់ទៅហើយ គឺបើក៏បង្គាប់បញ្ជាឲ្យធ្វើអ្វីៗ ក៏គ្រាន់តែឲ្យធ្វើធ្វើទៅ ដើម្បីឲ្យត្រូវតាមសភាពពិភពលោកប៉ុណ្ណោះ ឥតមានចង់បាន ផល ដែលចេញពីការធ្វើរបស់ខ្លួនឡើយ ។

មែនពិត, ចិត្តរបស់មនុស្សបុថុជ្ជនយើងនេះ; កាលណាក៏បង្គាប់បញ្ជាកាយ - វាចា ឲ្យធ្វើអ្វី ក៏សុទ្ធតែចង់បាន ផល ពីការធ្វើនោះទាំងអស់ បើទុកជាមិនចង់បាននេះ ក៏ចង់បាននោះ ជាការពិតប្រាកដណាស់ ។ យើងមិនបាច់និយាយទៅផ្នែកខាងចិត្តអាក្រក់ទេ ព្រោះចិត្តអាក្រក់ សុទ្ធតែមានប្រាថ្នាទើបធ្វើអាក្រក់បាន ដូចជាក៏លួចគេក៏ព្រោះតែចង់បានទ្រព្យ ក៏បៀតបៀនគេ ក៏ព្រោះតែចង់បានជ័យជំនះលើគេជាដើម ។ ឯផ្នែកខាងចិត្តល្អវិញក៏ដូចគ្នា គឺសុទ្ធតែឃើញប្រយោជន៍អ្វីមួយហើយទើបចុះធ្វើ មិនមែនធ្វើដោយឥតប្រាថ្នាទេ ។ អ្នកខ្លះនិយាយថា “ខ្ញុំប្រឹងធ្វើល្អដល់គេនេះ ខ្ញុំឥតចង់បានអ្វីទេ” យ៉ាងនេះ តើពិតជាមិនចង់បានមែនឬ ? ពិតជាមិនមែនទាល់តែសោះ ព្រោះថា បើមិនចង់បានទ្រព្យសម្បត្តិពីគេ

ក៏គង់ចង់បានទ្រព្យសម្បត្តិ ពីអ្នកដទៃទៀតដែរ ឬបើមិនចង់បានទ្រព្យសម្បត្តិពីអ្នកដទៃទៀតទេ ក៏គង់ចង់បានសម្បត្តិឯឋានសួគ៌ឋានព្រហ្មដែរ ឬក៏បើទុកជាមិនចង់បានសម្បត្តិឯឋានសួគ៌ស្ថានព្រហ្មទេ ក៏គង់ចង់បានកិត្តិយសមានការទទួលស្គាល់ – ការកោតសរសើរ – សេចក្ដីស្រឡាញ់ សេចក្ដីពេញចិត្តពីអ្នកផងទាំងពួងដែរ, ដែលថាមិនចង់បាននោះ ជាការមិនពិតតាលតែសោះ ។

ចំណែកអរិយបុគ្គលជាខីណាស្រវវិញ ទោះលោកគ្នាត់ធ្វើអាក្រក់ដោយឥតចេតនាក៏លោកគ្មានប្រាថ្នា ឬទោះលោកធ្វើល្អ ក៏គ្មានប្រាថ្នាដែរគឺលោកលែងត្រូវការអ្វីទាំងអស់ក្នុងពិភពលោកនេះទៅហើយ ប្រៀបដូចទឹកដែលពេញពាង, បើទុកជាគេយកទឹកឯទៀតទៅចាក់បន្ថែមក្នុងពាងនោះក៏គ្មានប្រយោជន៍ដែរ ព្រោះទឹក ពុំមិនអាចដក់នៅខ្ពស់ជាងមាត់ពាងទៅទៀតបានទេ គឺបានសេចក្ដីថា ព្រះខីណាស្រពលោកធ្វើការកំរើក ក៏ធ្វើគ្រាន់តែជាកាយវិការ តាមសភាពធម្មតារបស់លោកប៉ុណ្ណោះ ។ ដូចជាការបរិភោគ ប្រើប្រាស់ចតុប្បច្ច័យ, ក្នុងគម្ពីរលោកប្រៀបទុកថាដូចជាស្ត្រីជាមាតានៃទារកម្នាក់ បានពកូនតូចជាទីស្រឡាញ់ស្នេហ៍ដោយជីវិតនោះដើរកៀសខ្លួនកាត់ផ្លូវកន្តារ (ដាច់ស្រយាល) លុះអស់ស្បៀងរកអ្វីស៊ីមិនបានក៏ស៊ីសាច់កូនដែលស្លាប់នៅក្នុងដៃ ហើយប្រឹងធ្វើដំណើរតទៅទៀត ។ គេអាចសួរថា ស្ត្រីនោះមានចំណង់ចង់ស៊ីជុំសាច់កូនខ្លួន

ឬទេ ? តាមពិតគ្មានចិត្តម្តាយណាចង់ហែកស៊ីកូនតូចដែលជាទីស្រឡាញ់របស់ខ្លួនយ៉ាងនេះទេ ប៉ុន្តែ ក្នុងកាលៈទេសៈដែលម្តាយប្រឹងលេបដុំសាច់កូនស្ងួនជាទីស្រឡាញ់ដូច្នេះ ចិត្តគាត់គ្មានចង់ទាល់តែសោះ គាត់ប្រឹងលេបទាំងទឹកភ្នែក ដើម្បីដោះស្រាយបញ្ហាជីវិត ឲ្យបិតថេរនឹងធ្វើដំណើរឲ្យដល់ត្រើយនៃគោលដៅតែប៉ុណ្ណោះ យ៉ាងណាមិញ,ចិត្តព្រះខីណាស្រពដែលបរិភោគប្រើប្រាស់ចតុប្បច្ច័យនោះ ក៏គ្រាន់តែដោះស្រាយបញ្ហាជីវិតឲ្យតាំងនៅតាមសភាពធម្មតារបស់លោកប៉ុណ្ណោះ ឥតមានចិត្តជាប់ជំពាក់ដោយចំណង់ណាមួយ ក៏យ៉ាងនោះដែរ ។ មួយទៀត ដូចអ្នករទេះយកខ្លាញ់ទៅលាបភ្លៅរទេះ, ភ្លៅរទេះ គ្មានចិត្តចង់បានខ្លាញ់មកលាបទេ ប៉ុន្តែបើម្ចាស់រទេះមិនលាបវា ក៏វាមិនអាចវិលទៅបានស្រួលឡើយ យ៉ាងណាមិញ, ព្រះខីណាស្រព បរិភោគប្រើប្រាស់ចតុប្បច្ច័យគ្រាន់តែញុំាងដំណើរជីវភាពឲ្យប្រព្រឹត្តទៅដោយស្រួលតែប៉ុណ្ណោះ ដោយឥតមានចិត្តជាប់ជំពាក់ក្នុងបំណងបន្តិចបន្តួចសោះ ក៏យ៉ាងនោះដែរ ។ ម្យ៉ាងទៀតសោត ប្រៀបដូចបុរសលង់ទឹកដែលជិតតែនឹងផុតដង្ហើមទៅហើយ ស្រាប់តែឃើញសាកសពមួយហើមស្ពឹងអណ្តែតមកក្បែរ ក៏ប្រកតោងបណ្តែតខ្លួនបានរួចរំដោះពីការលង់ទឹករហូតដល់ត្រើយជាសុខស្រួល ។ តើបុរសនោះ ចង់តោងខ្មោចណាស់ទៅឬ ? គ្មានទេ ! គ្មានចង់ទាល់តែសោះ! ប៉ុន្តែគ្រោះថ្នាក់មកដល់ហើយ សុខចិត្តប្រកតោងខ្មោចទាំងឥតចង់សោះ

ឲ្យរួចតែជីវិតប៉ុណ្ណោះ យ៉ាងណាមិញ ព្រះខីណាស្រពបរិភោគប្រើប្រាស់បច្ចុប្បច្ច័យគ្រាន់តែរំដោះជីវិតតាមសភាពលោកិយតែប៉ុណ្ណោះ ក៏យ៉ាងនោះដែរ ។

ចុះបើលោកគ្មានចិត្តជាប់ចំពាក់ដោយសេចក្ដីប្រាថ្នា ដែលជាចិត្តឧត្តុង្គឧត្តមពិសេសជាងចិត្តមនុស្សធម្មតាយ៉ាងនេះហើយ តើ កម្មល្អ នឹង កម្មអាក្រក់ អាចចូលមកធ្វើអន្តរាគមន៍ក្នុងសន្តានចិត្តលោកដូចម្ដេចបាន ?

តាមធម្មតា កម្មល្អ កាលណា ជ្រៀតជ្រែកទៅនៅជាមួយនឹងជនណា រមែងនាំជននោះឲ្យបានសេចក្ដីសុខក្សេមក្សាន្ត ដូចជាថ្នាំកែរោគដូច្នោះ ។ ចុះបើមនុស្សគ្មានជម្ងឺឈឺថ្កាត់អ្វីបន្តិចបន្តួចសោះ តើថ្នាំមានប្រយោជន៍អ្វីសម្រាប់មនុស្សនោះ ហើយមនុស្សនោះគ្មានជម្ងឺអ្វីបន្តិចសោះ ទាំងដឹងថាថ្នាំក៏គ្មានប្រយោជន៍សម្រាប់ខ្លួនទេ តើចង់បានថ្នាំនោះមកធ្វើអ្វី ? មួយទៀត បើទុកជាមានកាលៈទេសៈខ្លះ ដែលត្រូវតែលេបវាមិនបាន ក៏ថ្នាំនោះគ្មានបានជាប្រយោជន៍អ្វីដល់អ្នកមិនឈឺនោះដែរ យ៉ាងណាមិញ, ព្រះខីណាស្រពក៏យ៉ាងនោះដែរ គឺលោកជាអ្នកឥតជម្ងឺ លោកជាជម្ងឺដាច់ស្រឡះទៅហើយ លោកបានសេចក្ដីសុខក្សេមក្សាន្តយ៉ាងបរិបូណ៌ហើយ បានជាលោកគ្មានសេចក្ដីប្រាថ្នាចង់បាន កម្មល្អ ដែលទុកដូចជាថ្នាំកែរោគនោះ ហើយបើទុកជាកាលៈ

ទោសៈខ្លះដែលលោកធ្វើការទៅលើ កម្មល្អ, ក៏ កម្មល្អ នោះគ្មានផលប្រយោជន៍អ្វីដល់លោកដែរ ព្រោះលោកមានសេចក្ដីសុខក្សេមក្សាន្តដូចជាពាងពេញព្រៀបដោយទឹកទៅហើយ ។

៦ កម្មអាក្រក់ វិញ ក៏ដូចគ្នា គឺកាលណាវាចូលទៅជ្រៀតជ្រែកក្នុងមនុស្សណា តែងតែធ្វើមនុស្សនោះឲ្យរងទុក្ខដ៏ក្ដៅផ្សា ដូចជាថ្នាំពិសដែលប្រឡាក់ដៃមានដំបៅ ឬមានមុខរបួសដូច្នោះ ។ ចុះបើបាតដៃ គ្មានមុខរបួស ឬដំបៅទេ តើថ្នាំពិសអាចពេលពលបង្កើតសេចក្ដីទុក្ខឈឺចាប់បានឬទេ ? មិនអាចឲ្យឈឺចាប់បានទេ ព្រោះវាមិនអាចជ្រាបចូលស្បែកបាតដៃបាន យ៉ាងណាមិញ, ព្រះខីណាស្រពលោកទុកដូចជាបុគ្គលមានដៃឥតមុខរបួស ឬដំបៅទៅហើយ, កម្មអាក្រក់ដែលដូចជាថ្នាំពិស មិនអាចធ្វើឲ្យលោកទទួលផលក្ដៅផ្សាបាន ក៏យ៉ាងនោះដែរ ។ សេចក្ដីនេះ សមនឹងព្រះពុទ្ធដីកាក្នុងខុទ្ទកនិកាយថា

បាណិម្ហិ ចេ វណោ នាស្ស ហរេយ្យ បាណិនា វិសំ
នាព្វណំ វិសមន្វេតិ នត្ថិ បាបំ អកុព្វតោ ។

ប្រសិនបាតដៃ ឥតមានដំបៅ កាន់ថ្នាំពិសទៅ ដោយបាតដៃបាន
ថ្នាំពិសមិនពេល ដៃដំបៅគ្មាន ដូចបាបមិនមាន ដល់អ្នកមិនធ្វើ ។

(ខ) បុគ្គលកាលប្រាថ្នាដឹកនាំ លូកដៃកាន់ថ្នាំពិសក្ដៅផ្សា
ប្រសិនបាតដៃបែកប្រេះឆា មានជារបួស ឬដំបៅ ។

ថ្នាំពិសទឹងពេលយ៉ាងធុតឆាប់ ឲ្យដៃចុកចាប់ឈឺផ្សាក្តៅ
ព្រោះវាអាចជ្រួតជ្រាបចូលទៅ ធ្វើសាច់ឲ្យក្តៅផ្សាមិនខាន ៗ
តែបើបាតដៃល្អបរិសុទ្ធ ដំបៅដាច់មុតអ្វីក៏គ្មាន
ទោះកាន់ថ្នាំពិសទាំងប៉ុន្មាន គេអាចកាន់បានឥតព្រួយភ័យ ៗ
ព្រោះថាថ្នាំពិសឫសតែពុល វាមិនអាចរុលចូលស្បែកដៃ
ដែលគ្មានដំបៅជាទោសពៃរ៍ រឿងនេះឧបមេយ្យបានយ៉ាងណា ៗ
រីឯបុគ្គលមានចិត្តខ្ពស់ កា[illegible]ល ស្រេចអស់ក្តីប្រាថ្នា
ទោះទឹងធ្វើកិច្ចការមេត្តា ហៅថាធ្វើកម្មក៏មិនបាន ៗ
បើគ្មានកម្មហើយក្តីអាក្រក់ ក៏មិនអាចដក់ក្នុងសន្តាន
ព្រោះលោកឥតកម្ម[illegible]ចូលប្រាណ រឿងនេះប្រៀបបានដូច្នោះដែរៗ

ពណ៌នាប៉ុណ្ណោះនេះ រួមសេចក្តីមក អាចបញ្ជាក់បានថា ពិតមែនតែការកំរើក ដែលមានចិត្ត (វិញ្ញាណ មនោ) នៅបន្ទាប់បញ្ហា ប៉ុន្តែការកំរើកដែលប្រកបដោយចិត្ត (វិញ្ញាណ-មនោ) ជា គិរិយា (កិរិយាចិត្ត) មិនអាចឲ្យកើតទៅជាកម្មបានទេ ៗ ឯការកំរើកដែលជាដំណើរឲ្យកើតទៅជាកម្មនោះ បានចំពោះតែការកំរើកប្រកបដោយចិត្តល្អ (កុសលចិត្ត) និងចិត្តអាក្រក់ (អកុសលចិត្ត) តែប៉ុណ្ណោះ ៗ ដូច្នេះការកំរើករបស់មនុស្សដែលមានចិត្ត (វិញ្ញាណ-មនោ) នៅបន្ទាប់បញ្ហានោះ គួរចែកជា ២ យ៉ាងទៀតគឺ

១ ការកើតរបស់មនុស្ស ដែលប្រកបដោយ កិរិយាចិត្ត នៅបន្ទាប់បញ្ញា បានដល់ការកើតរបស់ពួកព្រះអរហន្តខីណាស្រព ,

២– ការកើតរបស់មនុស្ស ដែលប្រកបដោយ កុសលចិត្ត នឹង អកុសលចិត្ត នៅបន្ទាប់បញ្ញា បានដល់ការកើតរបស់ពួកមនុស្សបុថុជ្ជនសាមញ្ញ ដូចជាពួកយើងសព្វថ្ងៃនេះ ។

បណ្ដាការកើតទាំងពីរបែបនេះ ការកើតទី ១ មិនអាចជាដំណើរឲ្យកើតទៅជា កម្ម បានទេ ព្រោះថា ចិត្ត ពិសេស ដែលគេបានអប់រំដល់ទីបំផុត លែងឲ្យទាក់ទងនឹង កម្ម បានហើយ ។ ឯការកើតទី ២ វិញ ទើបជាការកើតឲ្យកើតទៅជា កម្ម បាន, ហើយ កម្ម នេះឯង ជាបញ្ហាដែលត្រូវដោះស្រាយក្នុងទីនេះ ព្រោះវាជាទីដែលអាចបណ្ដុះវិញ្ញាណ (មនោ-ចិត្ត) ឲ្យកើតទៅក្នុងភពថ្មីទៀត ។

(នៅមានត)

ពុទ្ធចរិតៈ

# ប្រែងពីព្រះជីវប្រវត្តិនៃព្រះគោតម

លោក គួច-គីឡេង ប្រែរៀបរៀង

(តនឹងចប់)

---

គាថាទី ៦:- ព្រឹកឡើងព្រះសិទ្ធត្ថកុមារយានទៅដល់អាស្រមរបស់តាបសម្នាក់ ហើយទ្រង់ដោះគ្រឿងអលង្ការប្រគល់ទៅឲ្យឆន្នអមាត្យរួចប្រាប់ថាឲ្យត្រឡប់ទៅព្រះរាជធានីវិញចុះ ប៉ុន្តែឆន្នអមាត្យប្រកែកពុំព្រមត្រឡប់ ដោយហេតុថា ព្រះអង្គមិនស្តេចយានទៅផ្ទះផង តែថាព្រះអង្គបង្ខិតបង្ខំឲ្យទាល់តែទៅបាន ។ ទ្រង់ផ្ញើដាប់ជាមួយនឹងឆន្នអមាត្យទៅផ្ទះផងនូវសារលិខិតដល់ព្រះវរបិតានឹងបិយមហាជនរបស់ព្រះអង្គ ។ ព្រះអង្គទ្រង់កាត់ព្រះកេសាដោយព្រះខាន់ដ៏មុត ហើយគ្រវែងចោលទាំងដុំទៅឯដ៏អាកាស ។ ទេវតាក៏ទទួលយកទៅដំកល់ទុកសម្រាប់ជាទីសក្ការបូជា ។ ទេវតាស្រាប់តែតំណែងខ្លួនជាពនេចរម្នាក់យកចីវរមកថ្វាយព្រះអង្គ ។ ក៏ទទួលហើយចូលទៅកាន់អាស្រមបទទៅ ។

គាថាទី ៧:- ពេលដែលចូលកាន់អាស្រមបទនោះ ព្រះសិទ្ធត្ថសមណៈ បានពតិមានពីអ្នកនៅក្នុងទីនោះថា តាបសទាំងនោះបានប្រតិបត្តិកម្មដ្ឋាន ដើម្បីគ្រាន់តែទៅកាន់ស្ថានទេវលោក បន្ទាប់ពីលោកនេះ

ទៅប៉ុណ្ណោះ ។ ធម៌នេះពុំបានញុំាងព្រះទ័យព្រះគោតមឲ្យយល់ព្រមផងទេ ព្រោះគោលបំណងរបស់ព្រះអង្គពុំមែនចង់ទៅទេវលោកទេ គឺចង់យកជ័យជំនះខាងការកើតស្លាប់ ។ ការទៅកាន់ទេវលោកព្រះសិទ្ធត្ថសមណៈគិតពុំឃើញដោយច្បាស់ថា "គ្រាន់តែជាការផ្លាស់បំណងមួយទៅបំណងមួយប៉ុណ្ណោះ" ។ ព្រះអង្គក៏ចាកចេញពីទីនោះ ហើយយាងទៅជួបនឹងតាបសម្នាក់ទៀតឈ្មោះអាឡារៈទៅ ។

គាថាទី ៨:- ប្រជាពលរដ្ឋ, ព្រះមាតាចុងព្រះអង្គ ព្រះវរបិតានឹងព្រះអគ្គមហេសី លុះឃើញតែនាយសារថីនឹងសេះអាជានេយ្យវិលត្រឡប់ទៅវិញដោយពុំឃើញព្រះអង្គសោះដូច្នេះ ក៏ទ្រហោយំទ្រហឹងឡើងទាំងអស់គ្នា ។ នាយករដ្ឋមន្ត្រីនៃព្រះបាទសិរីសុទ្ធោទនៈ នឹងឧន្ទអមាត្យសុំខ្ញុំដើរស្វែងរកព្រះសិទ្ធត្ថកុមារ ដើម្បីនឹងសុំយាងមកពជធានីវិញ ។

គាថាទី ៩:- រដ្ឋមន្ត្រីនឹងឧន្ទអមាត្យក៏ចេញដំណើរទៅស្វែងរកអស់កន្លែងជាច្រើន បានឃើញព្រះអង្គនៅក្នុងអាស្រមបទលោកតាអាឡារៈ ។ ពជទូតទាំងនោះ បានសុំអង្វរព្រះអង្គដោយវិធីច្រើនបែបច្រើនយ៉ាង សូមព្រះអង្គត្រឡប់មកកាន់ពជធានីបាសវិញ តែព្រះអង្គពុំទទួលសោះ ហើយពជទូតទាំងនោះក៏ត្រឡប់មកវិញ ដោយក្រៀមក្រំស្រងូតស្រងាត់ ។

គាថាទី ១០:- កាលដែលព្រះគោតម ស្តេចយាងទៅកាន់ក្រុង

រាជគ្រឹះ ព្រះចៅពិម្ពិសារបានទតតាមបង្អួចរាំងឃើញព្រះអង្គហើយស្តេចយាងដោយផ្ទាល់ព្រះអង្គ ទៅជួបនឹងព្រះវិជិតមារនៅឯគុហាខាងក្រៅទីក្រុង ។ ព្រះចៅផែនដីទ្រង់បានសន្ទនាជាមួយនឹងព្រះចៅសាសនាអស់កាលជាយូរ ហើយទ្រង់សាកសួរទៅទៀត អំពីហេតុដែលព្រះអង្គលះបង់ព្រះរាជអាណាចក្រចោល ។

គាថាទី ១១:- ព្រះបិតានៃលោកបានឆ្លើយថ្វាយព្រះពរតបនឹងសំណួររបស់ព្រះមហាក្សត្រយ៉ាងពិស្តារ ។ ព្រះនរបតីក៏ទ្រង់និមន្តទុកឲ្យហើយថា បើព្រះអង្គបានទទួលលទ្ធផលតាមបំណងហើយសូមមេត្តាប្រោសនិមន្តទៅកាន់ទីក្រុងខ្ញុំព្រះករុណាកុំខាន ។

គាថាទី ១២ :- ព្រះគោតមបានស្តេចយាងទៅជួបនឹងអាឡារតាបសហើយពិភាក្សាជាមួយនឹងតាបសនោះយ៉ាងវែង អំពីទ្រឹស្តីដែលអាឡារតាបសនោះបង្ហាត់បង្រៀន ។ ប៉ុន្តែ ព្រះវីរសាក្យមុនីទ្រង់ពុំបានទទួលយល់ស្របតាមទេ ដោយហេតុថា ការបង្រៀនជាបែបព្រហ្មញ្ញដែលនិយាយតែពីព្រលឹង (soul) នោះពុំទាន់[illegible]ទេ ។

បន្ទាប់ពីនោះទៅ ព្រះសាក្យគោតមស្តេចយាងទៅរកតាបសម្នាក់ទៀតនាមឧទក: ដែលបង្រៀនកម្មដ្ឋានព្រលឹងដូចអាឡារតាបសនោះដែរ ។ ព្រះអង្គក៏ពុំទទួលយល់តាមទៀត ហើយស្តេចយាងចេញពីទីនោះសំដៅទៅគយាសីសប្បទេស។ ក្នុងទីនោះព្រះអង្គបានជួបបញ្ចវគ្គិយ-

ភិក្ខុនៅត្រង់មាត់ច្រាំងស្ទឹងនេរញ្ជរា ដែលកំពុងតែស្ងឹងស្ងាត់ ឲ្យបានរួប បាកទុក្ខតូចនិងទុក្ខធំ ៗ ព្រះប្រមុខជាតិសាក្យមួយអន្ទើដោយភិក្ខុទាំង ៥ អង្គនោះទ្រង់អធិដ្ឋានតាំងព្រះទ័យ ធ្វើទុក្ករកិរិយាឲ្យអស់រយៈកាល៦ ឆ្នាំ ៗ ប៉ុន្តែភិក្ខុទាំងនោះរត់ចោលព្រះអង្គ ដែលព្រះអង្គទ្រង់តាំងព្យាយាមពុំទាន់នឹងគ្រប់ឆ្នាំផង; រីឯព្រះអង្គក៏ឥតបានសម្រេចព្រះសម្ពោធិញាណ ៗ ព្រះលោកនាថទ្រង់យល់ច្បាស់ថា ការតឹងរឹងហួសពេកជាហេតុនាំឲ្យខូចការ ហើយក៏បន្ធូរសោយព្រះក្រយាតាមធម្មតាវិញ ទ្រង់ធ្វើទៅតាមការពិសោធន៍ដែលព្រះអង្គធ្លាប់បានធ្វើហើយ នៅក្រោមដើមជម្ពូព្រឹក្សកាលនៅជាយុវកុមារនៅឡើយ ៗ គោលបំណងដែលព្រះអង្គទ្រង់យកជ័យលើគូសត្រូវគឺមរណភាពនោះឯង ដែលមានពលភាពស្មើរតែតទល់ពុំបាន ៗ ព្រះអង្គស្តេចយាងចេញទៅបិណ្ឌបាត ៗ ទេវតាក៏និមិត្តខ្លួនជានាយគោបាលចុះមកថ្វាយមធុបាយាស ដល់ព្រះអង្គពល់ៗថ្ងៃ ៗ បញ្ចសហាជីវិនភិក្ខុ លុះបានឃើញព្រះអង្គទ្រង់លះបង់តបធម៌ដូច្នេះហើយក៏លះបង់ព្រះអង្គចោល ៗ ព្រះដ៏ជាទីគោតសរសើរ លុះទ្រង់បានទទួលសុខភាពបរិបូណ៌ដូចដើមវិញហើយ ក៏នៅតែតានតឹងពីបញ្ហាសព្វញ្ញុតញ្ញាណទ្រង់គង់ក្រោមដើមពោធិព្រឹក្ស អធិដ្ឋានយ៉ាងដាច់ខាតថា "បើមិនសម្រេចគោលបំណងតាមប្រាថ្នាទេ អញនឹងមិនក្រោកឡើងជាដាច់ខាត" ៗ

គាថាទី ១៣ :- មារាធិរាជដែលជាមេអវមង្គល លុះបានដឹងច្បាស់ថា សមណគោតមនឹងផុតចាកកណ្តាប់ដៃអាណានិគមក្នុងលោកនេះដូច្នេះហើយ ក៏ឆ្លៀតឱកាសប្រើឧបាយកលក្រខ្វក់ជាច្រើនបែបច្រើនយ៉ាង ដើម្បីបំផ្លិចបំផ្លាញគ្រោងការណ៍របស់ព្រះអង្គ ដោយយកបវរកញ្ញាជានុយ ប៉ុន្តែមារាធិរាជចាញ់ព្រះអង្គជាស្វ័យប្រវត្តិ ហើយរត់ចាកពីទីនោះទៅ ។ ពពួកទេវតាក៏បង្ហូរបុប្ផាពីលើស្ថានសួគ៌ចុះមក លើព្រះវិជិតមារជានិមិត្តរូបនៃជ័យជំនះរបស់ព្រះអង្គ ។

គាថាទី ១៤:- គាថានេះថ្លែងពីសិទ្ធត្ថសមណៈបានត្រាស់ដឹងអនុត្តរ-សម្មាសម្ពោធិញាណ ។ បន្ទាប់ពីបានផ្ចាញ់មារាធិរាជមកព្រះលោកាចារ្យទ្រង់ចូលកាន់ឈានយ៉ាងតឹងរ៉ឹង បានទទួលលទ្ធផលដ៏ប្រពៃក្នុងការជ្រាបច្បាស់នូវកំណើតពីអតីត, យល់ច្បាស់នូវកំណើតបច្ចុប្បន្នរបស់សត្វលោក និងជ្រាបច្បាស់នូវហេតុដែលសត្វលោកសោយទុក្ខ និងផលដែលសត្វ-លោកសោយសុខ ព្រោះតែផលនៃអំពើដែលខ្លួនបានធ្វើហើយ ។

# លោកុត្តរាភិសម័យ

## ភាគទី ២

## លោកុត្តរធម៌

អ្នកឧកញ៉ា ជា-សាឧ អតីតរដ្ឋមន្ត្រី រៀបរៀង

(តមក)

---

ឯលោកុត្តរធម៌ ប្រែថា ធម៌សម្រាប់ចម្លងសត្វ ឲ្យឆ្លងចេញរួចចាក លោកគឺចាកមនុស្សលោក ទេវលោក និងព្រហ្មលោក ។ ឯលោកុត្តរធម៌នេះ គឺសំដៅមគ្គ ៤ ផល ៤ និងនិព្វាន, ពីព្រោះមគ្គ ផល និព្វាន នេះលោកចាត់ទុក ៖

១– ជា វិមោក្ខធម៌ គឺធម៌អាចញុំាងសត្វឲ្យរួចចាកកិលេសដែលជាគ្រឿងសៅហ្មងនៃចិត្ត ។

២– ជា មោក្ខធម៌ គឺធម៌អាចញុំាងសត្វឲ្យរួចចាកកងទុក្ខមានជាតិទុក្ខជាដើម ។

៣– ជា លោកនិស្សរណធម៌ គឺធម៌ជាគ្រឿងរលាស់ខ្លួនឲ្យរួចចេញចាកលោក ។

គឺការត្រាស់ដឹងមគ្គ ៤ ផល ៤ និងនិព្វាននេះហើយ ដែលហៅថា លោកុត្តរាភិសម័យ ។

បើដូច្នេះគប្បីចោទសួរថាតើមគ្គ ៤ ផល ៤ និងនិព្វាននោះគឺជាអ្វីទៅ

បានជាបណ្ឌិតលោកចាត់ទុកថា ជាលោកុត្តរធម៌ គឺធម៌អាចបម្លងសត្វឲ្យឆ្លងចេញរួចផុតចាកត្រៃលោកបាននោះ? ។

ចំពោះសំនួរនេះខ្ញុំសូមឆ្លើយដកបថា មគ្គ ៤ ផល ៤ នោះមិនគឺអ្វីទេ គឺពិតជានាមនៃមគ្គចិត្ត ៤ និងផលចិត្ត ៤ ដែលប្រព្រឹត្តទៅក្នុងលោកុត្តរភូមិនោះឯង ។ ឯមគ្គចិត្ត ៤ នោះជាលោកុត្តរចិត្តដែលលះសំយោជនៈ ១០ តាមលំដាប់មគ្គដាច់ស្រឡះដោយសមុច្ឆេទបហានហើយ ផលចិត្ត ៤ នោះ ជាលោកុត្តរចិត្តដែលរួចចាកសំយោជនៈ ១០ តាមលំដាប់ផលដោយនិស្សរណវិមុត្តិ ដូចខ្ញុំបានអធិប្បាយបញ្ជាក់នៅផ្នែកលោកុត្តរចិត្តពីខាងដើមនេះសព្វគ្រប់ស្រាប់ ។

ដោយហេតុនេះទើបមគ្គ ៤ នោះគឺ :

សោតាបត្តិមគ្គ ជានាមនៃមគ្គចិត្តទី ១ ដែលលះសក្កាយទិដ្ឋិ វិចិកិច្ឆា និងសីលព្វតបរាមាស ។

សកទាគាមិមគ្គ ជានាមនៃមគ្គចិត្តទី ២ ដែលលះសំយោជនៈ ៣ ដូចខាងលើនេះ និងនឿយណាយចំពោះកាមរាគនិងបដិឃៈទៀត ។

អនាគាមិមគ្គ ជានាមនៃមគ្គចិត្តទី ៣ ដែលលះសំយោជនៈ ៥ គឺ ៣ ដូចខាងលើនេះ និង ២ ទៀតគឺ កាមរាគនិងបដិឃៈ ។

អរហត្តមគ្គ ជានាមនៃមគ្គចិត្តទី ៤ ដែលលះសំយោជនៈ ១០ គឺ ៥ ដូចខាងលើនេះ និង ៥ ទៀតគឺរូបរាគ, អរូបរាគ, មានះ, ឧទ្ធច្ចៈនិងអវិជ្ជា ។

ចំណែកឯផល ៤ នោះគឺៈ

សោតាបត្តិផល ជានាមនៃផលចិត្តទី១ដែលរួចចាកសំយោជនៈ ៣ គឺសក្កាយទិដ្ឋិ, វិចិកិច្ឆា នឹងសីលព្វតបរាមាស ។

សកទាគាមិផល ជានាមនៃផលចិត្តទី ២ដែលរួចចាកសំយោជនៈ ៣ ដូចខាងលើនេះហើយទៀយណាយបំពោះកាមរាគ នឹងបដិឃៈទៀត។

អនាគាមិផល ជានាមនៃផលចិត្តទី ៣ ដែល រួចចាកសំយោជនៈ ៥ គឺ ៣ ខាងលើនេះ នឹង ២ ទៀតគឺ កាមរាគនឹងបដិឃៈ ។

អរហត្តផល ជានាមនៃផលចិត្តទី ៤ ដែលរួចចាកសំយោជនៈ ១០ គឺ ៥ ដូចខាងលើនេះ នឹង ៥ ទៀតគឺ រូបរាគ, អរូបរាគ, មានះ, ឧទ្ធច្ចៈនឹងអវិជ្ជា ។

អាស្រ័យហេតុនេះ ទើបការត្រាស់ដឹងមគ្គ ៤ នឹងផល ៤ នោះគឺសំដៅការសម្រេចឡើងនៃមគ្គចិត្ត ៤ នឹងផលចិត្ត ៤ ដូចបានអធិប្បាយខាងលើនោះឯង ។

បើដូច្នេះតើនិព្វានោះគឺជាអ្វីទៅ ?

រីឯនិព្វានសព្ទនេះ គឺគ្រាន់តែជានាមនៃបរមសុខដូចមគ្គនឹងផលជានាមនៃមគ្គចិត្តនឹងផលចិត្តនោះដែរ ។

ដើម្បីងាយយល់នូវអត្ថរសនៃនិព្វាននោះ ខ្ញុំសូមបញ្ជាក់ថា អរហត្ត-

ផលគឺផលចិត្ត ៤ ដែលរួចចាកសំយោជនៈ ១០ នោះជាលោកុត្តរចិត្ត រួចផុតចាកកំដៅភ្លើងកិលេស ហើយតាំងនៅជាសុខុមាលភាព លែងស្គាល់សេចក្ដីក្ដៅក្រហល់ក្រហាយ, សេចក្ដីអន្ទះអន្ទែង និងសេចក្ដីស្រេកឃ្លាននូវអារម្មណ៍ ៥ ទៀតហើយ ។

បើដូច្នេះឃើញថានិព្វានគឺបរមសុខ ដែលសម្រេចកើតមានឡើងដោយការត្រាស់ដឹងនូវអរហត្តផលជាមូលហេតុ ពីព្រោះអរហត្តផលដែលស្ងាត់នៅឆ្ងាយពីកំដៅភ្លើងកិលេស តែងតែផ្ដល់ឲ្យព្រះអរហន្តនូវអានិសង្ស ១ ជាពិសេស គឺបរមសុខនោះឯង ។

ប៉ុន្តែនិព្វានគឺបរមសុខនោះមាន ២ ប្រការគឺ ៖ ឧបាទិសេសនិព្វាន គឺបរមសុខដោយរួចផុតចាកកំដៅភ្លើងកិលេស ១ និងអនុបាទិសេសនិព្វាន គឺបរមសុខដោយរួចផុតចាកទាំងកំដៅភ្លើងកិលេស(១) និងកំដៅភ្លើងទុក្ខ(២)ផង ១ ។

ឯឧបាទិសេសនិព្វាន គឺបរមសុខដោយរួចចាកកំដៅភ្លើងកិលេស នោះត្រូវទុកជាបរមសុខក្នុងបច្ចុប្បន្ន ពីព្រោះព្រះអរហន្តគប្បីបានសម្រេចនូវបរមសុខ គឺឧបាទិសេសនិព្វាននោះនៅក្នុងបច្ចុប្បន្ន គឺនៅខណៈដែលព្រះអរហន្តអង្គនោះ បានធ្វើឲ្យជាក់ច្បាស់នូវវិមុត្តិគឺការរួចចាកកិលេស ៣ ប្រការដែលជាគ្រឿងបញ្ជាក់ឲ្យដឹងថាកិលេស ឬ ភ្លើងកិលេសរលត

១ ឯភ្លើងកិលេស គឺរាគៈទោសៈមោហៈ ។ ២ ឯភ្លើងទុក្ខ គឺជាតិ,ជរា, ព្យាធិ និងមរណៈ ។

អស់ពីខន្ធសន្តានទៅហើយ ។ ត្រង់នេះហើយលោកសន្មតថាព្រះអរហន្ត បានធ្វើនិព្វានសច្ឆិកិរិយា គឺកិរិយាជាក់ច្បាស់នៃនិព្វានឲ្យកើតប្រាកដឡើងហើយ ។

រីឯវិមោក្ខ ៣ ប្រការនោះគឺ ៖

សុញ្ញតវិមោក្ខ គឺការរួចចាកកិលេសដោយសូន្យគ្មានកិលេស ១,

អនិមិត្តវិមោក្ខ គឺការរួចចាកកិលេសដោយគ្មានអ្វីជាគ្រឿងសំគាល់ជាកិលេស ១,

អប្បណិហិតវិមោក្ខ គឺការរួចចាកកិលេសដោយគ្មានអ្វីជាទីតាំងនៃកិលេស ១, ។

ដោយហេតុនេះ ទើបឧបាទិសេសនិព្វានគឺបរមសុខក្នុងបច្ចុប្បន្ននោះ ជាបរមសុខប្រកបដោយសុខយ៉ាងសុខុមក្រៃលែង មាន៥ប្រការជាដើមគឺ៖

១- អនាសវសុខ គឺសុខដោយគ្មានអាសវៈដែលជាកិលេសដេកត្រាំក្នុងសន្តានចិត្ត ។

២- និរាមិសសុខ គឺសុខដោយគ្មានអាមិស គឺគ្មានលាយឡំដោយកាមគុណ ។

៣- ចេតសិកសុខ គឺសុខខាងផ្លូវចិត្ត ។

៤- ឯកន្តសុខ គឺសុខតែមួយយ៉ាងគ្មានលាយឡំដោយទុក្ខ ។

៥- សន្តិសុខ គឺសុខយ៉ាងស្ងប់ស្ងាត់ក្រៃលែង ។

រីឯអនុបាទិសេសនិព្វាន គឺបរមសុខដោយរួចផុតចាកភ្លើងកិលេស នឹងភ្លើងទុក្ខផងនោះ ត្រូវទុកជាបរមសុខទៅអនាគត ពីព្រោះព្រះអរហន្ត គប្បីសម្រេចបរមសុខគឺអនុបាទិសេសនិព្វាននោះទៅពេលខាងមុខ គឺនៅពេលដែលព្រះអរហន្តអង្គនោះរំលត់ខន្ធ ដោយអាយុក្ស័យចូលកាន់បរិនិព្វាន ។

ដោយហេតុនោះ ទើបអនុបាទិសេសនិព្វាន គឺបរមសុខទៅអនាគតនោះ ត្រូវចាត់ទុកជាបរមសុខយ៉ាងសុខុមក្រៃលែង ប្រកបដោយបរមសុញ្ញ ២ ប្រការ គឺសុញ្ញដោយកិលេសរលត់អស់គ្មានសេសសល់ ១ នឹងសុញ្ញដោយបញ្ចក្ខន្ធរលត់អស់ ១ ។

គឺបរមសុញ្ញប្រកបដោយសុញ្ញ ២ ប្រការនេះហើយ ដែលជាមូលហេតុនឹងញុំាងព្រះអរហន្តអង្គនោះ ឲ្យបានដល់នូវអវសានជាតិធ្លងចេញរួចផុតចាកត្រៃលោក លែងត្រឡប់វិលកើតវិលស្លាប់ក្នុងត្រៃភពទៀត ។

អាស្រ័យហេតុនេះ ទើបលោកចាត់ទុកមគ្គ ៤ ផល ៤ នឹង និព្វានជាលោកុត្តរធម៌ គឺធម៌អាចចម្លងសត្វឲ្យឆ្លងចេញរួចផុតចាកលោកបានដោយប្រការដូច្នេះឯង ។

សរុបសេចក្តីទៅឃើញថា មគ្គ ផល និព្វាន គ្រាន់តែជានាមសម្រាប់ហៅមគ្គចិត្ត ៤, ផលចិត្ត ៤ នឹងបរមសុខដែលសម្រេចឡើងដោយមគ្គចិត្ត

និងផលចិត្តនោះឯង តប៉ុណ្ណោះ ។

ដោយហេតុនោះហើយបានជា មគ្គ ផល និព្វាននោះធ្វើឲ្យពុទ្ធបរិស័ទភាគច្រើនមានសេចក្តីឆ្ងល់ពន់ពេក ដោយនឹកគិតមិនយល់ថា តើមគ្គ ផល និព្វាននោះគឺជាអ្វីប្រាកដសោះ, ព្រោះបានដឹងតែនាមមិនដែលបានឃើញនូវរូបនៃមគ្គផលនិព្វាននោះដូចម្តេចសោះ ។

ខ្ញុំសង្ឃឹមទុកជាមុនថា រូបកាយមគ្គផលនិព្វានដែលខ្ញុំទើបនឹងកកាយរកឃើញនោះ មុខតែនឹងញាំងអស់លោកឲ្យលែងនឹកគិតសង្ស័យថា និព្វានជាឋានព្រហ្មលោក ឬថាជាឋានមានវិមាន ឬមានគ្រឿងទៀតហើយ, ពីព្រោះរូបមគ្គផលនិព្វានមានលក្ខណៈគ្រប់គ្រាន់ហើយជាក់ច្បាស់ គួរឲ្យវិនិច្ឆ័យថាត្រឹមត្រូវពិតមែន ។

ម្យ៉ាងទៀត ខ្ញុំសូមលើកយកព្រះពុទ្ធតម្រាស់មួយអន្លើដែលថា ៖

" និព្វានំ បរមំ សុខំ " បរមសុខគឺនិព្វាន ។

" និព្វានំ បរមំ សុញ្ញំ " បរមសូន្យគឺនិព្វាន ។

មកចុះផ្សាយនៅទីបញ្ចប់នេះ ដើម្បីជូនអស់លោកអ្នកដែលអានសៀវភៅលោកុត្តរភិសម័យនេះ ពិនិត្យនឹងពិចារណាឲ្យរឹតតែបានដឹងច្បាស់តទៅទៀតតាមត្រូវការចុះ ។

## លោកុត្តរភិសម័យ

### ភាគទី ៣ បដិបទា

ឯបដិបទាដែលអាចញ៉ាំងការត្រាស់ដឹងមគ្គ ៤ ផល ៤ គោលគឺមគ្គចិត្ត ៤ ដែលលះសំយោជនៈ១០ ដាច់ស្រឡះដោយសមុច្ឆេទប្បហាន និងផលចិត្ត ៤ ដែលរួចចាកសំយោជនៈ១០ ផុតស្រឡះដោយនិស្សរណវិមុត្តិ ឲ្យសម្រេចឡើងបាននោះ គឺសំដៅអដ្ឋង្គិកមគ្គដែលប្រកបដោយអង្គ ៨ មានអង្គសម្មាទិដ្ឋិជាដើមនិងអង្គសម្មាសមាធិជាទីបំផុតនោះឯង ពីព្រោះអដ្ឋង្គិកមគ្គនោះ ជាភាវេតព្វធម៌ដែលអរិយបុគ្គលគប្បីចំរើនឲ្យសម្រេចគ្រប់អង្គទាំង ៨ ដើម្បីនឹងបំពេញត្រៃខន្ធគឺសីលខន្ធ, សមាធិខន្ធនិងបញ្ញាខន្ធ ឲ្យពោរពេញទៅដោយគុណផ្សេង ៗ ដែលលោកចាត់ទុកជាគ្រឿងអាវុធកំដៅខន្ធសន្តានឲ្យរីងហួតស្ងួតចាកកាទិកិលេស គឺសំយោជនៈ ១០ នោះឯង ។

រីឯត្រៃខន្ធគឺទាំង ៣ នោះមានគុណធម៌ផ្សេង ៗ ដូចតទៅនេះគឺ ៖

សីលក្ខន្ធ គឺគុណសីលមានកាយសុចរិត ៣ វចីសុចរិត ៤ និងមនោសុចរិត ៣ ។

សមាធិក្ខន្ធ គឺគុណសមាធិមានអប្បនាសមាធិ និងឈានចិត្ត ៨

បញ្ញាក្ខន្ធ គឺគុណបញ្ញាមានវិបស្សនាញាណ ១០ ។

ឯសីល សមាធិ និងបញ្ញានេះ ដែលនឹងសម្រេចកើតឡើងជាខន្ធ

បុគ្គលបាននោះ ក៏ត្រូវអាស្រ័យការចំរើនកម្មដ្ឋាន ២ គឺ សមថកម្មដ្ឋាន នឹងវិបស្សនាកម្មដ្ឋាន ពីព្រោះការចំរើនសមថកម្មដ្ឋាន មានការចំរើនឈានជាទីបំផុតតែងផ្ដល់ឲ្យយោគាវចរនូវសមាធិ នឹងឈានចិត្ត ៨ មានរូបជ្ឈានចិត្ត ៤ ជាដើម ហើយការចំរើនវិបស្សនាកម្មដ្ឋាន ក៏រមែងតែហុចនូវវិបស្សនាញាណ ១០ ពុំខានឡើយ ។

គឺសមាធិចិត្ត, ឈានចិត្ត ៨ នឹងវិបស្សនាញាណ ១០ នោះហើយ ដែលជាគ្រឿងផុតកំដៅពេលខន្ធសន្ដាន ឲ្យរីងហួតស្ងួតបាត់ពពួកទឹកកិលេសអស់ទៅបាន ពីព្រោះឈានចិត្តដែលសម្បយុត្តដោយអង្គឯកគ្គតា នឹងឧបេក្ខាតែងតែតាំងនៅជាកណ្ដាលជានិច្ច ព្រងើយកន្ដើយមិនអើពើ មិនសោមនស្ស មិនទោមនស្សចំពោះឥដ្ឋានិដ្ឋារម្មណ៍ ហាក់ដូចជាមិនបិទទ្វារមិនឲ្យរាគៈ ទោសៈ ចូលមកកើតក្នុងខន្ធសន្ដានបាន ហើយធ្វើឲ្យខន្ធសន្ដាននោះរីងស្ងួតបាត់ពពួកទឹកកិលេសនោះអស់ទៅ ។

រីឯវិបស្សនាញាណ គឺញាណដែលដឹងច្បាស់នូវដំណើរនៃសង្ខារធម៌ទៅតាមការពិតនោះ ក៏រមែងតែប្រឆាំងពកំងមិនឲ្យមោហៈ នឹងសក្កាយទិដ្ឋិចូលមកកើតក្នុងខន្ធសន្ដានបាន ហើយធ្វើខន្ធសន្ដាននោះឲ្យរីងហួតផុតបាត់សក្កាយទិដ្ឋិ នឹងវិចិកិច្ឆាអស់ទៅ ។

កាលបើឈានចិត្ត ៤ នឹងវិបស្សនាញាណ ១០ កើតមានបរិបូណ៌ក្នុងខន្ធសន្ដាន ក៏ជាបច្ច័យតាក់តែងវិសុទ្ធិ គឺសេចក្ដីបរិសុទ្ធិ ៧ ប្រការដែល

ជាសម្ផានៃការត្រាស់ដឹងមគ្គ ៤ ផល ៤ និងនិព្វានឲ្យសម្រេចឡើង ជាលំដាប់ ។

វិសុទ្ធិ ៧ ប្រការនោះ គឺ៖

១- សីលវិសុទ្ធិ បរិសុទ្ធនៃសីល

២- ទិដ្ឋិវិសុទ្ធិ បរិសុទ្ធនៃការយល់ឃើញត្រូវ

៣- កង្ខាវិតរណវិសុទ្ធិ បរិសុទ្ធនៃការឆ្លងរួចចាកសេចក្ដីសង្ស័យ

៤- មគ្គាមគ្គញាណទស្សនវិសុទ្ធិ បរិសុទ្ធនៃការឃើញច្បាស់នូវមគ្គដែលជាសម្មាមគ្គត្រឹមត្រូវ ។

៥- បដិបទាញាណទស្សនវិសុទ្ធិ បរិសុទ្ធនៃការឃើញច្បាស់នូវបដិបទាដែលអាចញ៉ាំងការត្រាស់ដឹងមគ្គផលនិព្វាន ឲ្យសម្រេចឡើងបាន ។

៦- ញាណទស្សនវិសុទ្ធិ បរិសុទ្ធនៃការដឹងច្បាស់ទៅតាមការណ៍ពិត ។

៧- ចិត្តវិសុទ្ធិ បរិសុទ្ធនៃចិត្ត

៨- បញ្ញាវិសុទ្ធិ បរិសុទ្ធនៃបញ្ញា

៩- វិមុត្តិវិសុទ្ធិ បរិសុទ្ធនៃការរួចចាកកិលេស

វិធីពិសោធន៍សម្រាប់ចំរើនកសិណ ចំរើនវិបស្សនា និងចំរើនឈានដែល

នឹងមានដំណើរប្រព្រឹត្តទៅដូចម្តេចនោះ ខ្ញុំនឹងធ្វើអត្ថាធិប្បាយពន្យល់តាមសមត្ថភាព ដែលខ្ញុំអាចនឹងធ្វើទៅបានដូចមានតទៅនេះ ។

## ក- សមថកម្មដ្ឋាន

ឯសមថកម្មដ្ឋាននេះមាន ៤០ យ៉ាង ចែកចេញជា ៧ពួកគឺ៖

កសិណ ១០ – អសុភ ១០ - អនុស្សតិ១០ អប្បមញ្ញា ៤ – អរូប ៤ – អាហារេបដិកូលសញ្ញា ១ ធាតុវវត្ថាន ១ ។

ការចំរើនសមថកម្មដ្ឋាន គឺសំដៅការចំរើនកសិណជាដើម នឹងការចំរើនឈានជាទីបំផុត ។

### ១- អំពីកសិណ

ឯកសិណសព្ទនេះ មានសេចក្តីអធិប្បាយក្នុងសៀវភៅពុទ្ធគុណ បញ្ជាក់មួយអន្លើថា ៖

“ចិត្តឯណាដែលត្រពេស់ប្រព្រឹត្តវិលវល់នៅតែក្នុងកន្លែងមួយ ព្រោះហេតុនោះ បានជាចិត្តនោះឈ្មោះថា កសិណ ”

“ ឯមណ្ឌលគឺវង់មូលមានទំហំ ១ ចំអាម ៤ ធ្នាប់ក្តី និមិត្តដែលតាំងឡើងក្នុងមណ្ឌលនោះក្តី សមាធិចិត្តដែលមណ្ឌលនោះជាអារម្មណ៍ក្តី ក៏ហៅថាកសិណដែរ ” ។

បើសិនជាលើកយក បថវីកសិណ មកធ្វើជាអារម្មណ៍ មកធ្វើជា-ឧទាហរណ៍នោះ សេចក្តីបញ្ជាក់ដូចខាងលើនេះ នាំឲ្យយល់បានដូច្នេះគឺ៖

(នៅមានត)

# ព្រះអភិធម្មបិដក

# គម្ពីរព្រះយមក:

លោក ប៊ូ-ប៉ូ ប្រែរៀបរៀង

(តមក)

---

សុត្តំ សជ្ឈាយិត្វា និសិន្នេសុ កាលភិក្ខុទាំងឡាយអង្គុយសូធ្យាយព្រះសូត្រ ភិក្ខុមួយអង្គសួរថា ព្រះសូត្រប្រាកដដល់លោកទាំងឡាយយ៉ាងណា ? ភិក្ខុនោះប្រាប់ថា ព្រះសូត្រនេះប្រាកដដល់ខ្ញុំដូចជាទឹកហូរធ្លាក់ពីកំពូលភ្នំ ។ អង្គឯទៀតប្រាប់ថា ព្រះសូត្រប្រាកដដល់ខ្ញុំដូចជាព្រៃ ។ អង្គឯទៀតប្រាប់ថា ព្រះសូត្រប្រាកដដល់ខ្ញុំដូចជាដើមឈើមានម្លប់ត្រជាក់ប្រកបដោយស្លឹក នឹងមែកបរិបូណ៌ ។ ឯកំ ឯវំ សុត្តំ ព្រះសូត្រតែមួយ ប្រាកដដល់ភិក្ខុទាំងឡាយផ្សេង ៗ គ្នាដូច្នេះ ដោយសញ្ញានៃភិក្ខុទាំងឡាយនោះផ្សេង ៗ គ្នា មិនដូចគ្នាមានឧបមាយ៉ាងណា ។ ឯកំ ឯវំ កម្មដ្ឋានំ ព្រះកម្មដ្ឋានតែមួយតែនិមិត្តប្រាកដឡើងនោះផ្សេង ៗ គ្នា មិនដូចគ្នាទេ មានឧបមេយ្យដូច្នោះ ។ ចាប់ដើមអំពីនិមិត្តកើតប្រាកដឡើង នីវរណធម៌ទាំងប្រាំមានកាមច្ឆន្ទនីវរណៈជាដើម ក៏ខ្ចាត់ចេញពីចិត្តនៃព្រះយោគាវចរ ។ លុះព្រះយោគាវចរសង្កត់សង្កិននីវរណៈធម៌ទាំងប្រាំបានហើយ កិលេសខាងក្នុងក៏ស្ងប់ស្ងាត់ សតិក៏នឹងកើតមានឡើងប្រាកដ ចិត្តក៏នឹងតាំងនៅមាំមួន

ល្អ មិនគម្រើកញាប់ញ័រ ៗ ឯនិមិត្តនោះ ភិក្ខុគប្បីកំណត់ទុកក្នុងចិត្ត កុំគប្បីពិចារណាដោយលក្ខណៈ គប្បីរក្សាទុកឲ្យល្អបីដូចជាខត្តិយអគ្គម-ហេសីដែលទ្រង់ព្រះគភ៌បរមចក្រពត្តិ ៗ ពុំនោះសោត ព្រះយោគាវចរ គប្បីរក្សានូវនិមិត្តនោះទុក ឲ្យដូចជាអ្នកស្រែរក្សានូវពូជនៃស្រូវដំណើប ឲ្យគង់នៅ គប្បីវៀរលែងនូវទីកន្លែងមិនសប្បាយ ៧ កន្លែង, សេពនូវទីសប្បាយ ៧ កន្លែង មានអាវាសនាំឲ្យបានសប្បាយជាដើម ហើយគប្បីរក្សានិមិត្តទុក កាលរក្សានូវនិមិត្តទុកល្អហើយ ញ៉ាំងនិមិត្តឲ្យចំរើនឡើង ឲ្យដុះដាលឡើង ដោយអំណាចកំណត់ទុកក្នុងចិត្ត ហើយគប្បីភាវនាញ៉ាំងអប្បនាឈានឲ្យបរិបូណ៌ ហើយប្រព្រឹត្តនូវសេចក្តីព្យាយាមឲ្យស្មើ កុំឲ្យធូរតឹងធ្ងន់ស្រាលដាងគ្នា ហើយគប្បីចំរើននូវចតុត្ថជ្ឈាន, បញ្ចមជ្ឈាន ក៏នឹងបង្កើតក្នុងនិមិត្តដោយលំដាប់ លុះចតុត្ថជ្ឈាននោះស្ទាត់ជំនាញដោយវសីប្រាំប្រការហើយ គប្បីកំណត់នូវនាមនឹងរូប ដោយព្រះត្រៃលក្ខ-ណញ្ញាណ គឺពិចារណានូវបញ្ចសង្ខារដោយ អនិច្ចំ, ទុក្ខំ, អនត្តា ៗ ហេតុអ្វីបានជាឲ្យព្រះយោគាវចរធ្វើយ៉ាងនេះ ព្រោះហេតុថា ព្រះយោ-គាវចរអ្នកបំពេញវិធីចំរើនអានាបានស្សតិកម្មដ្ឋាននោះ កំណត់នូវនាមនឹងរូបហើយ ទើបចំរើននូវព្រះវិបស្សនា ព្រោះហេតុភិក្ខុនោះតាំងទុកនូវព្រះវិបស្សនា ពិចារណាឃើញដោយព្រះត្រៃលក្ខណញ្ញាណ នឹងឃើញនូវទីកើត, ទីរលត់នៃខ្យល់អស្សាសៈបស្សាសៈថា ករជ្ជកាយនឹងចិត្តនេះ

ជាទីកើតនៃខ្យល់ដង្ហើមចេញចូល ហើយឃើញទីរលត់ថា ករជកាយ នឹងចិត្តនេះរលត់ហើយ ខ្យល់ដង្ហើមចេញចូលក៏លែងកើត ក្នុងលំដាប់នោះ ប្រាជ្ញាបំបាត់សេចក្ដីសង្ស័យក្នុងធម៌វិសេសតៗ ឡើងទៅ ដរាបដល់ព្រះអរិយមគ្គព្រះអរិយផល ។ អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា ដែលពោលមកទាំងនេះដោយអំណាចនៃបុគ្គលដែលមានបុព្វាសនា ទើបបានសម្រេចព្រះអរិយមគ្គព្រះអរិយផលក្នុងជាតិនោះ មានសតិតាំងមាំហើយ ក៏នឹងបានសម្រេចដូចសេចក្ដីប្រាថ្នា បើមានបារមីនៅពុំទាន់ចាស់ក្លា តែមានសតិតាំងមាំក្នុងការធ្វើបរិកម្មភាវនា ក៏អាចការពារនូវអន្តរាយបាន នឹងជាឧបនិស្ស័យបច្ច័យទៅក្នុងបរបរភពខាងមុខ ការិមដ្ឋិ បង នឹងបាច់ស្រដីទៅថ្វីដល់លោកដែលមានបារមីចាស់ក្លា តាំងសតិក្នុងកម្មដ្ឋានភាវនា គ្រាន់តែបុគ្គលមានសតិតាំងមាំ មិនបានរៀនក្នុងការចំរើនមន្ត ដែលអាចារ្យប្រាប់ ក៏អាចការពារអន្តរាយអំពីចោរបាន នឹងលើកអតីតនិទានមកបញ្ជាក់ឲ្យឃើញច្បាស់, សេចក្ដីថា ៖

មានដំណាលថា មានបុរសម្នាក់នៅក្នុងនគរពារាណសី ទៅរៀនវិជ្ជាឯក្រុងតក្កសិលា ។ អាចារ្យប្រាប់សិល្បសាស្ត្រទាំងឡាយឲ្យចាំមិនបាន ។ តែបុរសនោះប្រកបដោយវត្តប្រតិបត្តិអាចារ្យ ។ ទើបចងមន្តមួយបទឲ្យដោយសេចក្ដីករុណា មន្តនោះថា ឃដេសិ កឹការណា ឃដេសិ អហំបិ តំ ជានាមិ បុរសនោះរៀនចាំស្ទាត់ហើយ

លាអាចារ្យត្រឡប់មកផ្ទះវិញ ឧស្សាហ៍សូត្រទឹករំពុកជានិច្ច មិនឲ្យ
លោះខាន ។

ថ្ងៃមួយ ព្រះមហាក្សត្រត្រាច់យាងត្រួតត្រាសង្កេតមើលអាណាប្រជារាស្ត្រក្នុងពេលរាត្រី គង់ឈរ នៅត្រង់ស្រមោលផ្ទះបុរសនោះ ។ ពេលនោះ មានចោរមកប្រុងលួចទ្រព្យរបស់បុរសនោះៗ ភ្ញាក់ឡើងសូត្ររំពុកមន្តនោះ ចោរបានឮក៏ភ័យរត់ចេញទៅ ។ លុះព្រឹកឡើងព្រះមហាក្សត្រត្រាស់បង្គាប់ឲ្យចាប់ចោរនោះយកទៅធ្វើទោស ហើយបង្គាប់ឲ្យបុរសនោះចូលមកគាល់ សួរជ្រាបសេចក្តីហើយសុំរៀនមន្តពីបុរសៗក៏ព្រមបង្រៀនថ្វាយ ។ ចំណែកសេនាបតីរបស់ព្រះអង្គ ឃុបឃិតសមគំនិតនឹងខ្មាន់ព្រះកេស ប្រាប់ឲ្យផ្តាច់ព្រះជន្មព្រះមហាក្សត្រនៅវេលាដែលចំរើនព្រះកេសាថ្វាយ ។ ព្រះរាជាចំរើនភាវនាបរិកម្មមន្តនោះឥតដាច់ពីព្រះឱស្ឋ ។ ខ្មាន់ព្រះកេសក៏ភ័យតក់ស្លុតទទួលសារភាពសូមជីវិតហើយ ក្រាបទូលតាមការពិតថា អំពើនេះ ជាគំនិតរបស់សេនាបតី ។ ព្រះរាជាត្រាស់ឲ្យហូតងារសេនាបតីចេញ ហើយទ្រង់ព្រះមេត្តាប្រោសព្រះរាជទានដំណែងសេនាបតីឲ្យបុរសជាអាចារ្យអ្នកបង្រៀនមន្តព្រះអង្គ ។ បុរសនោះបានទីជាសេនាបតី ។ ឯព្រះមហាក្សត្រពុំបានក្ស័យព្រះជន្មនឹងអំពើក្បត់ ព្រោះព្រះអង្គមិនភ្លេចស្មារតីចំរើនមន្តជានិច្ច គឺទ្រង់ប្រកបព្រះអង្គទុកក្នុងអៈមា-ទោ ទាល់តែបានសម្បត្តិនឹងបានព្រះជន្មប្រាកដដូច្នេះ ។ ហេតុនោះ

បានជាព្រះមានព្រះភាគទ្រង់ពប់អមោហៈ បញ្ចូលក្នុងមូលនៃកុសលក្នុងមូលយមកៈ ក្នុងគម្ពីរព្រះយមកៈនេះ ។

## អកុសលមូល

យេ កេចិ អកុសលា ធម្មា សព្វេ តេ អកុសលមូលា, យេ វា បន អកុសលមូលា សព្វេ តេ ធម្មា អកុសលា ។ យេ កេចិ អកុសលា ធម្មា សព្វេ តេ ធម្មា អកុសលមូលេន ឯកមូលាតិ ។

លំដាប់នេះ នឹងវិសជ្ជនាក្នុងមូលយមកៈចំណែកអកុសលតទៅ តាមដំណើរសេចក្ដីថា កកវា ព្រះមានព្រះភាគកាលព្រះអង្គត្រាស់ទេសនាក្នុងមូលនៃកុសលចប់ហើយ ក្នុងលំដាប់នោះទើបទ្រង់ត្រាស់ទេសនាក្នុងមូលនៃអកុសលជាលំដាប់តទៅ ទ្រង់ត្រាស់បុច្ឆាថា យេ កេចិ អកុសលា ធម្មា ធម៌ទាំងឡាយណា ដែលជាអកុសល ធម៌ទាំងឡាយទាំងពួងនោះឬជាមូលនៃអកុសល ធម៌ទាំងឡាយដែលជាមូលនៃអកុសលនោះឬឈ្មោះថា អកុសលធម៌ ? ព្រះអង្គទ្រង់ត្រាស់បុច្ឆាដូច្នេះហើយ ទើបទ្រង់ត្រាស់វិសជ្ជនាដោយព្រះអង្គឯងថា អាមន្តា អើ ! ធម៌ទាំងឡាយដែលជាអកុសលនោះ ឈ្មោះថាជាមូលនៃអកុសល, ធម៌ដែលជាមូលនៃអកុសលនោះ ឈ្មោះថា អកុសល ។ ព្រះអង្គត្រាស់ដូច្នេះហើយ ទើប

ទ្រង់ត្រាស់បុច្ឆាតទៅទៀតថា កតមេ ធម្មា ធម៌ទាំងឡាយដែលជាមូលនៃអកុសលនោះ មានប៉ុន្មានប្រការ ? ទើបទ្រង់ត្រាស់វិសជ្ជនាថា ធម៌ទាំងឡាយដែលជាមូលនៃអកុសលនោះ មានបីប្រការ គឺ លោភោ ១, ទោសោ ១, មោហោ ១ ។ ធម៌បីប្រការនេះឯង ឈ្មោះថាជាមូលនៃអកុសល ។ អកុសលធម៌ទាំងឡាយនេះ ជាឫសជាគល់ជាមូលជាទីតាំងនៃអកុសល ។ អកុសលទាំងឡាយនឹងកើតឡើងបាន ក៏តែងអាស្រ័យនូវធម៌ទាំងបីប្រការនេះ បើគ្មានធម៌បីប្រការនេះជាទីតាំងទេ អកុសលទាំងឡាយក៏មិនអាចនឹងកើតឡើងឯង ៗ បានឡើយ រុក្ខោ វិយ មូលំ ប្រៀបដូចដើមឈើនឹងស្មៅវល្លិ៍ទាំងពួង បើគ្មានឫសជាទីតាំងទេ ក៏មិនអាចនឹងដុះលូតលាស់ឡើងបាន ។ ធម្មតារុក្ខជាតិទាំងឡាយ បើទុកជាដុះលូតលាស់ឡើងដោយសារគ្រាប់ នឹងធំខ្ពស់ជា ដើមដងហូតដល់មានមែកធាងចេញផ្កាមានផ្លែ បើមានតែកម្លាំងដើមមួយប៉ុណ្ណោះក៏ដុះឡើងមិនបាន ត្រូវតែមានឫសចាក់ចុះជ្រៅទៅក្នុងផ្ទៃដី ទើបអាចដុះជាដើមធំខ្ពស់ឡើងបាន យថា មានឧបមាដូចម្តេច ? អកុសលធម៌ទាំងឡាយនឹងកើតមានឡើងបានក៏តែងអាស្រ័យនូវមូលបីប្រការគឺលោភោ, ទោសោ នឹង មោហោ មានឧបមេយ្យដូច្នោះ ។ ហេតុនោះ ធម៌បីប្រការនេះ ទើបបានឈ្មោះថាមូលនៃអកុសល ព្រោះហេតុជាទីតាំងនៃអកុសល ដូចមានសេចក្តីអធិប្បាយអំពី លោភោ តទៅនេះ៖

# លោភអកុសលមូល

លព្ភតីតិ លោភោ លោភនោះរមែងញុំាងចិត្តឲ្យប្រាថ្នាឲ្យគង្វល់ រួបរឹតជាប់ស្អិតទៅក្នុងកិលេសកាមនិងវត្ថុកាម មានសេចក្តីប្រាថ្នាចង់បានទ្រព្យសម្បត្តិរបស់អ្នកដទៃមកធ្វើជារបស់ខ្លួនជាត្រីមុខ មក្កដាលេបោវិយ លោភមានឧបមាដូចស្វាជាប់ជ័រស្អិត ទំងរើបម្រះខ្លួនឲ្យរួចរបូតពីជ័រចេញដោយកម្រ ។ អបរិច្ចាគលក្ខណោ លោភមានការមិនបានលះបង់នូវទ្រព្យសម្បត្តិរបស់ខ្លួនជាលក្ខណៈ ។ លោភបើមានតែបន្តិចបន្តួច ក៏ល្មមនឹងហាមឃាត់កំចាត់បង់បាន បើមានច្រើនខ្លាំងក្លាឡើងហើយ មិនងាយនឹងកំចាត់ចេញឡើយ តែងទន់ទាញអ្នកមានលោភច្រើននោះ ឲ្យបានសោយទុក្ខវេទនាជាពន្លឹក ។ បើអ្នកណាមានចិត្តលោភខ្លាំងក្លាហួសប្រមាណហើយ អ្នកនោះនឹងបានសេចក្តីវិនាសក្នុងបច្ចុប្បន្ន គឺនឹងត្រូវរាជទណ្ឌអំពីសំណាក់នៃព្រះមហាក្សត្រ លុះទៅដល់អនាគតជាហេតុនឹងឲ្យកើតក្នុងចតុរាបាយមាននរកជាដើម ។

សម្តេចព្រះមានព្រះភាគទ្រង់ទេសនាថា យំ សហតេ ជរំ លោក បើចូលៈទៅគ្រប់សង្កត់បុគ្គលណា បុគ្គលនោះរមែងប្រព្រឹត្តនូវការដែលមិនគួរប្រព្រឹត្ត ។ មនុស្សលោភរមែងប្រកបដោយបិយវិប្បយោគទុក្ខ គឺទុក្ខ-ព្រោះការបែកបាក់ព្រាត់ប្រាសចាកញាតិមិត្រ ដែលជាទីស្រឡាញ់ពេញចិត្ត ព្រោះហេតុតែលោភខ្លាំងពេក ។ ឬក ឆងី ស្ទើងតាំងពួងមាន

វេលាស្រកស្រុតខ្វះខាតទឹក មានវេលាពេញពោរផុតខ្វះកន្ទះ ។ ឯលោកវិញគ្មានវេលាណាទឹងពោរពេញទេ មានតែខ្វះកន្ទះជានិច្ច ។ លោកចង់បានតែកាមនឹងកិលេសកាមផ្សេង ៗ កាលបានមកដូចចិត្តប្រាថ្នាហើយ ក៏នៅតែគិតចង់បានរបស់ដទៃប្លែក ៗ ទៅទៀត លុះបានរបស់នេះមកហើយ នៅតែនឹកចង់បានរបស់នោះទៀត មិនចេះអស់មិនចេះហើយ ។ បុគ្គលធ្វើអទិន្នាទាន ក៏ព្រោះតែកើតមានចិត្តលោភបណ្ដាលឲ្យគ្រោធខឹងនឹងញាតិមិត្រ ដូចមានរឿងក្នុងព្រះបាលី មានសេចក្ដីដំណាលថា ៖

ព្រះមហាក្សត្រមួយព្រះអង្គ មានព្រះរាជឱរសពីរព្រះអង្គហើយទ្រង់ទិវង្គតទៅ ។ បំណែកព្រះរាជកុមារជាព្រះជេដ្ឋា ត្រូវសោយរាជសម្បត្តិតពីព្រះវររាជបិតា ប៉ុន្តែព្រះអង្គប្រកែកពុំព្រមទទួលរាជសម្បត្តិនេះ ទ្រង់លើកប្រគល់ឲ្យព្រះរាជកនិដ្ឋាសោយរាជ្យតទៅ ហើយព្រះអង្គឯងយាងចេញពីព្រះរាជធានីទៅសំណាក់អាស្រ័យនៅក្នុងស្រុកមួយ ដែលតាំងនៅនាអាណាខេត្រនគរនេះ ។

តេ សញ្ញាណិត្វា មនុស្សទាំងឡាយក្នុងត្រកូលនោះ ដឹងថាព្រះរាជកុមារជាព្រះរាជឱរសនៃព្រះមហាក្សត្រ ហើយត្រូវជាព្រះជេដ្ឋានៃព្រះមហាក្សត្រដែលទើបសោយរាជ្យថ្មី ក៏នាំគ្នាទំនុកបំរុងថែរក្សាមិនឲ្យព្រះកុមារនោះធ្វើការងារអ្វីឡើយ ។

អបរភាគេ លុះចំណេរមកខាងក្រោយ មនុស្សទាំងឡាយទូលព្រះ

រាជកុមារថា មយំ ចោរសេម ខ្ញុំព្រះអង្គពល់គ្នាបានទំនុកបម្រុងថែរក្សាព្រះអង្គមកជាយូរខែឆ្នាំហើយ សូមព្រះអង្គជួយសង្គ្រោះដល់អស់យើងខ្ញុំខ្លះផង សូមផ្ញើព្រះរាជសាសន៍ទៅថ្វាយព្រះមហាក្សត្រជាព្រះកនិដ្ឋារបស់ព្រះអង្គ ឲ្យបន្ធូរបន្ថយលោះលាសួយ(១) ដល់យើងខ្ញុំខ្លះផង ។ ព្រះរាជកុមារក៏ផ្ញើព្រះរាជសាសន៍ទៅថ្វាយព្រះមហាក្សត្រ តាមពាក្យអ្នកស្រុកសុំ ។ ព្រះមហាក្សត្រទ្រង់យល់ព្រមព្រះរាជទានតាមព្រះរាជសាសន៍នោះឥតជំទាស់ ព្រោះសុំតែមនុស្សក្នុងត្រកូលមួយឬគ្រួសារមួយដែលព្រះរាជកុមារជេដ្ឋាទៅគង់នៅជាមួយនោះ ។

លុះចំណេរយូរមក ព្រះរាជជេដ្ឋាផ្ញើព្រះរាជសាសន៍ទៅសុំឲ្យបន្ថយសួយគ្រប់មនុស្សពេញមួយស្រុកនោះ ។ ព្រះមហាក្សត្រក៏ទ្រង់ព្រះរាជទានតាមសុំ មិនឲ្យទាស់អធ្យាស្រ័យ ។ ក្រោយមកទៀតសុំនាទីសេនាបតីជាធំ ព្រះរាជាក៏ព្រមព្រះរាជទានតាមសុំ ។ កន្លងមកមិនយូរប៉ុន្មានសុំទីជាឧបរាជ ព្រះរាជកនិដ្ឋាក៏ព្រះរាជទាន ។

ព្រះរាជជេដ្ឋានោះ សូម្បីបានទីជាឧបរាជហើយក៏មិនទាន់អស់លោភពិសន្ដាន នៅតែចង់បានជាធំ គឺសោយរាជសម្បត្តិទៀត ទើបលើករេហ៍ពលសកលយោធាទៅចោមព័ទ្ធនគរ ហើយផ្ញើលិខិតទៅថ្វាយព្រះមហាក្សត្រមានសេចក្ដីថា រជ្ជំ វា យុទ្ធំ វា ទេហិ ព្រះមហាក្សត្រ

១ ក្នុងសម័យបុរាណគេហៅប្រាក់បង់ពន្ធគ្រប់ចំពូក ឬ វត្ថុទាំងឡាយដែលត្រូវដាក់ឃ្លាំងហ្លួងថា សួយ ។

ដែលជាព្រះកនិដ្ឋាចូរឲ្យរាជសម្បត្តិដល់យើងឬ ឬមួយនឹងច្បាំងគ្នា ក៏តាមតែសព្វព្រះរាជហឫទ័យចុះ ។

ចំណែកព្រះមហាក្សត្របានជ្រាបសេចក្ដីលិខិតនោះហើយ ក៏ទ្រង់ទោមនស្សតូចព្រះរាជហឫទ័យថា "កាលពីដំបូង ព្រះជេដ្ឋាប្រកែកពុំព្រមទទួលរាជសម្បត្តិ លើកប្រគល់ឲ្យអាត្មាអញសោយរាជ្យស្នងព្រះវររាជបិតា ហើយដាច់ព្រះទ័យចេញទៅគង់នៅក្នុងជនបទ ផ្ញើព្រះរាជសាសន៍មកសុំរបស់អ្វី ៗ អាត្មាអញចេះតែឲ្យរបស់នោះ ៗ គ្រប់មុខតាមសុំ មិនដំណាស់ឲ្យខុសអធ្យាស្រ័យ លុះដល់មកគ្រានេះចង់បានរាជសម្បត្តិទៀត បើអាត្មាអញធ្វើសង្គ្រាមក៏បានដែរ ប៉ុន្តែ ជយោ មេ ករិស្សតិ បើអាត្មាអញច្បាំងឈ្នះមុខជាអ្នកប្រាជ្ញតិះដៀលអញ ឯព្រះជេដ្ឋាក៏ចងពៀរវេរានឹងកើតទោសមានកម្មពៀរនឹងគ្នាទៅកពខាងមុខទៀត បើអាត្មាអញច្បាំងចាញ់ហើយព្រះជេដ្ឋាក៏បានសោយរាជ្យ បណ្ដាពួកបរិស័ទរបស់អញនឹងវិនាសបាត់បង់ជីវិតអស់ជាច្រើន ឯការសង្គ្រាមតែងមានសេចក្ដីទុក្ខលំបាកដូចគ្នា ទាំងពីរខាង តែងស្លាប់ដូចគ្នា ទាំងពីរខាង នឹងកើតការទុច្ចរិតមានអបាយភូមិជាខាងមុខ; ណ្ហើយចុះ! កុំធ្វើឲ្យអ្នកប្រាជ្ញតិះដៀលអញផង កុំធ្វើឲ្យមានទោសមានពៀរទាំងបច្ចុប្បន្ននឹងអនាគតផង" ។ ព្រះមហាក្សត្រទ្រង់ព្រះតម្រិះដូច្នេះហើយ ទើបផ្ញើព្រះរាជសាសន៍តបទៅវិញថា " សូមអញ្ជើញព្រះជេដ្ឋាស្ដេចយាងចូលមកសោយសិរីរាជសម្បត្តិ តាម

ព្រះរាជហឫទ័យចុះ" ។

ចំណែកព្រះជេដ្ឋា ហេតុតែលុះទៅក្នុងអំណាចលោភចេតនាខ្លាំងពេក គ្មានសេចក្ដីអៀនខ្មាសសោះ ក៏បានសោយរាជសម្បត្តិតពីព្រះរាជ·កនិដ្ឋារៀងទៅ ។

ឯលោភនេះ បើមានខ្លាំងក្លាក្នុងចិត្តអ្នកណាហើយ ជាហេតុធ្វើចិត្តអ្នកនោះឲ្យកាត់កាល់ញាតិនិងមិត្រជាទីស្រឡាញ់ចោលចេញ គិតតែពីខាងមានខាងបានសម្បត្តិអ្នកដទៃមកជារបស់ខ្លួនម្យ៉ាងប៉ុណ្ណោះ ។ ហេតុនេះ អ្នកមានបញ្ញាគួរតែខំកំចាត់បង់លោភសង្កត់សង្កិនលោភកុំឲ្យកើតមានក្នុងចិត្តខ្លាំងពេក ។

ប្រការមួយទៀត អ្នកណាមានចិត្តលោភលន់ពន់ប្រមាណ អ្នកនោះភ្លេចគិតភយន្តរាយ ដែលនឹងកើតមានដល់ខ្លួន គិតឲ្យតែពីខាងបានប៉ុណ្ណោះ ដូចជាកូនប្រសាស្រីរបស់ដូនចាស់ជរាម្នាក់ សូមនាំយករឿងនេះមកសំដែងបញ្ជាក់ឲ្យយល់ច្បាស់អំពីទោសរបស់លោភដូចតទៅនេះ៖

(នៅមានត)

# មធុរសវាហិនី

## សម្តេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

ព្រះញាណកោសល ញាណ-ឈឹង ពិនិត្យ

( តមក )

---

### ចោរសហាយវត្ថុកថា

សំដែងរឿងនិទានបុរសជាសំឡាញ់នឹងចោរតទៅទៀត ដោយពរបាលីថា. អត្ថាគតំ ភគវតិ បរិនិព្វុតេ ដូច្នេះជាដើម ។

អធិប្បាយជាសេចក្តីថា: កាលព្រះមានព្រះភាគជាម្ចាស់នៃយើងទ្រង់ចូលព្រះបរមនិព្វានទៅហើយ ។ កាលនោះ ក្នុងជម្ពូទ្វីបនេះ មានមនុស្សកំសត់ម្នាក់នៅក្នុងទេវទហនគរ បានគ្រាច់ទៅកាន់ស្រុកជនបទមួយ ហើយបាននៅសំណាក់អាស្រ័យក្នុងផ្ទះត្រកូលជាសំឡាញ់នាស្រុកជនបទនោះឯង ។

ឯមនុស្សទាំងឡាយដទៃក៏បានឲ្យបាយទឹកបរិភោគ ចិញ្ចឹមរក្សាទុកក្នុងជនបទនោះ ។ ពីនោះមក បុរសបានធ្វើមិត្តសន្ថវស្និទ្ធស្នាលជាមួយនឹងមនុស្សទាំងឡាយនៅក្នុងស្រុកនោះ យ៉ាងក្រៃលែង ប៉ុន្តែគាត់ពុំដែលទៅកាន់ទីកន្លែងដទៃឡើយ ។ លុះនៅបានប្រមាណជាពីរបីថ្ងៃខាងក្រោយមកបុរសនោះក៏ប្រព្រឹត្តធ្វើនូវចោរកម្មលួច ឆក់ទ្រព្យគេមកសម្រេចកិច្ចចិញ្ចឹមជីវិតខ្លួនក្នុងទីនោះ ។

ខាងក្រោយមកទៀត រាជបុរសទាំងឡាយចាប់បុរសអ្នកលួចនោះនាំយកទៅថ្វាយព្រះមហាក្សត្រិយ៍ ព្រះអង្គក៏ត្រាស់បង្គាប់ពេជ្ឈឃាដថា អ្នកទាំងឡាយត្រូវចងបុរសនេះឲ្យមាំ ហើយនាំយកទៅដាក់ក្នុងគុកទៅ ។

ឯពេជ្ឈឃាដទាំងឡាយ ក៏បានទទួលព្រះរាជឧង្ការ ហើយចងបុរសនោះនាំយកទៅឯផ្ទះគុកដាក់ច្រវាក់ទុកក្នុងទីនោះ ហើយចាត់គ្នីគ្នាឲ្យនៅចាំរក្សាដ៏មាំមួន ទើបត្រឡប់មកកាន់ផ្ទះខ្លួនទីទៃវិញហោង ។

កាលបើបុរសអ្នកលួចនោះបាននៅក្នុងផ្ទះគុក កន្លងទៅអស់រយៈវេលា ១២ ឆ្នាំហើយ ក្រោយពីនោះមកមានមនុស្សម្នាក់ទៀតនៅក្នុងបច្ចន្តគ្រាមធ្លាប់ជាមិត្រសំឡាញ់នៃបុរសដែលជាប់គុកនោះឯង បានធ្វើដំណើរមកកាន់ទេវទហានគរដោយកិច្ចអ្វីមួយ, ក៏បានដើរទៅជិតផ្ទះគុកនោះ ហើយបានឃើញបុរសជាសំឡាញ់ក៏ត្រូវជាប់ទោសដូច្នោះ មានចិត្តអាណិតអាសូរញាប់ញ័រយ៉ាងខ្លាំង ទើបស្រែហៅបម្រះនឹងនៀលសួរថា: ម្នាលសំឡាញ់មានធុរៈស្អី! តើអ្នកមានអំពើកំហុសដូចម្ដេចបានជាគេយកអ្នកមកដាក់គុកដូច្នេះ ?

ឯចោរនោះ លុះបានស្ដាប់ពាក្យសួរហើយ ក៏និយាយប្រាប់ដំណើរនោះថា: អើ! សំឡាញ់អើយ ខ្លួនខ្ញុំបានមកជាប់នៅក្នុងផ្ទះគុកសោយទុក្ខវេទនាកន្លងទៅយ៉ាងនេះអស់រយៈវេលា ១៦ ឆ្នាំហើយ សំឡាញ់អើយ; កាលយូរលង់ប៉ុណ្ណោះ ខ្ញុំនៅតែសេចក្ដីទុក្ខលំបាកយ៉ាងធំ ពុំដែលបាន

បរិភោគភោជនឆ្អែតដល់ម្តង ការដែលបានបរិភោគម្តងៗ នោះ ក៏ពុំដែលបានភោជនល្អឆ្ងាញ់ពិសាឡើយ បានតែភោជនអាក្រក់ស្មោកគ្រោកជានិច្ច, ប្រសិនបើខ្ញុំបានដើរចេញទៅស្វែងរកអាហារបរិភោគឲ្យបានឆ្អែតហើយត្រឡប់មកវិញដកបណា សូមសំឡាញ់មេត្តាជួយរកឧបាយដោះខ្ញុំឲ្យបានរួចអំពីគុកនេះ ចេញទៅរកអាហារបរិភោគដកបនោះឯងៗ

ឯអ្នកបច្ចុន្តគ្រាមជាសប្បុរសនោះ លុះបានស្តាប់ពាក្យសំឡាញ់អង្វរករដូច្នោះហើយក៏ពោលជាបទព្រះគាថាដូច្នេះថា:

រូបេន កិន្នុ គុណសីលវិវជ្ជិតេន
មិត្តាលយស្ស កិ តវស្ស សិយា កិមត្ថំ
ធនាធិបាតវិកតេន ច ធេន កិ វា
មិត្តេន កិ ព្យសនកាលបរាម្មុខេន ។

អធិប្បាយថា : ប្រយោជន៍អ្វីដោយរូបខ្ញុំនឹងរូបអ្នកដែលប្រាសចាកគុណធម៌នឹងសីលធម៌ (នេះ) ប្រយោជន៍អ្វីដល់អ្នកដែលនៅអាស្រ័យក្នុងគុក (នេះ) ប្រយោជន៍អ្វីដោយទ្រព្យសម្បត្តិដែលមិនបានបរិច្ចាគធ្វើបុណ្យមានឲ្យទានជាដើម(នេះ) ប្រយោជន៍អ្វីដោយកាលដែលដល់នូវសេចក្តីវិនាសក្នុងខាងមុខព្រោះប្រាសចាកមិត្ត (នេះ)! លុះបច្ចុន្តគ្រាមបុរសជាសំឡាញ់បានពោលគាថាយ៉ាងនេះហើយ ក៏និយាយផ្ទួនទៅនឹងសំឡាញ់អ្នកដេ

គ្រោះថា : អ្នកនឹងគ្រោះជាសំឡាញ់អើយ ! ការនេះប្រពៃហើយ ខ្ញុំនឹងធ្វើតាមពាក្យរបស់អ្នកពិត ៗ លុះថាហើយក៏ដើរចូលទៅកាន់សំណាក់នៃអមាត្យអ្នករក្សាហើយនិយាយអង្វរករសូមទោសថា: បពិត្រលោកទាំងឡាយដ៏ចំរើនអើយ! ប្រសិនបើបុរសដែលជាប់ទោសនោះ បានដើរទៅស្វែងរកបាយបរិភោគឆ្អែតបរិបូណ៌ហើយ វិលត្រឡប់មកវិញដរាបណា ខ្លួនខ្ញុំសូមធ្វើជាអ្នកធានាបុរសនោះក្នុងទីនេះដរាបនោះ សូមលោកនាយទាំងឡាយលែងបុរសនោះឲ្យចេញទៅស្វែងរកអាហារបរិភោគចុះ ៗ

ចំណែកឯអមាត្យអ្នកឆ្មាំទាំងឡាយក៏ពោលតបវិញថា: ម្នាលបុរសដ៏ចំរើន ! យើងទាំងឡាយមិនអាចនឹងហ៊ានលែងបុរសនេះឡើយ ក្នុងពេលបុរសនោះចេញទៅមិនទាន់វិលត្រឡប់មកវិញដរាបណា បើអ្នកសុខចិត្តឲ្យយើងដាក់ច្រវាក់អ្នកដរាបនោះ ទើបយើងអាចហ៊ានលែងបុរសនេះបាន បើអ្នកមិនឲ្យយើងដាក់ច្រវាក់អ្នកទេ យើងពុំអាចហ៊ានលែងបុរសនេះបានឡើយ ៗ សំឡាញ់ជាសប្បុរសនោះបានស្តាប់ហើយក៏ទទួលព្រមហើយឲ្យដោះច្រវាក់អំពីជើងនៃបុរសអ្នកទោសជាសំឡាញ់នោះ យកមកដាក់ជើងរបស់ខ្លួនវិញ រួចហើយក៏ចូលទៅនៅក្នុងគុកជាជំនួសបុរសជាសំឡាញ់នោះទៅ ៗ

ចំណែកឯជនជាអសប្បុរសនោះ លុះបានរួចអំពីចំណងគឺច្រវាក់ហើយ ក៏ដើរចេញទៅស្វែងរកអាហារ កាលបើបានអាហារបរិភោគ

ផ្អែតហើយ កំពុំបានត្រឡប់មកកាន់ទីផ្ទះគុកនោះវិញឡើយ គឺដើរចេញទៅកាន់ទីដទៃទៅ ។

អហោ ខយើងទាំងឡាយអើយ ! គួរខ្លាចគួរដឹងនូវអំពើរបស់បុគ្គលជាឥតតញ្ញូដំអាក្រក់ពន់ពេកណាស់, ព្រោះហេតុដូច្នោះ បានជាព្រះគន្ធរចនាចារ្យលោកពោលជាបទព្រះគាថាដូចនេះថា :

ភរិយ្យកេ យថា សោព្ភោ ឆេវច្ឆោ វិសមំ សមំ
បញ្ញាយតេ អសាធុស្ស ឃរំ មនសំ សម្ភរំ ។

អធិប្បាយថា: បឹងធំមានទឹកពេញពោរពាស តែថាទីដីខាងក្នុងបឹងរាបស្មើក្តី ពុំរាបស្មើក្តី នោះពុំប្រាកដឡើយ មានឧបមាយ៉ាងណា អំពើគោងកាចកើតឡើងក្នុងចិត្តនៃបុគ្គលជាអសប្បុរស គេពុំបានឃើញច្បាស់ មានឧបមេយ្យយ៉ាងនោះឯង ។

ភាសន្តិ មុខតោ ឯកំ ចិន្តេន្តិ មនសា បរំ
កាយេនេកំ ការេន្តិ ឯតាយំ អសាធុនំ ។

អសប្បុរសទាំងឡាយតែងពោលពាក្យដោយមាត់មួយយ៉ាង គិតដោយគំនិតដទៃមួយយ៉ាង ធ្វើកម្មដោយកាយមួយយ៉ាង នេះជាធម្មតារបស់បុគ្គលជាអសប្បុរសទាំងឡាយដោយពិត ។

តេសំ យោ ភាវំ វិជញ្ញា សោវ បណ្ឌិតជាតិកោ
ពហុស្សុតោបិ សោយេវ បរចិត្តវិទូបិ សោ ។

មួយទៀតបុគ្គលណាបានដឹងច្បាស់នូវសេចក្ដីប្រព្រឹត្តវៀចវេ នឹងការស្មោះត្រង់នៃជនជាអសប្បុរសទាំងនោះ បុគ្គលនោះឯងបានឈ្មោះថាជាអ្នកប្រាជ្ញ ទាំងបានឈ្មោះថាជាពហុស្សូតដោយពិត, ព្រោះបុគ្គលនោះបានដឹងបានស្គាល់នូវចិត្តនៃបុគ្គលដទៃនោះឯង ។

ក្រោយពីនោះមក ជនជាសប្បុរសដែលបានទទួលទោសជំនួសសំឡាញ់នោះក៏បាននៅក្នុងផ្ទះគុកប្រមាណ ១២ ឆ្នាំ ហើយតែងមានសេចក្ដីស្រេកឃ្លានបៀតបៀនជានិច្ច ពុំដែលបានដើរចេញទៅស្វែងរកអាហារបរិភោគឲ្យឆ្អែតដល់ម្ដងឡើយ, គឺពប់ថ្ងៃដែលបានបរិភោគនោះតិចពន់ពេក ឯថ្ងៃដែលមិនបានបរិភោគនោះច្រើនក្រៃលែង ម្ល៉ោះហើយមានរូបកាយស្គមថមថយកម្លាំង នៅតែស្បែកនិងឆ្អឹង សោយទុក្ខលំបាកឥតទីពឹងឡើយ ។

លុះគន្លងទៅបាន ១២ ឆ្នាំ, កាលនោះព្រះរាជបុត្រារបស់ព្រះបរមក្សត្រិយ៍ក៏បានប្រសូតចេញចាកផ្ទៃព្រះមាតាមកដោយសិរីសួស្ដីជ័យប្រសើរ ។ ចំណែកឯព្រះបរមក្សត្រិយ៍ ព្រះអង្គបានទតឃើញព្រះភក្ត្រព្រះរាជបុត្រហើយ ក៏មានព្រះរាជហឫទ័យសោមនស្សជ្រះថ្លា ត្រាស់បង្គាប់ឲ្យសេវកាមាត្យទាំងឡាយដោះលែងអ្នកទោសទាំងអស់ចេញ អំពីផ្ទះគុកក្នុងកាលនោះឯង ។

(នៅមានត)

# លោក អ៊ុម-ភគ បម្លងពីសាស្ត្រាស្លឹករឹត

*ព្រះពុទ្ធវង្ស គីម-តួរ ពិនិត្យ*

( តមក )

---

ពោធិសត្តោ តំ វីមំសនត្ថាយ តំ នាគរិកស្ស គេហេ ឋបេត្វា នាគរិកភរិយាយ អាចិក្ខិត្វា អត្តនោ ឯវ·សនិំ គន្ត្វា បុរិសេ អាមន្តេត្វា ។ បេ ។ បពិត្រអើយ! ឮដ៏កាលនោះកូវ , ពោធិសត្វនឹងចង់ល្បងលនាងអមរា ទើបមានព្រះបន្ទូលថា ភទ្ទេ ម្នាលនាងដ៏ជាភរិយាទេវីស្រីសំឡាញ់ស្ងួនបងអើយ! នាងអើយ! ឥឡូវនេះបងនឹងផ្ញើទុកនាងនៅនាផ្ទះនាយទ្វារនេះសិនហោង បងនឹងចូលទៅមុន ម្យ៉ាងហើយ រំពៅមហោសថអ្នកប្រាជ្ញ អាចលីលាយាត្រា ទៅដល់ផ្ទះអាត្មា ហើយស្រដីទៅនឹងបុរសម្នាក់ថា ហៃបុរសអើយ! អញបាននាំយកនូវស្រីម្នាក់មកផ្ញើទុកនាទ្វារផ្ទះអ្នកចាំទ្វារនោះ, ចូរព្រះស្ដង់យកនូវមាសមួយពាន់ដំឡឹង ទៅឲ្យស្រីនោះលងមើល, បុរសនោះទៅធ្វើដោយនូវពាក្យបង្គាប់ពោធិសត្វ ហើយថា អម្ម ហៃនាងអមរាអើយ! ចូរនាងទៅនៅនឹងអញ ។ ឲ្យមាសមួយពាន់ដំឡឹង ។ នាងអមរា នាងមិនប្រាថ្នាស្រឡាញ់ចង់បានមាសនោះឡើយ នាងថា មាសមួយពាន់ដំឡឹង មិនស្មើល្អងធូលីជើងប្ដីខ្ញុំនេះ

ឡើយ ៗ បុរសនោះត្រឡប់មកសំដែងប្រាប់ចៅមហាសេដ្ឋកក្រាដ, ចៅមហាសេដ្ឋកក្រាដអាចប្រើ បុរសដទៃទៅទៀត ជាគំរប់បី-បួន ដងក្តី រីនាងអមរា នឹងបានមានចិត្តប្រាថ្នាដល់តិចតួចនោះឥតអង្គីមាន ឡើយ ៗ បុរសនោះវិលមកប្រាប់ពោធិសត្វ ព្រះអង្គប្រើឲ្យបុរស នោះទៅចាប់ដៃនាងអមរានាំចូលមកឰដ៏ឋាននេះ នាងមកដល់យល់ ពោធិសត្វឋិតនឹងឥស្សរសម្បត្តិមានសិរីសួស្តី នាងក៏ពុំស្គាល់ជាពោធិសត្វ ឡើយ ស្មានជាព្រះមហាក្សត្រ នាងសើចហើយយំវិញ ៗ រីពោធិ-សត្វព្រះអង្គជ្រាបនូវប្រការទាំងពីរដំពូកនោះហើយ មានបន្ទូលដណ្តឹងថា ហៃនាងអើយ! អម្បាញ់មិញនាងសើចឥឡូវនេះនាងយំវិញ តើហេតុដំណើរដូចម្តេច? ចូរនាងប្រាប់មកឲ្យបានដឹង ៗ ទើបនាងអមរា ឆ្លើយថា បពិត្រអម្ចាស់អើយ! ខ្ញុំមិលមើលឥស្សរសម្បត្តិអម្ចាស់ច្រើន ហេតុអំពើកុសលផលបុណ្យអំពីមុននាយអម្ចាស់បានសាងមក ទើបបាន សម្បត្តិទាំងនេះ ហេតុនោះបានជាខ្ញុំសើចអរនឹងផលអម្ចាស់បានសាង អំពីមុនច្រើនេកហើយ, ឥឡូវនេះ ខ្ញុំយំវិញ ហេតុអម្ចាស់រកទងណ្តើម កូនអ្នកដទៃគេក្នុងព្រាបាល ហើយអម្ចាស់នឹងទៅសោយទុក្ខវេទនានៅ ឯនរកនាយ ហេតុនោះខ្ញុំយំវិញហោង ៗ

សោ តំ វីមំសិត្វា តស្សា បរិសុទ្ធភាវំ ញត្វា....

រីពោធិសត្វលងនាងអមរា ដឹងសុភាពបរិសុទ្ធហើយ ក៏ពោធិសត្វប្រើ

បុរសនោះថា ម្នាលព្រះស្តែនអើយ ! ចូរអ្នកនាំនាងនេះទៅទុកនាឋាន ដែលវិញ ទើបបុរសនោះធ្វើតាមបង្គាប់ពោធិសត្វ, រីពោធិសត្វអ្នកយក គៀសអាត្មាជាអ្នកប៉ាក់ផុលវិញទៀត ទៅដេកសំកន្ទជាមួយនឹងនាងនោះ ហោង, លុះព្រឹកឡើង ពោធិសត្វចូលទៅកាន់ត្រកូលស្តេចនាព្រឹកនោះឯង , ពោធិសត្វសំដែងប្រាប់នាង ។ ទុម្ពរទេវីជាអគ្គមហេសី ទេពីនៃព្រះបាទវិទេហកជ ។ នាងទូលស្តេចជ្រាបហើយ ឲ្យប្រដាប់គ្រឿងតាំងពួងប្រយោជន៍នឹងឲ្យទទួលពោធិសត្វ នូវនាងអមក ឲ្យឡើងជិះលើរទេះដ៏ប្រសើរ នាំមកផ្ទះព្រះមហោសថអ្នកប្រាជ្ញ នឹងបរិវារនោះច្រើន ឲ្យវណ្ណាប់ជាមង្គលប្រសើរហោង ។

តទា ពោធិសត្តស្ស សហស្សមូលំ បណ្ណាការំ បេសេសិ ។ ទោវារិកេ អាទឹ កត្វា សកលនគរវាសិនោ បណ្ណាការេ សជ្ជយឹសុ ។ ក្នុងកាលនោះ, ស្តេចឲ្យជូននូវគ្រឿងបណ្ណាការដល់ពោធិសត្វជាដើម គឺមាសមួយពាន់ដំឡឹង, អ្នកចាំទ្វារក្តី អស់អ្នកនគរនោះក្តីក្តី ស្តេចនឹងជូននូវគ្រឿងបណ្ណាការផងមកពោធិសត្វ នូវនាងអមរហោត នាងក៏ទទួលយកគ្រឿងបណ្ណា-ការដែលស្តេចឲ្យជូននោះ, នាងក៏បង្វែបែងជាភាគពីរ, ភាគមួយឲ្យនាំទៅថ្វាយបញ្ចូលឃ្លាំងស្តេចវិញហោង, ភាគមួយនោះ នាងឲ្យជូនគ្រឿងបណ្ណាការផងទៅអស់អ្នកនគរទាំងឡាយ សឹងចងជាមិត្តយកចិត្ត

ជាមេត្រី ៗ ចាប់ដើមអំពីកាលសម័យថ្ងៃនោះទៅ ព្រះបរមពោធិសត្វ ក៏នៅរួមសមគ្គសំវាសជាមួយនាងអមរាទេវីនោះ ដោយការព្រមព្រៀងគ្នា រញ្ញោ អត្ថញ្ញូ ធម្មញ្ញូ អនុសាសិ ហើយព្រះអង្គទ្រង់ណែនាំ ប្រៀនប្រដៅនូវអាថ៌ធម៌ដល់ព្រះមហាក្សត្រតរៀងទៅ ៗ

អមរាទេវី បរិយេសនំ ចិណ្ណំ រឿងស្រដីសរសើរដំណើរ ដំណាលអំពីចំណោះប្រាជ្ញាពោធិសត្វកាលស្វែងរកនាងអមរាទេវី នាំយក មកជាភរិយានោះវិញ ក៏ស្រេចដោយនូវប្រការអម្បាលនេះហោង ៗ

អថេកាទិវសំ សេនកោ ឥតរេ តយោ អត្ត-នោ សន្តិកំ អាគតេ ទិស្វា តេ អាមន្តេត្វា អម្ភោ មយំ គហបតិបុត្តស្ស មហោសធស្ស នប្បហោម លំដាប់នោះ, មានកាលសម័យថ្ងៃមួយ, រីអាចារ្យទាំងបីមកអំពីលំនៅ អាត្មា យល់ហើយស្រដីនឹងអាចារ្យសេនកថា ហៃអាចារ្យសេនកអើយ ! រីយើង ឥតអំណាចស្មើនឹងចៅមហោសថកូនគហបតីសិរីវឌ្ឍកសេដ្ឋីនោះ ឡើយ, ឥឡូវនេះ ចៅមហោសថនាំប្រពន្ធអំពីណាមក មានប្រាជ្ញា ឈ្លាសវៃក្រពេកដោយខ្លួនឯង, រីអ្នកទាំងបីថាបើដូច្នោះហើយ តើយើង នឹងរកឧបាយកលធ្វើចៅមហោសថកណ្តាលជំនុំស្តេចនូវប្រការដូចម្តេច? ៗ អាចារ្យសេនកថា បើអ្នកពុំដឹង ម្នាលអ្នកទាំងឡាយអើយ ! កុំបីអ្នកបារម្ភ ឡើយ, អញមានឧបាយកលមួយ ៗ អាចារ្យទាំងបីថា ហៃអាចារ្យ

អើយ ! គលឧបាយនោះតើដូចម្ដេច ? ៗ រីអាចារ្យសេនកស្រដីថា អញទៅលួចយកនូវចុឡាមណីរ័ត៌នស្ដេច ហើយអញឲ្យនាំទៅទុកនៅផ្ទះអញ; អាចារ្យបុក្កុស ; ចូរព្រះស្ដែងទៅលួចទូសុវណ្ណមាលាមាស នាំមកទុកនៅផ្ទះ, អាចារ្យកាមិន្ទ ចូរព្រះស្ដែងទៅលួចសំពត់ត្រកម្ពល: អាចារ្យទេវិន្ទ ចូរព្រះស្ដែងទៅលួចសុពណ៌បាទុកមាស នាំមកទុកនៅផ្ទះយើងទីទៃ ៗ ហើយៈយើងកុំឲ្យអ្នកឯណាដឹងឡើយ , ហើយយើងធ្វើឧបាយកលមួយទៀត គឺយើងរកខ្ញុំស្រីមួយម្នាក់ ១ ៗ ម្នាក់ ១ ឲ្យទុកដាក់នូវទ្រព្យឲ្យកំបាំង ហើយឲ្យទៅលក់ឯផ្ទះមហោសថកូនគហបតីសេដ្ឋីនោះហោង ៗ រីអាចារ្យទាំងបីទទួលយកពាក្យអាចារ្យសេនកហើយ ធ្វើដោយបង្គាប់នោះស្រេច , រីឯអាចារ្យសេនកយកចុឡាមណីរ័ត៌នមកទុកក្នុងទឹកក្អមមួយ បន្ទែឲ្យដៃស្រីមួយឲ្យយកទៅទុកលក់ ហើយផ្ដាំថា បើអ្នកដទៃឯណាមួយគេនឹងទិញយក មេកុំបីលក់ឲ្យឡើយ បើមានមនុស្សអំពីមហោសថក្ដី ឬក៏មកដល់ផ្ទះប្រពន្ធមហោសថឯងក្ដី ឲ្យមេលក់ឲ្យទៅហោង ៗ រីមេស្រីនោះ ទទួលយកពាក្យអាចារ្យសេនកស្រេចហើយ យកទឹកក្អមទៅដល់ផ្ទះមហោសថអ្នកប្រាជ្ញ ហើយស្រដីថា ហៃអ្នកផ្ទះអម្ចាស់ខ្ញុំអើយ ! ចូរអ្នកទិញទឹកក្អមទុកពិសា ហើយរ៉ដើរចូលទៅនាទ្វារផ្ទះហៅមហោសថហោង ៗ អមរទេវី ទ្វារេ ឋិត្វា តស្សា គារិយំ ទិស្វា . . . រីនាងអមរាទេវី, កាលៈនោះនាង

បិតនៅនាទ្វារផ្ទះអាត្មា នាងយល់នូវអំពើស្រីមួយនោះពុំដើរទៅទីឯទៀតឡើយ, នាងរំពឹងគិតថា រីអាថ៌ប្រស្នានេះ សូម្បីមានឯងមិនទៅឡើយ នាងប្រើខ្ញុំស្រីទាំងឡាយឲ្យទៅប្រាប់ ឲ្យមេស្រីនោះថយចេញទៅលក់ទីឯទៀត, រីស្រីនោះក៏មិនទៅទីឯទៀតឡើយ ; ឯនាងអមរានាងយល់មេស្រីនោះពុំដើរទៅទីឯទៀតហើយ, នាងឲ្យហៅមកកាន់ផ្ទះនាងហើយនាងដណ្តឹងថា ហៃក្មេងក្រមុំព្រហ្មចារីសំដីពីរោះអើយ ! មេតើឈ្មោះអ្វី ? ៗ រីមេនោះប្រាប់ថា អម្ចាស់ខ្ញុំឈ្មោះមេតាសី ខ្ញុំស្រីអ្នកអាចារ្យសេនកប្រើខ្ញុំមកលក់ក្អមទឹកនោះហោង ។ នាងអមរាដណ្តឹងឈ្មោះម្តាយអាពុកមេនោះ ៗ ប្រាប់ថា ម្តាយខ្ញុំឈ្មោះ (មារ) អាពុកខ្ញុំឈ្មោះ (នពអន្ទល់) ដោយខ្ញុំសំគាល់យសគាត់ខ្ពស់ធំប្រដាង ពោះធំកំប៉ោង ហើយក្បាលទំពែកផង នោះហោងអាពុកខ្ញុំ ៗ រីនាងអមរាធ្វើសំបុត្រសន្ទកកត់ជាចំណាំ ថ្ងៃព្រហស្បតិ៍ពេញបូណ៌មីខែពិសាខ អាចារ្យសេនកប្រើខ្ញុំមកជូនគ្រឿងប្រដាប់ដល់មកផ្ទះចៅមហោសថនោះហោង, នាងយកហើយនាងឲ្យដំណើរមេនោះទៅផ្ទះអាចារ្យសេនកវិញហោង ៗ បុក្កុសោបិ សុវណ្ណមាលំ សុមនបុប្ផចង្កោដកេ ឋបេត្វា តំ បុប្ផេហិ ឆាទេត្វា បេសេសិ ។ កាមិន្ទោបិ កម្ពលំ បណ្ណបច្ឆិយំ ឋបេត្វា បណ្ណេហិ ឆាទេត្វា បេសេសិ ។ ទេវិន្ទោ សុវណ្ណបាទុកំ យវកលាបន្តរេ ពន្ធិត្វា

បេសសិ ។ រីអាចារ្យបុក្កុសយកសុវណ្ណមាលាមាសទុកក្នុងប្រអប់ដាក់ផ្កាភ្ញីប្រើជូនមកផ្ទះចៅមហោសថ ។ អាចារ្យកាមិន្ទយកសំពត់វត្តកម្ពលទុកក្នុងកញ្ជើហើយយកបន្ទាស្រស់ដាក់លើ ប្រើជូនមកផ្ទះចៅមហោសថអ្នកប្រាជ្ញ ។ អាចារ្យទេវិន្ទ យកសុពណ៌បាទុកមាសចង់ទុកក្នុងស្បូវគណ្ដាប់ ហើយប្រើជូនមកដល់ផ្ទះចៅមហោសថអ្នកប្រាជ្ញ ។ រីនាងអមរាទទួលយកគ្រឿងប្រដាប់បណ្ណាការទាំងនោះហើយនាងស្រាយវែងប្រាប់ឈ្មោះអាត្មា ខ្ញុំស្រីទាំងអម្បាលនោះ សរសេរត្រាឈ្មោះទុកក្នុងសំបុត្រដូចយើងសំដែងហើយបង្ហាញពោធិសត្វ គឺព្រះមហោសថអ្នកប្រាជ្ញអាចយកទុកទៅហោង ។

តេបិ ចត្តារោ បណ្ឌិតា រាជកុលំ គន្ត្វា តឹ ទេវឹ ចុឡុមណឹ ច បិលន្ធជាតិ អាហាំសុ ។ រាជា បិលន្ធិស្សាម អាហរថាតិ អាហ ។ តេ គន្ត្វា តត្ថ ចុឡុមណឹ អទិស្វា ឥតរានិ តានិបិ ច បស្សឹសុ យេវ ។ អថ តេ ចត្តារោបិ ទេវិ តុម្ហាកំ អាភ-រណានិ មហោសថស្ស គេហេ វសន្តិ សោ តាវ សយំ វលញ្ជេតិ បដិសត្ថុ តេ មហារាជ គហាបតិ-បុត្តោតិ តំ បរិភុញ្ជឹសុ ។ រីអាចារ្យទាំង ៤ ឡើងទៅគាល់ស្ដេចវិទេហរាជ ហើយធ្វើជាទូលថា ទេវ បពិត្រអម្ចាស់ខ្ញុំអើយ ! សព្វថ្ងៃ

រៀងមក ព្រះអង្គទ្រង់នូវគ្រឿងប្រដាប់ចុឡាមណីរ័ត្ន នូវមកុដអាភម អន្ទាមព្រះស្ទូងមណីរ័ត្ន, ឥឡូវនេះ បទអ៊ុំក៏ស្តេចពុំទ្រង់ឡើយ ៗ តំ សុត្វា រាជា អាហា ស្តេចស្តាប់អាចារ្យទាំង ៤ ទូលនូវប្រការអម្បាលនោះហើយ, ស្តេចប្រើបំរើទៅយកអស់គ្រឿងប្រដាប់ចុឡាមណី-រ័ត្នមកស្តេចនឹងទ្រង់, អាមាត្យទៅរកចុឡាមណីរ័ត្នពុំយល់នូវគ្រឿងប្រដាប់ទាំង ៤ ប្រការនោះឡើយ ក៏ត្រឡប់មកទូលស្តេច ស្តេចក្រោធពិរោធក្រៃពេក ៗ អាចារ្យទាំង ៤ ទូលថាដូច្នេះទេវ បពិត្រអម្ចាស់អើយ! វិធ្មមអម្ពរគ្រឿងប្រដាប់នោះ ដូចទៅនៅនាផ្ទះ·ចាំមហោសថនាយនោះហើយមិនទេ ឡើយ, ចូរអម្ចាស់ឲ្យទៅសួរពិតមានប្រការយ៉ាងណា នូវមហោសថនោះឃើញហោង, បពិត្រមហារាជអើយ! ព្រះមហោសថកូនគហបតីនោះ សិងជាមិត្តទ្រុស្តអម្ចាស់; ចូរអម្ចាស់ឲ្យចាមចាប់ចៅមហោសថនោះ ធ្វើទុក្ខធ្វើទោសដោយនូវព្រះរាជទណ្ឌនោះហោង ៗ

លំដាប់នោះ, វិអស់មនុស្សម្នាមហាជនផង ឮពាក្យអាចារ្យទាំង ៤ នាក់ចូលទូលស្តេចដូច្នោះហើយ សឹងនាំគ្នាទៅសំដែងប្រាប់ព្រះមហោ-សថ ៗ ឯព្រះមហោសថសោតរំពឹងគិតថា អញនឹងទៅឲ្យស្តេចយល់ស្តេចខ្ញាល់នឹងអញ បើដូច្នោះ អញមិនឲ្យយល់ខ្លួនអញឡើយគួរអញនឹងរត់ចៀសចេញកុំឲ្យស្តេចឃើញអញហោង, ម្ល៉ោះហើយចៅមហោ-សថឲ្យប្រាប់នាងអមរា ដ៏ជាភរិយាឲ្យជាដំណឹង ហើយយកសំពត់

ចាស់ដំជាមន្ទិលស្លៀកកៀសពុំឲ្យគេស្គាល់អាត្មា ហើយចេញទៅអំពីនគរ បវរកជបានពិមានៈស្តួចវិទេហរាជដ៏ជាធំប្រសើរហោង , ហើយដើរចេញទៅដោយនាទិសទក្ខិណាយវមជ្បកគ្រាម ហើយក្លែងខ្លួនធ្វើជាអ្នកសូនផ្ទាំង , រីអ្នកនគរទាំងឡាយ បានឮថា ចៅមហោសថអ្នកប្រាជ្ញរត់ចៀសចេញ ហើយជាកោលាហលវើលវល់មួយអន្ទើទៅវិញទៅមកក្រៃពេកហោង ។ ក្នុងកាលនោះ , រីអាចារ្យទាំង ៤ នាក់ មានអាចារ្យសេនកជាដើម ដឹងសុភាពជាចៅមហោសថរត់បាត់ហើយ ក៏ក្រាកដោះឡើងទះទ្រូងទះស្មាអរឯងស្រដីថា ម្នាលអ្នកទាំងឡាយអើយ ! ឥតនឹងចៅមហោសថហើយ យើងកុំគិតបារម្ភឡើយ , ម្ល៉ោះហើយយើងមិនឲ្យអ្នកទាំងឡាយទៃ ៗ ដឹងឡើយ ហើយយើងឲ្យជូនទូវគ្រឿងបណ្ណាការឲ្យនាងអមរា ហើយយើងនឹងយកជាភរិយាសង្ក្រយើងហោង ។ អាចារ្យទាំង ៤ សឹងធ្វើដោយគំនិតនោះហើយ , នាងអមរាទទួលយកគ្រឿងបណ្ណាការដែលអាចារ្យទាំង ៤ ឲ្យជូនមកនោះ ហើយនាងផ្តាំថា ឲ្យអាចារ្យសេនក មកពីល្ងាចព្រះអាទិត្យអស្តង្គតលិចបាត់ស្មើងងឹតវេលាថ្ងៃនេះ ឲ្យគាត់មកកាន់អញហោង នាងឲ្យដំណើរទៅហើយ ហៅអស់ខ្ញុំស្រីទាំងឡាយឲ្យជីករណ្តៅមួយ ហើយឲ្យចាក់បំពេញទូវលាមកស្មើនឹងទឹក , ឯមាត់រណ្តៅបង្គន់នោះគ្របទូវក្តារយន្តហើយក្រាលកន្ទេលគ្របពីលើ ហើយឲ្យរណ្តាប់ទឹកអប់ត្រឡប់ទូវគន្ធពិដោរស្រេចហើយ ,

តស្មឹ បទោសកាលេ សេនកោ អត្តានំ អលង្ក្រិត្វា នានគ្គរសភោជនំ ភុញ្ជិត្វា ពោធិសត្តស្ស គេហំ អគមាសិ ។ សោ ទ្វារេ ឋត្វា អត្តនោ អាគតភាវំ ជានាបេត្វា ឯកសបរិគ្គហំ អមរទេវិយា អាពេទា-បេសិ ។ សា តស្ស វចនំ សុត្វា ឯហីតិ អាហ ។ សោ គន្ត្វា តស្សា សន្តិកេ អដ្ឋាសិ ។ គ្រានោះ, អាចារ្យសេនក ធ្វើដោយបណ្តាំពាក្យនាងអមរា ហើយរៀបចំមកមុន ពេលនោះបន្តិច ឲ្យទៅប្រាប់នាងអមរាថា អញនាំអាត្មាមកដល់ហើយ នាងអមរាថា អើជាហើយ ឲ្យគាត់មកហោង ។ អាចារ្យសេនក ទៅកាន់សំណាក់នាងអមរានៅដោយចំណង់ចិត្ត, លំដាប់នោះ, នាងអមរាថានឹងអាចារ្យសេនកនូវពាក្យដូច្នេះថា ហៃអ្នកអើយ! ឥឡូវនេះ អញលុះដោយនូវអំណាចអ្នកហើយ ចូរអ្នកធ្វើដូច្នេះ អ្នកទៅដួតទឹកកក់សិតសក់ជំរះអាត្មាឲ្យជ្រះស្រះមន្ទិលក្អែលញើសសន្សឹមអ្នកមកហោង ។ រីអាចារ្យសេនកស្តាប់ពាក្យនាងអមរាហើយថា ហៃនាងអើយ ! សាធុពីរោះ ៗ ពេកហោង, ម្ល៉ោះហើយអាចារ្យសេនកដោះឡើង ចេញទៅអង្គុយនឹងធ្វើដោយពាក្យនាងអមរាបង្គាប់នោះ, រីអស់ខ្ញុំស្រីរបស់នាងអមរា ក៏នាំគ្នានឹងយកទឹកស្រោចកក់ ក៏រាជាន់ក្តារយន្តនោះ ពួដ៏កាលនោះ រាថ្ងស់គន្ទឹះក្តារយន្តនោះ របូតអាចារ្យសេនកធ្លាក់ចុះទៅក្នុងរណ្តៅនោះ

ហោង, ឯអាចារ្យទាំង ៣ នាក់នោះ សឹងដើរមកដោយលំដាប់គ្នា ដូចដំណើរនិយាយពីអាចារ្យសេនកមុននោះហោង, រីសូម្បីអ្នកទាំង ៤ នោះឋិតនៅក្នុងរណ្ដៅដំពៅបង្គន់លាមកនោះឋិតជិតគ្នា បើនឹងអន្ទ័យប្រមាណទឹមមាត់ ឯក្បាលប្រជុំគ្នា ហើយអាត្មាអាចារ្យសេនកប្រាប់ស្វាបថា នែណានេះ, អាចារ្យបុក្កសថា នែណានេះ រីអាចារ្យសេនកសោត ថាទៅវិញទៅមកនឹងអាចារ្យបុក្កុស ហើយស្រដីថា យើងធ្វើដូចម្ដេចឥឡូវនេះ? ។ អាចារ្យបុក្កុសថា វើយ អ្នកអើយ! កុំស្រដីខ្លាំងពេក, អំពើនោះសោត យើងខ្មាស់អស់មហាជនទាំងឡាយណាស់ហោង ម្ល៉ោះហើយកុំស្រដីខ្លាំងពេក ។ អាចារ្យទាំង ៤ នាក់នោះ សឹងឋិតនៅក្នុងរណ្ដៅបង្គន់នោះអស់មួយពត្រីនោះហោង ។

រីនាងអមរាបញ្ចោះអ្នកប្រាជ្ញទាំង ៤ នាក់នោះឲ្យការជាអាក្រក់មានសភាពជាបង្ហូរដូច្នេះហោង, លុះព្រឹកឡើង នាងឲ្យអូសចេញហើយបង្គាប់អស់មហាជនទាំងឡាយ ឲ្យយកពួរទៅឯអ្នកប្រាជ្ញទាំង ៤ នាក់អូសឡើងអំពីក្នុងរណ្ដៅបង្គន់នោះ ហើយឲ្យដូតទឹក, ឲ្យកោរក្បាល, ហើយឲ្យដុសនឹងឥដ្ឋឲ្យចេញឈាម ហើយឲ្យគ្រាំអង្ករដាល់ជាគម្ពៀឲ្យក្បូរជាបបរឲ្យរាប់ ឲ្យលាបស្រឡាបអំពីក្បាលអាចារ្យទាំង ៤ នាក់អស់ទាំងខ្លួនស្រេចហើយ ឲ្យយកសំឡីថ្ពបញ្ចោល្អិត ឲ្យផ្គិតអស់សពាង្គកាយឲ្យដាក់ទ្រូងរុំនឹងកន្ទេលចងខ្សែភ្ជាប់ហើយ នាងអមរាយកគ្នាឲ្យសែងទៅ

មួយអន្លើនឹងនាង យកទៅថ្វាយស្ដេចទតអ្នកទាំង ៤ នោះ, នាងបិតនៅ ហើយទូលស្ដេចថា បពិត្រមហារាជអើយ! អញ្ជើញម្ចាស់រមិលមើលដង្កាយទាំងឡាយនេះហោង, រីកន្ទេលរុំអ្នកទាំង ៤ នោះ នាងឲ្យលើកទៅដាក់ទៀបខាងព្រះបាទវិទេហរាជ ៗ ស្ដេចឲ្យបើកនូវដង្កាយនោះហើយទ្រង់ទតព្រះនេត្រទៅយល់អ្នកប្រាជ្ញទាំង ៤ នាក់ មានអាចារ្យសេនកជាដើមមានពណ៌ដូចជាស្វាស ហើយព្រះអង្គគង់ស្ងៀមនៅ ៗ

លំដាប់នោះ, រីអស់បណ្ដាមហាជនផងទាំងឡាយ លុះឃើញអាចារ្យទាំង ៤ នោះដូច្នោះហើយ ក៏នាំគ្នាសើចនូវសំណើចដ៏ខ្លាំងកងរំពងឡើង, សូម្បីអ្នកទាំង ៤ នោះខ្មាសគេច្រើនយ៉ាងណាក៏ដោយ ៗ ពេលនោះនាងអមរាទេវីទូលថា ទេវ បពិត្រម្ចាស់អើយ! រីសភាពខ្ញុំនេះមិនជាចោរឡើយ, បពិត្រម្ចាស់អើយ! ព្រោះមហោសថពុំជាទោសសត្រូវអ៊ើនឹងអម្ចាស់, នាងអមរាទូលទៀតថា បពិត្រម្ចាស់អើយ! រីអ្នកទាំង ៤ នាក់នេះ សឹងជាចោរពិតហោង ; ឯអាចារ្យសេនកគាត់ជាចោរលួចចុឡាមណីកែវអម្ចាស់, អាចារ្យបុក្កុសគាត់ជាចោរលួចសុវណ្ណ-មាលាអម្ចាស់, អាចារ្យកាមិន្ទគាត់ជាចោរលួចសំពត់កម្ពលអម្ចាស់, អាចារ្យទេវិន្ទគាត់ជាចោរលួចសុពណ៌បាទុកអម្ចាស់, រីអ្នកទាំង ៤ នេះប្រើឲ្យជូនទៅដល់អញខ្ញុំ ៗ យកអំពីដៃខ្ញុំស្រី ឈ្មោះដូច្នេះ, មានកំណត់ថា ថ្ងៃដូច្នេះ ខែដូច្នេះ ឆ្នាំដូច្នេះ, ចូរម្ចាស់រមិលមើលគុង

សំបុត្រអញខ្ញុំ ហើយសូមអញ្ជើញអម្ចាស់ទទួលយកព្រះរាជទ្រព្យវិញ ហោង, នាងថា បពិត្រមហារាជអើយ! វីអ្នកទាំង ៤ នាក់នេះ ឲ្យអម្ចាស់ទទួលយកជាចោរហោង, នាងធ្វើអ្នកទាំង ៤ នាក់ ឲ្យដល់នូវវិប្បការលំបាកពិការជាច្រើននូវប្រការអម្បាលនោះហើយ នាងថ្វាយបង្គំព្រះមហាក្សត្រត្រឡប់លីលាមកកាន់ផ្ទះអាត្មានាងវិញហោង ៗ លំដាប់នោះ, ស្ដេចមិនសន្និះសង្ស័យក្នុងសុភាពពោធិសត្វនោះឡើយ, ហេតុពុំមានអ្នកប្រាជ្ញក្រៃលែងនោះនឹងតែងចំរើន, ទើបស្ដេចពុំមានបន្ទូលនឹងអ្នកប្រាជ្ញទាំង ៤ នោះដល់តិចឡើយ, ហើយទើបស្ដេចមានបន្ទូលប្រើអាមាត្យទាំង ៤ ឲ្យងូតទឹកហើយបញ្ជូនទៅផ្ទះអាត្មាទីទៃ ៗ ហោង ៗ

ចន្ទាភេ បណ្ឌិតចោរ ឆដ្ឋិតា ៗ នេះនឹងស្រដីពីអ្នកប្រាជ្ញទាំង ៤ ជាចោរលួចព្រះរាជទ្រព្យស្ដេចនេះមិញ ក៏សុំចប់ដោយនូវប្រការអម្បាលនេះហោង ៗ

( នៅមានត )

ផ្នែកអក្សរសាស្ត្រ

## វប្បធម៌ខ្មែរ

# វប្បធម៌ផ្ដិតជាប់ក្នុងប្រវត្តិសាស្ត្រ


លោក លី - ធាមតេង

សមាជិកក្រុមអភិបាល សមាគមអ្នកនិពន្ធខ្មែរ


រៀបរៀង

---

កាលណា គេពោលពីវប្បធម៌ គេតែងតែនឹកឃើញដល់ប្រវត្តិសាស្ត្រនៅពេលជាមួយគ្នានោះដែរ ព្រោះប្រវត្តិសាស្ត្រនេះ ជាជង្រុកផ្ទុកនូវក្បួនខ្នាត ឬ ហេតុការណ៍គ្រប់បែបគ្រប់យ៉ាងនៃវប្បធម៌យើង ឬបើពោលឲ្យងាយស្ដាប់ជាងនេះបន្តិចទៅទៀតថា៖ ដើម្បីសិក្សាឲ្យបានយល់ច្បាស់ប្រាកដអំពីវប្បធម៌ គេត្រូវតែសំគីឈ្លេចឈ្លើសង្កេតក្នុងប្រវត្តិសាស្ត្រឲ្យបានល្អិតល្អន់ជាមុនសិន ។ ប្រវត្តិសាស្ត្រជាកញ្ចក់ ឬ កែវថតចុះជាប់នូវរឿងរ៉ាវរបស់ជាតិតាមយុគតាមសម័យ ដែលមានមកជាហូរហែតាមរយៈសតវត្សដែលកន្លងផុតទៅ ។

បើពោលពីសារៈសំខាន់របស់ប្រវត្តិសាស្ត្រដូចនេះ នាំឲ្យយើងភ្ញាក់ចិត្តនឹកឃើញដល់ប្រវត្តិសាស្ត្រជាតិយើង ដែលជាជាតិមួយមានរឿងរ៉ាវពង្សាវតារជាអង្វែងមកយូរឆ្នាំ យូរសតវត្សហើយថា៖ តើប្រវត្តិសាស្ត្រ

យេីងសព្វថ្ងៃស្ថិតនៅឯណាខ្លះ? មានបងជាក្បួនគ្រប់គ្រាន់សព្វគ្រប់ហើយឬនៅ? ឯការសិក្សារបស់បុលបុត្រ-ធីតាយេីង ត្រូវរេះប្រវត្តិសាស្ត្រជាតិខ្លួនឬទេ? សំនួរទាំងអម្បាលម៉ាននេះ នាំឲ្យយេីងសញ្ជឹងរិះរកចំលេីយ ដេីម្បីជាការត្រិះរិះពិចារណារបស់អ្នកមានទស្សនាវដ្ដីយេីងដូចតទៅ ៖

ជាយូរឆ្នាំមកហើយ ប្រវត្តិសាស្ត្រពុំទាន់មានជាក្បួនជាក្រាំងគម្ពីរមូលមត់នៅឡើយ ។ ឯការកត់កយនេះ ពុំមែនកើតឡើងដោយចាស់ព្រឹទ្ធាចារ្យយេីងឥតគំនិតនោះទេ គឺបណ្ដាលមកពីហេតុកេទស្រុកទេសរេះតែបង្ខិតបង្ខំឲ្យយេីងបាត់បង់ឯកសារ និងដានជាក់លាក់ដែលជារឿងរ៉ាវក្នុងប្រវត្តិសាស្ត្រយេីង ។ ដូច្នេះ រឿងរ៉ាវទាំងនោះ នៅចាំត្រឹមតែលេីមាត់មនុស្សណាដែលបានជួបប្រទះព្រឹត្តិការណ៍នោះៗ ។ លុះជនទាំងនោះស្លាប់បាត់បង់ទៅ រឿងរ៉ាវក៏បាត់រូបគោមច្បាស់លាស់ទៅជាមួយដែរ នៅសល់តែស្រមោលខ្លះក្នុងស្មារតីរបស់អ្នកដែលចងចាំជាដំណៗ មក និងពុំមានភាពពិតអះអាងឲ្យជាប់ខាតបានផង ។ ក្រៅពីនេះ មានឯកសារជាទិដ្ឋានុរូបខ្លះនៅលេីចារិកថ្ម គឺមានចារជាអក្សរលេីផ្ទាំងសិលា និងឆ្លាក់រូបភាពៈលេីផ្ទាំងជញ្ជាំងប្រាសាទនានា មានប្រាសាទអង្គរធំ, អង្គរវត្ត និងបន្ទាយស្រីជាដេីម ។ រូបភាពទាំងនោះ សម្ដែងពីជីវភាពរស់នៅរបស់អ្នកស្រុកយេីង (អង្គរធំ) និង ព្រឹត្តិការណ៍សង្គ្រាមព្រមទាំង

ជំនឿក្នុងលទ្ធិសាសនាណាមួយ សំរាប់ជាភស្តុតាងឲ្យយើងសព្វថ្ងៃយល់បានថា កាលសម័យនោះ ៗ យើងមានការរស់នៅបែបណា? មានជំនឿអ្វីខ្លះ? មានសង្គ្រាមឬទេ? ពិធីបរពេលប្រព្រឹត្តទៅដូចម្តេច? ៗ ប៉ុន្តែឯកសារទាំងនេះ ពុំទាន់បានជាពត៌មានគ្រប់គ្រាន់សព្វគ្រប់ទេ ព្រោះច្រើនតែមានត្រង់នេះ ឥតត្រង់នោះ ពោះ ៗ តាមការយល់ឬតាមមនោគតិអ្នកចារ ឬ អ្នកឆ្លាក់ ៗ ហេតុហ្នឹងហើយ បានជាយើងយល់ថា នៅខ្វះចន្លោះច្រើនអន្លើទៀត ដែលយើងត្រូវតែដឹង ត្រូវការចង់ដឹងយ៉ាងប្រាកដប្រជាគ្រប់ពេលគ្រប់សម័យ ក្នុងប្រវត្តិស្រុកទេសយើង ៗ

បំណោរតមក នៅក្នុងរជ្យព្រះករុណាព្រះបាទសម្តេចព្រះអង្គ-ចន្ទ ព្រះអង្គបានប្រជុំអ្នកកត់ត្រាឲ្យប្រមូលនូវរឿងរ៉ាវខ្លះ ៗ កត់ត្រាទុកដោយគោល ៗ ឡើង ៗ លុះមកដល់រជ្ជកាលព្រះបាទសម្តេចព្រះហរិរក្សរាមា-ធិបតីព្រះអង្គ-ឌួង កំណត់ហេតុទាំងនេះ ក៏បានរួបរួមជាក្រាំងជាសៀវ-ភៅមួយឡើង គ្រាន់ជាគ្រឿងបំភ្លឺរហូតមកដល់សព្វថ្ងៃនេះ ៗ

មានឯកសារមួយពួកទៀត កើតបានជារូបរាងឡើងដោយមតិជនជាតិបរទេស ដែលគេធ្វើដំណើរមកកាន់ប្រទេសយើងកាលពីសម័យមុន ហើយគេបានកត់ត្រាហេតុការណ៍ស្រុកទេសយើង ដើម្បីផ្សាយចូទៅក្នុងប្រទេសគេ មានជាតិចិន, ជាតិពរទុគេស៍ និង អេស្បាញ៉ុល ជាអាទិ៍ ៗ ពិតមែនតែឯកសារទាំងនេះ ពុំហូរហែសព្វគ្រប់ តែអ្នក

ប្រាជ្ញជាតិបារាំង សម័យដែលធ្វើជាអាណាព្យាបាលស្រុកយើង គេបានបង្កើតជាមន្ទីរស្រាវជ្រាវមួយ ដើម្បីប្រមូលរាវរកឯកសារពីគ្រប់ប្រភពដែលស្ដីពីប្រទេសយើង ហើយបោះពុម្ពផ្សាយឲ្យកូនចៅខ្មែររៀនសូត្រតាមគេរៀបចំតែងនោះ ។ ប៉ុន្តែ មកដល់បច្ចុប្បន្នកាលនេះ ជាសម័យដែលយើងត្រូវពិនិត្យសិក្សាពីវប្បធម៌យើងឡើងវិញដោយខ្លួនយើង ហេតុនេះក្បួនខ្នាតខាងប្រវត្តិសាស្ត្រ ក៏ត្រូវសើរើរៀបចំឡើងវិញដោយខ្លួនយើងដែរ ដើម្បីរាវរកឫសគល់ច្បាស់យកមកផ្សាយឲ្យកុលបុត្រ-ធីតាយើងទៅក្រោយ ៗ រៀនសូត្រយ៉ាងច្បាស់ពីធាតុពិត ៗ របស់មាតុភូមិជាទីស្រឡាញ់របស់យើង ។ ឯការកសាងក្បួនខ្នាតប្រវត្តិសាស្ត្រនេះ ពុំអាចធ្វើឡើងដោយកំឡាំងឯកជនបានឡើយ ដ្បិតខ្វះមធ្យោបាយសំរាប់បំពេញកិច្ចការទាំងនោះឲ្យជាក់លាក់ ។ ដូច្នេះ ត្រូវតែធ្វើដោយកំឡាំងរួបរួមអ្នកវិះស្រាវជ្រាវច្រើនរូប ដោយប្រមូលយកឯកសារពីប្រភពសំខាន់ ៗ ទាំងប្រាំគឺ ៖ ១- សិលាចារឹក, ២ ព្រះរាជពង្សាវតារខ្មែរដែលមាននៅក្នុងសាលាបណ្ណិត្យស្រាប់, ៣ ឯកសារចិន, ឯកសារជាតិពទុគេស៍ នឹង អេស្ប៉ាញ៉ុល, ៥- រឿងព្រេងដែលនៅប្រចាំភូមិពាសពេញក្នុងប្រទេសយើង ។ កាលណាគណៈកម្មការស្រាវជ្រាវបានឯកសារទាំងនេះមកហើយ គណៈកម្មការអាចផ្ទៀងផ្ទាត់ដោយប្រៀបធៀបហេតុការណ៍មួយ នឹង ហេតុការណ៍មួយទាល់តែរកឃើញការពិត

ហើយបង្កើនឡើងវិញ  ដោះពុម្ពផ្សាយឲ្យបានទូទៅក្នុងប្រទេសយើង ជាពិសេសក្នុងមជ្ឈដ្ឋានសិក្សានានា ។

ហេតុតាំងប៉ុន្មាន  ដែលពោលមកហើយខាងលើនេះ គ្រាន់តែបញ្ជាក់ចំពោះមតិយើងដែលយល់ថា៖ វប្បធម៌យើងពិតជាផ្ទិតជាប់នៅក្នុងប្រវត្តិសាស្ត្រ ។ គឺថាបើសិក្សាពីវប្បធម៌ខ្មែរ ត្រូវសិក្សាពីប្រវត្តិសាស្ត្រខ្មែរជាបឋម បើត្រូវការចាំបាច់ក្នុងការសិក្សាពីប្រវត្តិសាស្ត្រយ៉ាងនេះ ប្រវត្តិសាស្ត្រក៏ត្រូវតែមានភាពជាក់លាក់ឡើងដែរ ដើម្បីគ្រោលបំភ្លឺវប្បធម៌ជាតិឲ្យមានរស្មីប្រាលរន្ទាលឡើងក្នុងសន្តានចិត្តជនជាតិយើង ។ មូលហេតុតាំងនេះឯង ដែលជាបញ្ហាមួយជាកាតព្វកិច្ចថា : ប្រវត្តិសាស្ត្រយើងក៏ត្រូវតែកសាងឡើងជាការចាំបាច់ដែរ ។

(នៅមានត)

# ពាក្យខ្មែរប្រែចេញពីបរទេស

## ដោយគណៈកម្មការវប្បធម៌

(តមក)

| | | |
|---|---|---|
| Calamité | *n. f.* | វិបត្តិភ័យ |
| Calamiteux | *adj.* | មានវិបត្តិភ័យ |
| Sinistre | *n. m.* | ជាបគ្រោះ |
| Malheur | *n. m.* | អពមង្គល |
| Exploitation | *n. f.* | អាជីវកម្ម, ទោហនកម្ម |
| Compte d'exploitation | | គណនីទោហនកម្ម |
| Compte de résultat ou de profit et de perte | | គណនីលទ្ធផលឬគុណប្រយោជន៍និងការខាតបង់ ។ |
| Plus-value | *n. f.* | អធិកលាភ |
| Compte financier | | គណនីហេរញ្ញិក |
| Compte d'actif, du passif | | គណនីសកម្ម, អកម្ម |
| Aval | *n. m.* | រូបិយបដិភោគ |
| Avaliste | *n. m.* | រូបិយបដិភោគី |
| Profit brut | | គុណប្រយោជន៍ ដុល |
| Profit net | | គុណប្រយោជន៍ សុទ្ធ |
| Ne varietur | | អបរិណាម |
| Roche stratifiée | | សិលាស្តរិត |
| Fossile | | ជាសាណីភូត |
| Spath d'Islande | | ស្ប៉ាត |
| Gneiss | *n. m.* | ញ៉ែស |

(នៅមានត)

## វចនានុក្រមសំស្ក្រឹត.ខ្មែរ

*ព្រះមហា ឋាំង - ខាត់ រៀបរៀង*

តមក

---

អតិមុត្តិ ស្រ្តី. កិរិយារួចក្រៃលែង ។

អតិមុខរ គុ. ដែលនិយាយច្រើន ។

អតិមុគ្ធ គុ. ដែលជ្រួលជ្រើមក្រៃលែង, ដែលជ្រួលច្របល់ ។

អតិមុបី ធាតុ. រូបក្រៃលែង ។

អតិមូឍ គុ. ដែលឆ្កួតក្រៃលែង ។

អតិមូត្រ គុ. ដែលមានមូត្រក្រៃលែង, (ដែលរូបពីមូត្រ)

អតិម្ទី ធាតុ. បំផ្លាញក្រៃលែង ។

អតិម្ទុហ្ទយតា ស្រ្តី. ការដែលបុគ្គលមានហឫទ័យទន់ភ្លន់ក្រៃលែង។

អតិមោក្ស ពុ. កិរិយារួចក្រៃលែង, មោក្ខដ៏ប្រសើរ ។

អតិយត្ន បុំ. សេចក្តីព្យាយាមដ៏ក្រៃលែង ។

អតិយន្ត្រណា ស្រ្តី. សេចក្តីបង្អៀតបង្អល់ក្រៃលែង ។

អតិយឝ ឬ អតិយឝស៑ គុ. ដែលមានយសក្រៃលែង ។

(នៅមានត)

# រឿងសាមកុក

## កណ្ឌទី ៤៥

ឧកញ៉ាវិបុលរាជសេនា ង្ហួ-កិន ប្រែរៀបរៀង

(តមក)

| |
|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ<br>អ្នកវាងវៃឆ្លាសបើបានអាន<br>នឹងបេះឲ្យបាយកលបំណាន<br>ទាំងមានសន្តានស្នេហាជាតិ ។ |

ទៀវហៀនទីប្រឹក្សាក៏និយាយនឹងស៊ុនគួនថា ដែលជាហេតុដូច្នេះ ព្រោះលោកលើកកំពស់ខ្លួនមើលងាយមិនខ្លាចដល់សឹកសត្រូវ មិនសូវរាំងការពាររក្សាខ្លួន ឯប្រវេណីការសង្គ្រាមនេះគួរនឹងប្រើទាហានដែលមានថ្វីដៃខ្លាំងពូកែចេញច្បាំងជាមុន មិនត្រូវមេទ័ពនឹងចេញច្បាំងដោយខ្លួនឯងជាមុនទេ ខ្លួនលោកជាធំមិនសមនឹងមិនពិគ្រោះមើលការគួរឬមិនគួរ ប្រញាប់តែចេញទៅតច្បាំងនឹងទៀវលៀវ ដែលត្រឹមតែជានាយទាហាន បាឌជាមានសេចក្តីធ្លស់ការខូចខាតទាហានឯកយ៉ាងនេះ គួរឲ្យស្តាយណាស់ ស៊ុនគួនទទួលខ្លួនថា ខ្ញុំធ្លោយខ្លួនខុសហើយ អ្នកនិយាយនោះត្រូវណាស់ ការដែលធ្លស់ធ្លោយដូច្នេះ ព្រោះយើងគិតខុសដោយខ្លួនឯង ៗ

ខណៈនោះ ថៃស៊ិជួក៏ចូលមកជំពបស៊ិនគួនថា កោកេងបាវខ្ញុំបាទ មានបងប្អូនឈ្មោះ “ អាវហោ ” ជាមនុស្សឃ្លាលសេះរបស់ទៀវលៀវ អាវហោគ្មានទោសខុសពីអ្វីសោះ ទៀវលៀវយកខ្លួនទៅធ្វើទោស អាវ-ហោមានសេចក្តីខឹងក្តៅក្រហាយឲ្យមនុស្សមកប្រាប់ខ្ញុំបាទថា ពេលយប់នេះ អាវហោនឹងគិតសម្លាប់ទៀវលៀវចេញ ហើយដុតភ្លើងឡើងជាសំគាល់ ខ្ញុំបាទនឹងសុំទាហានលើកទៅធ្វើការជាមួយនឹងអាវហោ មុខជានឹងសងសឹកជំនួសស៊ុងខៀមបាន ។

ស៊ិនគួនសួរថា ឥឡូវកោកេងនៅឯណា ថៃស៊ិជួថា កោកេងបន្ទំជាទាហានទៀវលៀវចូលទៅក្នុងស្រុកហ័បប៉ាហើយ ស៊ិនគួនឮដូច្នោះក៏-មានអំណរណាស់ ទើបចាត់ទាហាន ១ ពាន់ឲ្យថៃស៊ិជួ ជួកាត់គិនក៏-និយាយនឹងថៃស៊ិជួថា ទៀវលៀវនោះមានដម្រេះប្រាជ្ញានឹងថ្ងៃដៃខ្លាំងពូកែណាស់មុខជាមិនធ្វេសប្រមាទ អ្នកត្រូវរិះគិតឲ្យល្អិតល្អ កុំអាលមើលងាយទៀវលៀវនោះឡើយ ថៃស៊ិជួមិនបានឆ្លើយតបថាម្តេច ក៏លាស៊ិនគួនលើកទាហានចេញតាកបន្ទាយទៅ ។

ឯកោកេងដែលបន្ទំជាទាហានទៀវលៀវ ចូលទៅក្នុងស្រុកហ័បប៉ានោះ ក៏និយាយនឹងអាវហោថា ថ្ងៃមិញយើងឲ្យមនុស្សទៅប្រាប់ថៃស៊ិជួ ថៃស៊ិជួផ្តាំមកថា ពេលយប់នេះនឹងលើកទាហានមកចាំខាងក្រៅកំផែងស្រុក ការខាងក្នុងនេះអ្នកនឹងរិះគិតប្រការម្តេច អាវហោថា ទីលំនៅដែល

ខ្ញុំស្នាក់នៅនេះ ជិតទៀបកន្លែងទៀវលៀវណាស់ ពេលយប់នេះខ្ញុំនឹងយកភ្លើងដុតគំនរចម្បើងឲ្យឆេះភ្លឺឡើង បើកាលណាភ្លើងឆេះហើយឲ្យអ្នកស្រែកថា សត្រូវចូលស្រុកបានហើយ ពួកអ្នកស្រុកទាំងអស់គ្នាមិនទាន់ដឹងការក៏នឹងភ្ញាក់ផ្អើលច្រួលច្របល់វឹកវរឡើង បើទៀវលៀវនឹងមកលត់ភ្លើង ខ្ញុំនឹងលបចាក់ទៀវលៀវឲ្យស្លាប់ កោកេងឮដូច្នោះក៏យល់ឃើញត្រូវ ។

ឯទៀវលៀវកាលដែលត្រឡប់ចូលទៅក្នុងស្រុកហ័បប៉ាវិញ ក៏ត្រួតត្រាកេក្ខាទាហានទាំងអស់ឲ្យយាមល្បាតហើយបង្គាប់ថា ពេលយប់នេះអ្នកពល់គ្នាកុំបីប្រមាទ ឲ្យរិះគិតការពារកេក្ខាខ្លួនឲ្យមែនទែន ត្រូវតែពាក់គ្រោះសៀតអាវុធដេកគ្រប់គ្នា ទាហានទាំងពួងឆ្លើយថា កាលពីថ្ងៃដែលយើងមានជ័យជំនះ ស៊ុនគួនបែកបាក់ទៅហើយ លោកនឹងឲ្យរាំងរក្សាដោយហេតុអ្វី ? ទៀវលៀវថា ធម្មតាអ្នកដែលជានាយកងនាយទ័ពនឹងធ្វើការសង្គ្រាមនោះ បើចាញ់ក៏កុំអាលតូចចិត្តណាស់ បើបានជ័យជំនះក៏កុំអាលត្រេកត្រអាលណាស់ កាលពីថ្ងៃដែលយើងបានជ័យជំនះហើយ បើប្រមាទធ្លោយក្រែងស៊ុនគួនមានចិត្តគិតក្តៅឃើញថាយើងភ្លើតភ្លើន ក៏នឹងលើកទាហានមកបោមយាយ យើងនឹងមិនអន្តរាយទេឬ ហេតុនេះបានជាយើងហាមប្រាមអ្នកពល់គ្នាឲ្យប្រុងប្រយ័ត្នដោយហេតុនេះ ។

ខណៈកាលទៀវលៀវកំពុងនិយាយនឹងទាហាននោះ ក៏ឃើញភ្លើង

ឆេះឡើងក្នុងខាងក្រោយបន្ទាយហើយស្រែកថា សត្រូវចូលស្រុកបាន ហើយ ពួកអ្នកស្រុកទាំងពួងក៏ភ្ញាក់ផ្អើលច្រួលច្របល់វឹកវរសន្ធឹកណាស់ ទៀវលៀវឃើញដូច្នោះក៏តក់ស្លុតក្នុងចិត្តទើបឡើងសេះនាំទាហាន ៦ នាក់ ចេញទៅឈរទទឹងផ្លូវ ទាហានស្រែកថា ឮសំឡេងជិតណាស់មកហើយ មុខជាសត្រូវនឹងចូលមកដល់ ទៀវលៀវថាមិនទាន់ឃើញអ្វីជាបំប្លែកទេ វាធ្វើកែងដូច្នេះប្រាថ្នានឹងឲ្យមនុស្សទាំងអស់គ្នាភ្ញាក់ផ្អើលទេ ហើយទៀវ-លៀវក៏ប្រាប់ទាហានទាំងពួងថា បើនរណាផ្អើលវឹកវរនឹងឲ្យកាត់ក្បាល ចេញ ឲ្យនាំគ្នាចាប់ខ្លួនឈ្មោះណាជាដើមហេតុឲ្យបាន ប្រហែល ១ ម៉ោង លីទៀនក៏ចាប់ខ្លួនកោតេងនឹងអាវចោមកឲ្យទៀវលៀវ ៗ សួរសាកដឹង សេចក្តីហើយ ក៏ឲ្យទាហាននាំខ្លួនកោតេងនឹងអាវចោទៅប្រហារជីវិត ៗ ទទួលសំឡេងទាហាន វាយឃោះគងទូងស្គរហ៊ោកញ្ជ្រៀវអឺងកងក្រៅ ស្រុក ទៀវលៀវក៏និយាយនឹងទាហានទាំងពួងថា កងទ័ពស៊ុនគួនលើក មកធ្វើការតាមសញ្ញាកោតេងហើយ យើងត្រូវគិតត្រួតកលស៊ុនគួនឲ្យ បានវិញ ទៀវលៀវ ក៏ឲ្យទាហានយកភ្លើងដុតឡើងក្នុងស្រុក ហើយ បើកទ្វារចេញស្រែកថា សម្លាប់សត្រូវចូលស្រុកបានហើយ ៗ

ថៃស៊ូជូឮដូច្នោះក៏សំគាល់ថា កោតេងនឹងអាវចោធ្វើការសម្រេច ហើយក៏បំផាយសេះផ្ទែកមកមុខទាហានៈទៅក្នុងស្រុក ទៀវលៀវឲ្យយក ធ្នូបាញ់ចម្រុះចូលមកទាំងសងខាងផ្លូវ ត្រូវថៃស៊ូជូជាច្រើនអន្លើ ថៃស៊ូជូ

ភ័យណាស់ក៏ញាក់សេះត្រឡប់ទៅវិញ ទៀវលៀវក៏ឲ្យង័កជិនដេញពីក្រោយថៃស៊ីជូទៅដល់មុខបន្ទាយស៊ុនគួន, ឡុកស៊ុនទឹងតាំងសិតឃើញដូច្នោះក៏លើកទាហានចេញមកជួយថៃស៊ីជូ លីទៀនទឹងង័កជិនដេញកាប់សម្លាប់ទាហានថៃស៊ីជូស្លាប់ជាច្រើន ហើយឃើញឡុងសុន តាំងសិតចេញមកជួយថៃស៊ីជូ លីទៀនទឹងង័កជិនក៏លើកទាហានត្រឡប់ចូលទៅស្រុកវិញ ឡុកស៊ុនទឹងតាំងសិតក៏នាំថៃស៊ីជូចូលទៅក្នុងបន្ទាយ ស៊ុនគួនឃើញថៃស៊ីជូ ត្រូវរបួសព្រួញឈឺចាប់ជាទម្ងន់ជាច្រើនអន្លើ ឃើញថានឹងមិនរស់ជីវិត ក៏នឹកអាណិតណាស់ ។

ទៀវលៀវនិយាយនឹងស៊ុនគួនថា យើងលើកទ័ពមកគ្រានេះ ឃើញខូចខាតទាហានច្រើនណាស់ គ្រានេះថៃស៊ីជូក៏ពិការធ្ងន់ទៅទៀត សុំឲ្យលើកទ័ពត្រឡប់ទៅស្រុកយើងសិនចុះ នឹងបានរិះគិតការគេទៅទៀត ស៊ុនគួនក៏យល់ឃើញត្រូវ ទើបចាត់ឲ្យទាហានរៀបចំទូកបម្រុងលើកទ័ពត្រឡប់ទៅស្រុកឡាំស៊ី លុះទៅដល់ថៃស៊ីជូក៏រឹតឈឺធ្ងន់ចុះ ស៊ុនគួនក៏ឲ្យទៀវជៀវទៅសួរថៃស៊ីជូ ។ និយាយនឹងទៀវជៀវថា កើតមកជាកូនប្រុសទោះបីនឹងស្លាប់ក្នុងទីសង្គ្រាមសឹក ក៏មិនត្រូវនឹកស្តាយអាយុជីវិត ត្រូវតែគិតធ្វើការឲ្យពេញដៃជើង ឥឡូវខ្លួនយើងមកអស់អាយុកំពុងពេញពាលដូច្នេះ ថៃស៊ីជូថាតែប៉ុណ្ណោះក៏ដាច់ខ្យល់ស្លាប់ កាលថៃស៊ីជូស្លាប់

នោះទើបបានអាយុ ៤១ ឆ្នាំ ស៊ិនគួនជីងថាថៃស៊ូជួស្លាប់ក៏ខឹកអាណិត អនាថពន់ប្រមាណណាស់ ទើបឲ្យតែងការសពនាំទៅកប់ទុកនៅជើងភ្នំ ប៉ាក់ក្លួហើយយកថៃស៊ូអៀងជាបុត្រថៃស៊ូជួមកធ្វើការជំនួសបិតា ។

ឯឡៅពីនៅស្រុកកេងជីវ ឮថាស៊ិនគួនលើកទ័ពទៅវាយស្រុកហ័ប-ប៉ា បរាជ័យនឹងឡេវលៀងត្រឡប់លើកទ័ពមកស្រុកឡាំស៊ុ ក៏ហៅខុងបេងមកពិគ្រោះ ខុងបេងថា កាលពីយប់មិញខ្ញុំមើលឫក្សឃើញផ្កាយ ១ ដួងធ្លាក់ចុះមកខាងទិសឯជើងគៀងឯលិច ឃើញថានឹងខូចរង្សរបស់លោកម្នាក់ជាប្រាកដ ទទួលទាហានមកប្រាប់ឡៅពីថា ឡៅគីជាបុត្រឡៅពៀវដែលឈឺនោះស្លាប់ទៅហើយ ឡៅពីឮដូច្នោះ ក៏យំសោកាល័យឡៅគី ខុងបេងក៏និយាយនឹងឡៅពីថា ការដែលកើតមកហើយរមែងជាគួតានឹងសេចក្ដីស្លាប់គ្រប់ ១ រូបកាយ គេយើងទាំងឡាយនឹងចៀសចាក់មិនបានទេ លោកនឹងមកសោកយំដូច្នេះ រោគក៏នឹងបង្កើតឡើង កិច្ចការដែលយើងនឹងគិតធ្វើតទៅនោះក៏ជាច្រើនណាស់ សុំឲ្យលោករះគិតចាត់ទាហានឲ្យទៅនៅរក្សាស្រុកសុងយ៉ុងជំនួសឡៅគីចុះ ។

ឡៅពីក៏ប្រើគួនអ៊ូឲ្យទៅរៀបចំសពឡៅគី ហើយឲ្យនៅរក្សាស្រុកសុងយ៉ុង ឡៅពីក៏និយាយនឹងខុងបេងថា ឥឡូវឡៅគីស្លាប់ហើយ មុខជាស៊ិនគួននឹងឲ្យមកទារយកស្រុកកេងជីវជាប្រាកដ លោកនឹងរះគិតកែខៃយ៉ាងណា ខុងបេងថា លោកកុំព្រួយរវល់ជាទុក្ខឡើយ ការនោះជាភ្នាក់

ងាររបស់ខ្ញុំនឹងទទួលជាធុរៈ លុះកន្លងមក ១៥ ថ្ងៃ មានទាហានមកប្រាប់ ឡេវពីថា ស៊ិនគួនឲ្យឡោសុកមកសួរដំណឹងឡេវគី ខុនបែងក៏ចម្ងល់ ឡេវពីចេញទៅទទួលឡោសុកចូលមកដល់ទីលំនៅ គំនាប់គ្នាហើយឡោ-សុកក៏ថាស៊ិនគួនព្វថាឡេវគីអនិច្ចកម្ម បានជាប្រើខ្ញុំឲ្យយកធូបទៀនមកសួរ ជាដំណឹងសពតាមទំលាប់ពប់អាន កាលខ្ញុំនឹងមកនោះដីវយីក៏បានឲ្យពារ មកដល់លោកផង ឡេវពីនឹងខុនបែងព្វដូច្នោះ ក៏ក្រោកឡើងគំនាប់ទទួល យកធូបទៀន ហើយអញ្ជើញឡោសុកឲ្យបរិភោគអាហារ ខណៈកាល កំពុងសេពសុក ឡោសុកក៏សួរឡេវពីថា ពីដើមលោកបានមានប្រសាសន៍ នឹងខ្ញុំថា បើឡេវពីអស់ព្រេងសំណាងហើយ នឹងបង្វិលស្រុកកេងជីវឲ្យ ស៊ិនគួនវិញ ឥឡូវឡេវគីអនិច្ចកម្មហើយ លោកនឹងបង្វិលស្រុកឲ្យខ្ញុំថ្ងៃ ណា នឹងបានចាត់អ្នកពជការឲ្យមកឈររក្សាតទៅ ឡេវពីថា អញ្ជើញ អ្នកពិសារគ្រឿយាស្រាបាយឲ្យសប្បាយចិត្តសិនចុះ រួចសឹមប្រឹក្សាគ្នាជា ក្រោយ ឡោសុកដំភាស់នឹងឡេវពីមិនបានក៏ស្ងៀមទំតែបរិភោគអាហារ លុះយូរបន្តិចឡោសុកក៏ឡើងនិយាយទៅឡេវពីទៀត ឡេវពីមិនឆ្លើយថា ម្ដេច ។

ខុនបែងធ្វើជាខឹងនិយាយនឹងឡោសុកថា អ្នកជាមនុស្សមានដម្រេះ ប្រាជ្ញាដឹងការពក់ព្រៅ បើនៅស្ងៀមនឹងឲ្យយើងបើកមាត់និយាយផងបាន ឬ ? កាលគ្រាព្រះចៅហ័នកោចានោះ ទ្រង់ក៏មានព្រះទ័យអាសូរតែរណា

អស់អាណាប្រជានុរាស្ត្រទាំងពួង ទើបបានសោយរាជសម្បត្តិព្រះរាជ-វង្សរៀងមក លុះដល់ព្រះចៅហៀនតេសព្វថ្ងៃនេះ ផែនដីក៏នៅមិនទាន់រាបទាប ព្រោះនាម៉ឺនខែត្រខណ្ឌទាំងពួងដែលមានសក្តិកំឡាំងប្រហែលគ្នា ក៏នៅមិនទាន់រួបរួមជួយគ្នាទំនុកបំរុងព្រះចៅហៀនតេសោះ បណ្តា-អាណាខែត្រទាំងអស់ ក៏សឹងតែប្រទូស្តគ្នាមិនចំណុះចូលទៅខាងណាឡៀវពីជាចៅហ្វាយខ្ញុំ ក៏ជាពូជព្រះរាជវង្សជាប់លោហិតមកពីព្រះចៅ "ហៅកេងតេ" បាន ២៤ ជួរក្សត្រិយ៍ លុះដល់ឡៀវពីៗ ក៏ជាប់ព្រះចៅហៀនតេ ប្រោកដនោះត្រឹមតែផែនដី ១ ដុំប៉ុនស្រុកកេងជីវប៉ុណ្ណោះ នឹងយកទុកជាទីស្នាក់អាស្រ័យមិនបានឬ ឯស៊ុនគួនចៅហ្វាយអ្នកជាពូជភូឃុំស្រុកជីតង់ទេតើ ឥឡូវបានជាធំក្នុងស្រុកកាំងតាំង មានស្រុកទោ ៦ ដំបន់ទាំងពលទាហានក៏មាំមួនច្រើនណាស់នៅមិនទាន់ឆ្អែតចិត្តទេឬ ? បានជាឲ្យមកទាស្រុកកេងជីវទៀត មួយទៀតកាលចូចូលើកទ័ពទឹកទ័ពគោកមកវាយស្រុកកាំងតាំងនោះ ឡៀវពីក៏បានលើកទាហានទៅជួយច្បាំងជាមាំមួនទាំងខ្លួនខ្ញុំក៏បានជួយហៅខ្យល់ឲ្យស៊ុនគួន ទើបមិនបានជាអន្តរាយ បើខ្ញុំមិនទៅជួយ កុំថាតែបុត្រីងាងកៀវកុកឡើយប៉ុណ្ណោះ ទោះភរិយាបុត្ររបស់អ្នកនឹងជាមិត្តភក្តិរបស់ចូចូទាំងអស់ ៗ

ឡោស៊ុកឮដូច្នោះក៏មិនបានតបថាប្រការម្តេច ស្ងៀមនៅយូរណាស់ក៏ឆ្លើយផ្តាស់តបទៅខុងបេងថា ឯស្រុកកេងជីវនេះជាធុរៈចំពោះលើខ្លួនខ្ញុំ

ផង ដែលលោកមានប្រសាសន៍ប្រៀបធៀបដូច្នេះមិនត្រូវផ្លូវសេចក្ដីសោះ ខុងបេងក៏សួរឡោសុកថា ហេតុម្ដេចបានជាអ្នកថាមិនត្រូវផ្លូវសេចក្ដី ឡោ-សុកថា កាលគ្រាឡៅពីបានសេចក្ដីលំបាក បែកទ័ពពីចូឆូទៅស្រុកស៊ុងយ៉ុងនោះ ខ្ញុំក៏បាននាំលោកទៅជួបនឹងស៊ុនគួន ខ្ញុំក៏បានខ្ចីស្រុកកេងជីវឲ្យលោក លុះជីវយីលើកទ័ពមកច្បាំងគិតនឹងយកស្រុកកេងជីវវិញ ខ្ញុំក៏បាននិយាយឃាត់ទាំងកំផែកមិនឲ្យជីវយីលើកមក បានជាខ្ញុំមកជួបនឹងលោក ៗ នឹងឡៅពីក៏បាននិយាយប្ដេជ្ញាថា បើឡៅពីអស់បុណ្យវាសនាកាលណា នឹងបង្វិលស្រុកកេងជីវឲ្យស៊ុនគួនវិញ ខ្ញុំក៏បានរ៉ាប់រងធានា ឥឡូវលោកបែរជាខុសអំពីពាក្យមុន ខ្ញុំនឹងយកសេចក្ដីត្រង់ណាទៅដោះសានឹងស៊ុនគួនបាន ឯជីវយីនឹងស៊ុនគួន ក៏រាប់អានលោកនឹងឡៅពីថាមានពាក្យសត្យពិតត្រង់ បើខ្ញុំទៅប្រាប់តាមពាក្យលោកនិយាយ ស៊ុនគួនក៏មិនជឿស្ដាប់ ត្រឡប់យកទោសខ្ញុំវិញ ទោះបីខ្លួនខ្ញុំនឹងស្លាប់មិញ ខ្ញុំក៏-មិនស្ដាយជីវិត តែនៅគិតបរិតក្កថា មុខជាស៊ុនគួននឹងឡៅពីប្រែទៅជាសត្រូវនឹងគ្នា បើឡៅពីនឹងស៊ុនគួនជាខ្មាំងសត្រូវនឹងគ្នាហើយ លោកក៏អស់បានសេចក្ដីសុខ មនុស្សអ្នកស្រុកទាំងអស់ក៏នឹងសើចដំនៀលថាលោកជាអ្នកមានដម្រេះប្រាជ្ញាមកបែរជា ត្រឡប់ត្រឡិនមិនពិតត្រង់ បានជាកើតហេតុដូច្នេះ ។

ខុងបេងថា អ្នកកុំនិយាយថ្វី ខ្ញុំនឹងខ្លាចអ្វីដណ្ដូចជីវិតជីវយីប៉ុណ្ណោះ

ព្រោះជាកេងតូចណាស់ សូម្បីបូជនឹងលើកមករាប់រយម៉ឺន ម្ដេចខ្ញុំមិនខ្លាច តែខ្ញុំឃើញអ្នកមានសេចក្ដីរឯងក្រែងខុស ខ្ញុំក៏រិះគិតនឹងឡោពីសរសេរជាសំបុត្រសញ្ញាផ្ញើទៅស៊ុនគួន ថានឹងខ្ចីស្រុកកេងជីវទុកជាទីស្នាក់អាស្រ័យសិន តទៅមុខ បើឡោពីទៅច្បាំងបានស្រុកណា សឹមបង្វិលស្រុកកេងជីវឲ្យវិញ តើអ្នកនឹងយល់ឃើញដូចម្ដេច ។

ឡោសុកក៏សួរថា លោកវាយបានស្រុកណា ទើបនឹងបង្វិលស្រុកកេងជីវឲ្យវិញ ខុងបេងថា ខ្ញុំគិតនឹងទៅវាយយកស្រុកហ៊ូគោ តែឃើញថាជាស្រុកចំនឹងយកដោយរហ័សឆាប់ពុំបាន ឯស្រុកសៃឈួននោះសោតឡៅដៀងចៅហ្វាយស្រុកជាមនុស្សល្ងង់អាប់ឥតប្រាជ្ញា ខ្ញុំនឹងឲ្យឡោពីទៅវាយយកដែរ បើបានស្រុកសៃឈួនហើយ ទើបខ្ញុំនឹងបង្វិលស្រុកកេងជីវឲ្យវិញ ឡោសុកឮដូច្នោះក៏អារម្មណ៍ចិត្តខុងបេង ព្រមទទួលពាក្យតាមដែលខុងបេងនិយាយគ្រប់ប្រការ ។

ខណៈនោះឡោពីក៏សរសេរសំបុត្រតាមពាក្យដែលខុងបេងថា នោះដាក់ឈ្មោះខុងបេងជានាយប្រកាន់ទទួលធានា ខុងបេងក៏និយាយនឹងឡោសុកថា ខ្លួនខ្ញុំជាពួកម៉ាករបស់ឡោពីបុះឈ្មោះជាអ្នកធានា មុខជាស៊ុនគួនមិនសុខចិត្តនឹងសុំឈ្មោះអ្នកដាក់បុះក្នុងសំបុត្រជាធានាផង ទើបស៊ុនគួនអស់សង្ស័យ ឡោសុកថា ឯខ្លួនខ្ញុំរាប់អានឡោពីថាជាមនុស្សមានចិត្ត

មេត្តាកប់ឝានដោយសុចរិតពិតត្រង់ បើចង់ចុះឈ្មោះខ្ញុំផងក៏បាន ឡៅតីក៏សរសេរចុះឈ្មោះឡោសុកជាអ្នកធានាខាងចុងក្រដាស ហើយប្រគល់សំបុត្រនោះទៅឲ្យឡោសុក ។ ទទួលសំបុត្រហើយក៏លាឡៅតី-ខុងបេងទៅវិញ ។ ឡៅតី·ខុងបេងក៏តាមជូនដំណើរឡោសុកទៅដល់ទូក កាលឡោសុកនឹងចេញទូកទៅនោះ ខុងបេងក្លែងនិយាយថា បើអ្នកទៅដល់ស៊ុនគួនហើយ ចូរជួយនិយាយឲ្យល្អផង ដើម្បីនឹងឲ្យចៅហ្វាយយើងទាំង ២ ប្រក្រតីនឹងគ្នាតទៅ កុំឲ្យចូច្ចូរមើលងាយប្រមាថយើងបាន បើអ្នកមិនធ្វើតាមពាក្យខ្ញុំនិយាយទេ ទោះបីស្រុកកាំងតាំងនឹងអាណាខែត្រឯទៀតខ្ញុំក៏នឹងកយដណ្ដើមយកទាំងអស់ ។

---

(នៅមានត)

## រឿងមនុស្សពិតប្រែប្រួល

## ឃុនបណ្ណានុរក្ស ប៊ូ-ប៊ូ រៀបរៀង

(តចប់)

---

នាងរស់ អង្គុយប៉ះទោះបណ្ដើរស្ដាប់អាពុកនឹងកូនសន្ទនាគ្នាបណ្ដើរ ឮកូនបេះតែប្រកែកដូច្នោះ គឺងចិត្តពេកឆ្លើយថា ណ្ហើយគេហ៎! ឈប់និយាយទៅ កុំបន្ទំចិត្តវា បើវាមិនតាមយើងជាម៉ែឪទេ ស្រេចនឹងវាចុះ ប្អូនលោកថា "ដំមិនដែលធំជាងឆ្នាំង" ឥឡូវ បើទំធំជាងឆ្នាំងហើយ នៅទទូចនិយាយថ្វីទៀត ព្រឹកស្អែកឲ្យវាទៅធ្វើចំការឯថ្គុតទៅ ។

ព្រឹកឡើង នាងរស់រៀបអង្ករគ្រឿងឆៀត ឲ្យដីប្រែយកទៅចំការផ្ដាំថា ថ្ងៃត្រង់ឯងដាំបាយបរិភោគនៅចំការចុះ ល្ងាចចាំមកបាយឯផ្ទះ ដ្បិតភូមិថ្គុតឆ្ងាយពីភូមិកោះរះ លំបាកទៅមក ។

ដីប្រែ— ទឹមគោអូសនង្គ័លនៅភ្ជួរដីចំការនៅខាងត្បូងវត្តថ្គុត តាំងពីព្រលឹមដល់ថ្ងៃត្រង់ទើបឈប់សំរាកបាយអាស្រ័យ ថ្ងៃបន្តិចភ្ជួរតទៅទៀត រហូតដល់ថ្ងៃរសៀលទាបលែងភ្ជួរបរគោមកផ្ទះវិញ ។ ដីប្រែទៅធ្វើចំការរាល់ថ្ងៃរហូតដល់ភ្ជួរដីរួចស្រេច ប្រាប់ម្ដាយឲ្យយកគ្រាប់ពោតពូជទៅដាំ លុះពោតដុះលូតលាស់បែកគុម្ពល្អលិចមាន់ហើយ ដីប្រែទៅជម្រះស្មៅពោតរាល់ថ្ងៃ ។

នាងប្រុល នៅជម្រះស្មៅពោតក្នុងចំការព្រំជាប់គ្នា នឹងចំការដីប្រែ ជួនកាលជួយដាំបាយឲ្យដីប្រែផង ហើយឲ្យម្ហូបចំណីដីប្រែជាញយ ៗ ។ អ្នកទាំងពីរស្គាល់គ្នាយ៉ាងជិតស្និទ្ធដូចបងប្អូនបង្កើត ពេលឈប់ជម្រះស្មៅ បរិភោគបាយរួច អង្គុយនិយាយគ្នាលេងពីនេះពីនោះ ក្រោមដើមពំង ខ្យល់បក់មកល្ហើយត្រសៀក ។

នាងប្រុលសួរដីប្រែថា ម៉ែឪបង គាត់រកផ្ទះសំបែងឲ្យបងហើយ ឬនៅ ? ។

ដីប្រែ– ប្អូនកុំសួរពីរឿងនេះ បងមិនចង់ឲ្យព្រួយទេ បងស្មាលា ហើយប្អូន ។ មួយទៀត ប្អូនកុំមកអង្គុយនិយាយលេងជាមួយបងញយៗ ពេក ក្រែងប្ដីសីប្អូនប្រចែប្រច័ណ្ឌនឹងបង ។

នាងប្រុល– ចាស! មិនអីទេ បង! ប្ដីខ្ញុំគាត់បែកស្លាប់ទៅ ជិត ១ ឆ្នាំហើយ តាំងពីអាប្រមក់នេះទើបនឹងកើតបាន ១ ខែ ខ្ញុំមាន តែកូនប្រុស ១ នេះទេ ។

ដីប្រែ– បើដូច្នោះ ប្អូនមិនចង់បានប្ដីសីទៀតទេឬអី គ្រាន់បានជា គ្នាជួយធ្វើការរកស៊ី ។ ដីប្រែនិយាយត្រង់ ៗ តាមស្និទ្ធ គ្មានចិត្តព្រាថា នាងប្រុលបន្តិចសោះ ព្រោះខ្លួនតាំងចិត្តថា លែងយកប្រពន្ធហើយ ។

នាងប្រុល- ចាស! ខ្ញុំមិនយកប្ដីទៀតទេ បង! ខ្ញុំរាងចាលហើយ ធ្វើម្ដេចបានជាជ្រុលខ្លួនទៅយកប្ដី ១ ឆ្នាំបានកូន ១ នេះ ទទួលគាត់បែក

ស្ថានទៅ ឥឡូវខ្ញុំស៊ូទ្រាំធ្វើរបរចិញ្ចឹមខ្លួនតែម្នាក់ឯងទៅចុះ ទំរាំដល់ស្លាប់, នាងប្រុលមាត់ថាម្យ៉ាង ឯចិត្តគិតទៅម្យ៉ាង គិតថា បងប្រែនេះអាយុ ដំណាលប្តីអញដែរ ហើយជាអ្នកចេះដឹងច្រើនផង ទាំងចិត្តថ្លើមក៏ស្លូត ត្រង់ល្អ ល្មមអញទីពឹងបាន ប៉ុន្តែ កុំអាលធ្វើឲ្យគាត់ដឹងខ្លួនថាអញ ស្រឡាញ់គាត់ ។

ដីប្រែ – ជឿពាក្យសំដីនាងប្រុលស្ទុង ស្តាប់ចិត្តឃ្លកថា នាងនេះ មិនចង់បានប្តី ដូចអញមិនចង់បានប្រពន្ធដែរ តាំងពីពេលនោះមកក៏តែ ជឿទុកចិត្តនាងប្រុលលើសពីមុន ៗ ។

កន្លងពីនោះមកពីរបីថ្ងៃ ពេលរសៀលទាប នាងប្រុលឈប់ជម្រះ ស្មៅហៅចៅប្រែទៅអង្គុយលេងលើខ្ទមខ្លួនប្រាប់ថា បងប្រែ! ថ្ងៃនេះ យើងកុំប្រញាប់ទៅផ្ទះពីថ្ងៃពេក យើងនៅឲ្យដល់ព្រលប់ធំចាំទៅ ព្រោះ តែដល់ថ្ងៃលិចហើយ ហ្វូងក្តាន់ចូលមកស៊ីពោតយើងរាល់យប់ យើង នៅចាំដេញផ្កសិន ថាបក្តីដាំបាយបណ្តើរ ។

ចៅប្រែ – ដេកកើយមែកកាំង ១ កំណាត់ លើខ្ទមរបស់នាងប្រុល និយាយគ្នាលេងចាំបាយឆ្អិន ។

នាងប្រុល – និយាយបន្ទុយថា ខ្ញុំគិតថាមិនយកប្តីទេ ប៉ុន្តែ បង ឃើញស្រាប់នឹងភ្នែក មកឯព្រៃបាត់ឯផ្ទះ គ្មានគ្នាជាទីពឹង លំបាកចិត្ត រាល់ថ្ងៃ យប់ដេកតែម្នាក់ឯង ភ័យខ្លាចក្រែងចោរលួចនឹងសត្វប្រមាថ

មើលឆាយ គិតសព្វៗ ទៅមិនគួរនៅម្នាក់ឯងទេ ឈឺចាប់យប់អធ្រាត្រ បានអ្នកណាជួយមើល ដូចបងឯងក្ដី ខ្លួនខ្ញុំក្ដី មកនៅធ្វើចំការក្នុងព្រៃ គោកតែម្នាក់ឯង បើមានទុរៈចុកពោះ ឬពស់ចឹក ឬខ្លាមកកំហែង គេនឹងបានអ្នកណាជួយ នេះកុំបានបងនៅជាមួយគ្រាន់ជាគ្នា កុំអីខ្ញុំក៏ព្រាស្លាប់ក្នុងចំការតែម្នាក់ឯងហើយ ។

ចៅប្រែ – សម្ងំស្ដាប់សំដីនាងប្រុលដល់ត្រង់នេះទន់ចិត្តនឹកអាណិតនាងប្រុលព្រួចៗ ក្នុងពោះឆ្លើយថា មែនហើយ ប្អូន! គួរតែប្អូនយកប្ដីទៀតទៅ កុំនៅម្នាក់ឯងយ៉ាងនេះលំបាកណាស់ តាមបងឃើញសព្វថ្ងៃ បងក៏នឹកអាណិតប្អូនណាស់ដែរ បានជាសុខចិត្តនៅកំដរដល់ព្រលប់ ។

នាងប្រុល – ដឹងថាៈចៅប្រែទន់ចិត្តអាណិតខ្លួនហើយ យល់ថាចិត្តមនុស្សប្រុសស្រីបើអាណិតហើយមុខជាស្រឡាញ់ៗ កើតក្រោយអាណិត ដូច្នេះត្រូវអញធ្វើឲ្យបងប្រែស្រឡាញ់ទៀតនៅពេលនេះ ទាន់បានឱកាសល្អ ទើបនាងឆ្លើយថា លាក់បាំងអី បង! តាមលំបាកសព្វថ្ងៃនេះ នឹកចង់បានប្ដីដែរ ប៉ុន្តែ ខ្លាចក្រែងប៉ះទៅលើប្រុសចិត្តអាក្រក់ប្រសិនបើប្រុសចិត្តល្អដូចបងឯង ខ្ញុំប្រថុយហើយ មាត់តែថា ដៃលូកចាក់ក្រឡៀកចៅប្រែៗ លូកចាក់ក្រឡៀកនាងប្រុល ចាក់ទៅ ចាក់មកជាប់ដៃប្រឡែងគ្នាមួយសន្ទុះ ហត់តែសព្វខ្លួន ប៉ុន្តែ នាងប្រុលមិន

ឲ្យជ្រុលដល់ទីដម្រៅទេ បណ្ដាយតែក្រៅ ៗ ដើម្បីការពារកេរ្តិ៍ស្រី ។

ចៅប្រែ — កើតចិត្តស្រឡាញ់នាងប្រួល ដោយសារសាច់ប្រុស នឹងស្រីប៉ះទង្គិចគ្នា ដូចពាក្យចាស់ទុំលោកថា " ស្ករនឹងស្រមោច, ក្អែកនឹងពងមាន់ " ។ ពេលនេះ ចិត្តចៅប្រែប្លែកពីថ្ងៃមុន ៗ កើតមោហ៍បាំងភ្លេចសំដីរបស់ខ្លួនជាន់ដើមអស់ ច្បាប់ទម្លាប់ដែលធ្លាប់ ចេះដឹងមកក៏រលត់សូន្យ ដូចពាក្យចាស់ទុំលោកថា " ចេះមិនឈ្នះចង់ ត្រង់មិនឈ្នះធាល់ " ចៅប្រែស្ទុះទៅឱបកនាងប្រួលកំពុងដួស បាយជាប់ហើយសួរថា ប្អូនសុខចិត្តយកបងធ្វើប្ដីទេ បើប្អូនសុខចិត្តបង ក៏ព្រមយកប្អូនធ្វើប្រពន្ធដែរ ។

នាងប្រួល — នៅស្ងៀម បណ្ដោយឲ្យចៅប្រែឱបកមួយស្របក់ ទើបឆ្លើយថា បើបងស្រឡាញ់ប្អូនយកធ្វើប្រពន្ធ ប្អូនក៏ព្រមយកបងធ្វើប្ដីដែរ ប៉ុន្តែ ពេលនេះ សូមបងអាណិតខ្ញុំ កុំអាលវីវរអី ចាំបងទៅផ្ទះ ជំរាបម៉ែឪ ឲ្យម៉ែឪមកស្ដីដណ្ដឹងខ្ញុំរៀបសែនព្រេនមេបាចាស់ទុំរួចចាំយើង នៅរួមសុខ-ទុក្ខជាមួយគ្នាកុំឲ្យខុសច្បាប់ ។

អ្នកទាំងពីរបរិភោគបាយលើខ្ទម រួចនាំគ្នាទៅផ្ទះរៀងខ្លួន ៗ ចៅប្រែទៅផ្ទះនៅឃុំកោះរះ ។ ឯនាងប្រួលទៅផ្ទះនៅឃុំថ្ងគ ។

នាងសៅ — ម៉េចក៏បាត់ដល់ថ្ងៃនេះ កូន ! ម្ដាយចេះតែអង្គុយចាំ មើលផ្លូវ ក្រែងជាមិនជា ឯងរួចបាយហើយឬនៅ?

ចៅប្រែ – បាទ! រួចហើយ ម៉ែ ។

នាងសេ – ចុះឯងអាស្រ័យបាយនៅផ្ទះអ្នកណា?

ចៅប្រែ – នៅខ្ទមនាងប្រួល ។ ចេះតែឃាត់ខ្ញុំឲ្យនៅកំដរ ។

នាងសេ – សំឡឹងមើលមុខកូនឃើញប្លែកជាងសព្វថ្ងៃ នឹកសង្ស័យក្នុងចិត្តណាស់ តែមិនសួរដេញដោលតទៅទៀត ខ្លាចក្រែងកូនអៀនខ្មាស ។

ចៅប្រែ – ចូលដេកមិនសុខមិនសាប់សោះ ចេះតែទន្ទឹងឲ្យភ្លឺឆាប់ ព្រោះចិត្តនឹកទៅនាងប្រួលឥតភ្លេច ធ្វើក្អកក្អឺះ ៗ រហូតដល់មាន់រងាវកុះ ទើបលក់ទៅ យល់សប្តិឃើញបានចិញ្ចៀនប្រាក់ ១ វង់ ដាំត្បូងពេជ្រភ្លឺរន្ទាល នឹកត្រេកអរណាស់ទៅ និយាយមមើមមាយស្រែកប្រៀងថា៖

ពាក្យ ៨

ផ្គរលាន់ខែចេត្រកើតហេតុយ៉ាងធំ កង្កែបស្រែកយំលើ
ចុងឈើទាល ក្រពើលង់ទឹកស្លាប់ពាសពេញវាល ទឹកក្តៅ
រោលរាលពេញទាំងសមុទ្រ ។ ចិត្តអញស្អប់ស្រីឥតអ្វីប្រៀប
ឡើយ លុះបានកៀកកើយកើតចិត្តស្រយុត អាល័យរលឹកនឹក
យ៉ាងបំផុត ក្តីស្នេហ៍មកដុតឲ្យខ្ញុំខានដេក ។ ថ្ងៃរះពីឯលិចភ្លឺ
ចិញ្ចែង នឹកកាលប្រឡែងលេងចាក់ក្រឡេក ចាប់ទៅចុបមក
កើតក្តីដម្រេក នាំចិត្តឲ្យត្រេកត្រអាលនឹងស្រី ។

នាងរស់ កំពុងតែអង្គុយនៅកន្ទុយជើងគ្រាន បបរតាំងពីយប់ងងឹត មិនទាន់ភ្លឺ ឲ្យកូនស្រស់ស្រូបព្រឹកព្រហាមមុនទៅចំការ ពុសួរកូនមមើ ច្រៀងយ៉ាងច្បាស់ខំផ្ទៀងស្តាប់យល់ថា ដីប្រែច្បាស់ជាជាប់ចិត្តស្រឡាញ់ស្រីណាហើយ បានជាដេកមមើយ៉ាងនេះ នឹកត្រេកអរណាស់ ចូលទៅដាស់ប្តីក្នុងមុងខ្សឹប ៗ ថា គេហ៍អើយ! ក្រោកឡើងស្តាប់ដីប្រែវាមមើ ៗ

អ្នកកើត - ចុះវាមមើថាម៉េចខ្លះ ?

នាងរស់ – វាថានឹកកាលប្រឡែងនឹងស្រីណាស់ ប្រហែលជាវាទៅដេកជាមួយមេណាហើយ បានជាល្ងាចមិញទាល់យប់ទើបវាមកដល់ផ្ទះ ៗ

អ្នកកើត – ណ្ហើយគេហ៍ ! មេណាក៏ដោយឲ្យតែវាស្រឡាញ់យកធ្វើប្រពន្ធទៅចុះ ព្រោះពីដើមវាស្បថស្បថាលែងយកប្រពន្ធមួយជាតិ អញព្រួយចិត្តនឹងវាណាស់ ឥឡូវបើវាព្រមយក យើងត្រេកអរទៅ ៗ

នាងរស់ – ត្រេកអរម៉េចនឹងរួច គេហ៍ ! បើស្រីមេម៉ាយកូនមួយស្តាប់ប្តី ៗ

អ្នកកើត – យី ! ឯងមិនទាន់ដឹងទេ ! បុរាណថា "មេម៉ាយកូន ១ ល្អលើសក្រមុំ" ព្រោះវាចែកសាច់ឈាមដោយសារត្រូវដីជាតិ ណ្ហើយឯងកុំមាត់គអ៊ីដូចតាស់ទុំថា "កកក៏បាយមេម៉ាយក៏ស្រី" បើវាទៅលើនាងប្រួលមែន សំណាងវាហើយ ដ្បិតនាងប្រួលអញស្គាល់ពូជអម្បូរវាអស់ហើយ

ក៏មានមារយាទល្អណាស់ ទាំងរូបពង់ក៏ល្អមិនចាញ់ស្រី ៗ ឯទៀតទេ ក្រមុំមិនសូវមិនសាចាញ់ក៏ស្រឡះ គ្រាន់តែក៏ទាល់ក្រជាងគេបន្តិចប៉ុណ្ណោះ ផ្ទះប្តីក៏ធ្វើទុកឲ្យស្រាប់ ដីភូមិកេរ្តិ៍ពីម៉ែឪក៏មក ទាំងចំការពោតក៏មានដែរ បើក៏ព្រមយកដីប្រែធ្វើប្តីស្រួលហើយ ដ្បិតចំការពោតព្រំដីជាប់គ្នា យើងឲ្យចំការនោះទៅក៏ចុះ ។

នាងស់ – ស្តាប់ចូលចិត្តនៅស្ងៀម ថយចេញទៅជួបបងដាក់បានឲ្យដីប្រែ ៗ ហុតបងប្អូននិយាយទប្រ ៗ ប្រាប់ម្តាយមិនហ៊ានឲ្យឪពុកឮថា ម៉ែថ្ងៃនេះ ខ្ញុំមិនទៅចំការទេ សូមម៉ែទៅស្តីដណ្តឹងនាងប្រួលឲ្យខ្ញុំ ៗ ពេញចិត្តនាងនេះហើយ បើគេព្រមព្រៀងសូមម៉ែកំណត់ពេលសែនព្រេនមេបាឲ្យគេឆាប់ ៗ ទៅ កុំនៅយូរ ព្រោះពោតយើងឯចំការជិតទុំហើយ ។

នាងស់ – ទទួលថាអើ ! ចាំអញទៅស្តីដណ្តឹងគេឲ្យ តែថប់ក្រែងនាងប្រួលប្រកែក ព្រោះឯងរូបអន់បន្តិច ។ នាងស់ចំអន់កូនលេងលមើលចិត្ត រួចចេញទៅក្រៅដំណាលប្រាប់ប្តីតាមសំដីកូនសព្វគ្រប់ ។

អ្នកកើត – អស់សំណើចឃឹក ៗ លាន់មាត់ថា ពីដើមក៏ស្បថស្បែថាលែងយកប្រពន្ធមួយជាតិ ឥឡូវស្រាប់តែតឿនម៉ែក៏ឲ្យសែនព្រេនឆាប់ ៗ ដ្បិតពោតជិតទុំ ទុំអើ អញដឹងចិត្តក៏ហើយ ។

ហេតុតែចិត្តម៉ែឪមិនប្រកាន់ទំនើងសំដីកូន បណ្តើរគ្នាដើរទៅឯ

ឃុំប្តូគតាំងព្រលឹមអុរ ដល់ផ្ទះនាងប្រុល ឈររេកនៅមុខផ្ទះក្អកគ្រហែមពីរបីដង ។

នាងប្រុលកំពុងរៀបចំដំណើរទៅចំការ ព្រួសស្បូវសំដីនៅមុខផ្ទះ អើតទៅឃើញអ្នកតាំងពីរក៏យល់ហេតុភ្លាម ស្រែកថា អញ្ជើញឡើងមកលោកគ្រូ, មីង ។

អ្នកកើត, នាងរស់ឡើងលើផ្ទះសំពះសួរយាយប្រឹង ( មេម៉ាយអំពីតាប្រឹង ) ជាជីដូននាងប្រុលថា ជម្រាបសួរធំ! ធំសុខសប្បាយជាទេឬអី ?

យាយប្រឹង – អើ! ធំជាទេក្មួយ ! ចុះក្មួយទាំងពីរនាក់មានការអ្វី បានជានាំគ្នាមកផ្ទះធំតាំងព្រហាមស្រាង ៗ យ៉ាងហ្នឹង ប្រាប់ធំឲ្យគ្រាន់មកមើល ។

នាងរស់ – លើកស្លាម្ទូនឹងទំពីរគញ្ចប់ជូនទៅយាយប្រឹងរួចជម្រាបថា សូមទោសធំទៅចុះ លោកចាំងអី មកនេះមានការណ៍បន្តិច ខ្ញុំរកពឹងអ្នកជិតខាងមិនទាន់ មកផ្គាល់ខ្លួនពីរនាក់ក្តីប្រពន្ធកែម្តង សូមធំកុំប្រកែកប្រកាន់ទោសក្មួយចុះ នាងប្រុលនៅជាមេម៉ាយ ឬមួយគេមានថ្លៃហើយ? ដ្បិតដីប្រក្ខនប្រុសច្បងរបស់ខ្ញុំពេញចិត្ត ប្រើខ្ញុំឲ្យមកសាកសួរធំ ។

យាយប្រឹង– មិនអីទេក្មួយ ! ធំមិនប្រកាន់អ្វីទេ ! មីប្រុលនៅមេម៉ាយនៅឡើយ ធំក៏ពេញចិត្តនឹងចៅប្រដៅ ព្រោះធ្លាប់ឃើញមកលេង

ផ្ទះធំញឹកញយ ស្តាប់សំដីសំដៅពជាអ្នកចេះដឹងគួរសម ប៉ុន្តែ ធំមិនហ៊ានអារកាត់ចិត្តម៉ែទៅទេ ចាំសួរវាមើលសិន ។ យាយប្រឹងបែរមុខទៅរកនាងប្រួលសួរថា ម៉េចចិត្តទៅ ៗ ពុស្រាប់ហើយ ស្រេចលើចិត្តទៅចុះ យាយមិនដឹងទេ ព្រោះមានពាក្យចាស់ទុំលោកថា " ក្រមុំជណ្តើផ្កាយ មេម៉ាយជណ្តើចិត្ត " ។ បើតាមយោបល់យាយថា គួរទៅផ្ញើខ្លួនប្រាណទៅលើដីប្រែចុះ ព្រោះខ្លួនឯងកំព្រាឥតម៉ែឪ ហើយដីប្រែគេក៏អ្នកចេះដឹងចិត្តស្លូតបូតល្អផង ។

នាងប្រួល - ខ្ញុំមិនប្រកែកទេ ខ្ញុំយល់ស្របតាមចិត្តយាយហើយ សូមយាយសម្រេចការជាមួយពូកើតមីងសេឲ្យស្រេចទៅចុះ ។

កប់ពីថ្ងៃដែលប្រឹក្សាគ្នាមកបានប្រាំថ្ងៃ គេពុស្បូរក្មេងមង្គលការចៅ-ប្រែនឹងនាងប្រួលពិរោះរងំ ញាតិមិត្រជិតឆ្ងាយបរិភោគបាយទំចំណីដោយរីករាយ និយាយគ្នាពីចិត្តចៅប្រែដែលប្រកែកថា មិនយកប្រពន្ធសោះអស់មួយជីវិត ។

អ្នកកើតទៀតយកឱកាសនេះ ប្រាប់កូនចាំងពីររូបឲ្យចាំកុំភ្លេចអំពើរឿងមនុស្សចិត្តប្រែប្រួល ។

ចប់

រឿងព្រេងចិន

លោក ក៉យ-ប៊ុត ប្រែរៀបរៀង

---

# រឿងព្រេងចិនមាន ៩ យ៉ាងគឺ៖

១ រឿងអស្វកោវិទ "កញ្ចាញ់ចេក" ( Le cavalier Rainette)

២– រឿងសេះឈើ (Le cheval de bois)

៣- រឿងជក់ទិព្វ (Le pinceau ma ique)

៤– រឿងវីរជនម្នាក់នាមសឺកាល (L'histoire du Héros chégal)

៥- រឿងលោកឡៅសាននឹងចៅក្រម (Lao San et le magistrat)

៦– រឿងព្រះនាងម៉ឹងគីយាង-នីយូ (Meng kiang Niu )

៧ រឿងបឹងនៃរុក្ខជាតិអូលីវីយេ (Le lac des Oliviers)

៨ រឿងបែងចំណែក ( Le parlage )

៩– រឿងផ្សេងៗនៃលោកណាស៊ិឌិនអវន្តី (Quelques histoires de Nasrdin Avanti)

ដំបូង, ខ្ញុំនឹងពណ៌នាអំពីរឿងអស្វកោវិទ "កញ្ចាញ់ចេក" (Le cavalier Rainette; រឿងនេះ ជារឿងព្រេងប្រទេសទីបេត៍ ។

១– រឿងអស្វកោវិទ "កញ្ចាញ់ចេក" នៅលើគិរីដ៏មានសភាពខ្ពស់ដាច់សន្ធឹមស្ថិតនៅឆ្ងាយដាច់ស្រយាល, មានជនពីរនាក់ជាស្វាមីភរិយារស់នៅទីនោះ ធ្វើចម្ការមួយដាំអ្វីមិនសូវដុះទេ, ដាំបានតែខ្ពៅ

នឹងដំឡូងបាក់ឆ្អឹងបន្តិចបន្តួច, អ្នកទាំងពីររស់នៅដោយលំបាកពន់ពេក ។

លុះអ្នកទាំងពីររស់នៅជាមួយគ្នាជាយូរឆ្នាំ, ហើយដល់ខ្លួនចាស់ជរា, ក៏មានចិត្តព្រួយឥតឧបមាដោយខ្លួនគ្មានបុត្រធីតាមួយសោះឡើយ ។ ថ្ងៃមួយ អ្នកទាំងពីរក៏ពោលទូរពាក្យថា " ឱ! បើសិនណាជាយើងមានបុត្រម្នាក់ យើងនឹងសប្បាយចិត្តយ៉ាងណាទៅ, បុត្រយើងដល់យើងចាស់ជរា វានឹងករកស៊ីចិញ្ចឹមជួសយើង វាធ្វើការជួសយើងក្នុងពេលកំណែនរបស់ស្តេចត្រាញ់ម្តង ៗ វានឹងទៅកាប់ឧសឯភ្នំជួសយើង ដែលយើងទុព្វលភាពខ្លាំងកោង យើងនឹងអាចសម្រាកកាយសប្បាយចិត្តអាំងភ្លើងនៅគេហដ្ឋាន . . ." ។

មានកាលមួយថ្ងៃ អ្នកទាំងពីរក៏បានទៅបន់ទេវតាក្នុងទន្លេ សូមឲ្យបានបុត្រមួយដូចបំណង, ក្នុងពេលដែលកំពុងបន់នោះ ចិត្តអ្នកទាំងពីរក៏មានចិត្តតួចយ៉ាងខ្លាំងដូចគ្នា, មិនយូរប៉ុន្មាននាងជាភរិយាក៏មានគភ៌ ។ លុះកាលគន្លងមកបាន ៧ ខែ, នាងជាភរិយាក៏ប្រសូតបុត្រ តែមិនមែនទារកដូចធម្មតាទេ, គឺសត្វកញ្ចាញ់ចេកតូច មានភ្នែកធំ ។

ស្វាមីក៏ពោលថា ឱ! នាងគួរឲ្យធុញពេកណាស់, មិនមែនទារកដូចមនុស្សធម្មតាទេ ដែលនាងឯងផ្តល់ទន្លេនេះ គឺកញ្ចាញ់ចេកមានភ្នែកធំ នាងឯងត្រូវតែយកវាទៅចោលឯក្រៅទៅ, កុំទុកឲ្យវានៅទីនេះធ្វើអ្វី ។

នាងជាភរិយាដល់ឮសព្ទពាក្យប្រុសជាប្ដីនាងដូច្នោះ ក៏នឹកក្នុងចិត្តថា :

"ឱ! ទេវតានេះមិនព្រមតាមពាក្យដែលយើងបន់សោះ, ទេវតាលោកឲ្យកញ្ចាញ់ចេកមួយ, មិនមែនទារកដូចមនុស្សជាកំដម្កាទេ ! តែបើទុកជាកញ្ចាញ់ចេកក៏ដោយ ក៏កញ្ចាញ់ចេកនោះកើតពីខ្លួនអញ, មិនត្រូវអញយកទៅបោះចោលទេ ។ សត្វកញ្ចាញ់ចេកតែងរស់នៅក្នុងទឹកត្រពាំង ឥឡូវនេះមានត្រពាំងខាងក្រោយគេហដ្ឋាន, គួរបោះចោលក្នុងទឹកត្រពាំងនេះចុះ ដើម្បីឲ្យវាមានជីវិតរស់នៅបាន" ។

បុរសក៏យកកញ្ចាញ់ចេកនោះ កាន់នឹងដៃចេញពីគេហដ្ឋានទៅ ។ ក្នុងពេលនោះ, កញ្ចាញ់ចេកដែលស្ថិតនៅក្នុងបាតដៃបុរសក៏ពោលថា :

" ឱ! មាតាបិតាអើយ , កុំយកខ្ញុំទៅចោលក្នុងត្រពាំងសោះឡើយ , ខ្ញុំជាកូនមនុស្សជាតិពិតប្រាកដ ចូលទុកខ្ញុំឲ្យរស់នៅជាមួយមនុស្សចុះ, ដល់ខ្ញុំចំរើនវ័យវឌ្ឍនាការពេញរូបរាងពេញ ខ្ញុំនឹងធ្វើភូមិនេះឲ្យបានចំរើនថ្កុំថ្កើនរុងរឿងឡើង, ខ្ញុំនឹងតម្កើងជីវភាពមនុស្សដែលស្ថិតនៅភូមិនេះឲ្យមានឋានៈដ៏ឧត្តុង្គឧត្តមតទៅអនាគត" ។

បុរសក៏ភ្ញាក់ស្មារតីឡើងពោលទៅកាន់ភរិយាថា :

" ឱនាង! ជាការប្លែកណាស់, កញ្ចាញ់ចេកនេះចេះនិយាយ" ។

នាងជាភរិយាក៏តបទៅស្វាមីវិញថា តើកញ្ចាញ់ចេកនេះចេះពោល

ពាក្យពិរោះពិសាណាស់ដែរ ។

ពិតមែនហើយ ជីវភាពនៃមនុស្សដែលស្ថិតនៅទីនេះ ត្រូវតែប្រែកែតាមលំនាំតទៅ បើជីវភាពនេះស្ថិតនៅក្នុងស្ថានការណ៍ដ៏លំបាកដូច្នេះ យើងនឹងទទួលមរណភាពដោយទុក្ខភ័យមិនខាន! កញ្ញាញ៉ែចកដែលចេះពោលពាក្យបែបនេះមិនមែនកញ្ញាញ៉ែចកធម្មតាទេ, យើងត្រូវទុកជីវិតឲ្យកញ្ញាញ៉ែចកនេះរស់នៅជិតយើងចុះ ។

ស្វាមីនឹងភរិយាដែលមានចិត្តប្រកបដោយព្រហ្មវិហារធម៌, ក៏រក្សាកញ្ញាញ៉ែចកនោះទុកជាមួយនឹងខ្លួន ហើយក៏បានជួយឧបត្ថម្ភចិញ្ចឹមបីបាច់ថែរក្សាឲ្យដូចជាកូនមនុស្សដូច្នោះ ។

ដល់បីឆ្នាំកន្លងមក កញ្ញាញ៉ែចកដល់ឃើញស្វាមីនឹងភរិយាធ្វើការលំបាកពន់ពេក, ក៏ពោលពាក្យថា :

"មាតា! ស្អែកសុំលោកមាតាធ្វើនំបុ័ងមួយឲ្យខ្ញុំ ហើយសុំដាក់ទៅក្នុងថង់ ឬ ស្បោងឲ្យខ្ញុំព្រោះខ្ញុំនឹងទៅកាន់ប្រាសាទដែលស្ថិតនៅខាងចុងជ្រោះក្នុងណោះដើម្បីនឹងសូមព្រះនាងព្រះអគ្គធ្វើភរិយា ។ ព្រះអង្គទ្រង់មានព្រះរាជបុត្រីមានរូបឆោមលោមពណ៌ស្រស់ប្រិមប្រិយពអង្គ ។ ខ្ញុំនឹងទៅរកកូនប្រសាស្រីមួយមានសមត្ថភាពគ្រប់គ្រាន់ ល្មមជួយធ្វើការបាន" ។

(នៅមានត)

# ភូមិសាស្ត្រសេដ្ឋកិច្ចប្រទេសជប៉ុន

លោក រ៉ូហ្សមបែរត៍

អតីតសាស្ត្រាចារ្យនៃមហាវិទ្យាល័យច្បាប់ប្រទេសកម្ពុជា

បាននិពន្ធកាលពីឆ្នាំ ១៩៥៩ - ៦០

លោក ញ៉ែម.ចិម ប្រែសម្រួល

(តមក)

---

ដីដែលគេធ្វើការយកផលនោះមានទំហំតូច ៗ ហើយចែកជាកង់ ៗ ។ កាលពីឆ្នាំ ១៩៤៦ សហរដ្ឋអាមេរិកបានតម្រូវឲ្យធ្វើការកែទម្រង់ដីមួយយ៉ាងសំខាន់ ។ ដីទាំងឡាយដែលម្ចាស់ដីមិនបានដាំដំណាំដោយខ្លួនឯងត្រូវរាជការទិញយក ហើយចែកឲ្យទៅអ្នកគ្មានដី តែជាអ្នកធ្លាប់ដាំដំណាំលើដីនោះ ។ សព្វថ្ងៃនេះ ២ ភាគ ៣ (២/៣) នៃប្រជារាស្ត្រជប៉ុនសុទ្ធតែមានដីផ្ទាល់ខ្លួនឯង តែតាមធម្មតាម្នាក់ៗមានដីមិនលើសពី ១ ហិកតាឡើយ ។

ផលិតផលកសិកម្មដែលសំខាន់ៗ — ពាក់កណ្តាលនៃផ្ទៃដីដែលដាំដំណាំបានមានធ្វើសុទ្ធតែស្រូវ ។ ដំណាំស្រូវនេះបានឲ្យផលយ៉ាងច្រើន គឺ ៣៣ កាំងតាល់ (១ កាំងតាល់ ១០០ គីឡូក្រាម) ក្នុងមួយហិកតា ។ ផលនេះបានមកពីការប្រើជីនិងការបូចទឹកបញ្ចូលស្រែ ។ ប្រទេសជប៉ុនជាប្រទេសលេខ ៣ ក្នុងសាកលលោកខាងផលស្រូវ ។ ក្នុងមួយឆ្នាំ ៗ ប្រទេសជប៉ុនធ្វើអង្ករបាន១២ លានតោន

ប៉ុន្តែចំនួននេះក៏មិនគ្រប់គ្រាន់នឹងចិញ្ចឹមប្រជាជនជប៉ុនទេ, ប្រទេសជប៉ុនត្រូវតែទិញស្រូវពីប្រទេសក្រៅថែមទៀត ។

កាលមុនឆ្នាំ ១៩៣៩, ក្នុងប្រទេសជប៉ុនមានការចិញ្ចឹមដង្កូវនាងជាច្រើន, ហើយប្រទេសជប៉ុនជាប្រទេសលេខ ១ ក្នុងសាកលលោកខាងការនាំសូត្រចេញទៅលក់ឯបរទេស ។ ប៉ុន្តែ សូត្រកើតពីធម្មជាតិនេះបានជួបប្រទះនូវការវិបត្តិមួយយ៉ាងខ្លាំង ព្រោះត្រូវការប្រជែងជើងគ្នាជាមួយនឹងព្រៃធ្វើដោយជាតិស្ល (rayonne) នឹងនីឡុង ។ សព្វថ្ងៃនេះសូត្រធម្មជាតិបានថយចំនួន ៥ ដង, ហើយផលិតផលសូត្រ បានចុះពី ៣៣.០០០តោន មក ១០.០០០តោន ។ សូត្រកើតពីដង្កូវនាងនៅមានធ្វើតែនៅកន្លែងត្រង់កណ្តាលកោះហុងដូតែប៉ុណ្ណោះ ។

អំពីដំណាំបន្ទាប់បន្សំ.- ជួនកាលនៅខាងជើង ជួនកាលនៅខាងត្បូងប្រទេសជប៉ុន នៅសិសិរដូវ, គេមានដាំស្រូវសាលី, ស្រូវអាវ៉ែន (សម្រាប់ធ្វើអាហារសេះ), ស័ហ្យ៍, មីយេ ។

ដំណាំសម្រាប់ឧស្សាហកម្មពុំសូវសំខាន់ប៉ុន្មានទេ ។ នៅតំបន់ខាងត្បូងនៃប្រទេសគេមានធ្វើកប្បាស បានផលមិនគ្រប់គ្រាន់នឹងសេចក្តីត្រូវការទេ នឹងដាំដើមតែបានផល ៥០០.០០០ តោនក្នុងមួយឆ្នាំ ។ គេមានការលំបាកនឹងបង្កើនផលខាងកសិកម្មណាស់ ។ មានតែមធ្យោបាយមួយ គឺការបាចទឹកបញ្ចូលទៅលើដីណា ដែលពុំទាន់មានទឹកទេ

ទើបអាចបង្កើនផលិតផលកសិកម្មបាន ។ ប៉ុន្តែការនេះត្រូវចំណាយលុយជាច្រើនដែលពួកជប៉ុនពុំអាចចាត់ចែងការបានភ្លាម ៗ ។

អំពីការនេសាទត្រី.– កាលពីឆ្នាំ ១៩៣៩, ប្រទេសជប៉ុនជាប្រទេសលេខ ១ ខាងរបរត្រី ប៉ុន្តែនាវានេសាទជប៉ុនបានត្រូវខូចខាតជាតំណាក្នុងពេលចម្បាំង ហើយនៅឆ្នាំ ១៩៤៥ ប្រទេសជប៉ុនបរាជ័យត្រូវបាត់បង់ទីប្រជុំកោះជាច្រើនដែលសុទ្ធតែសម្បូរត្រី ។ សព្វថ្ងៃនេះប្រទេសជប៉ុនបានធ្លាក់មកជាប្រទេសទី ២ ក្នុងសាកលលោកខាងផលត្រីបន្ទាប់ពីប្រទេសអង់គ្លេស ។ ក្នុងមួយឆ្នាំ ៗ ប្រទេសជប៉ុនចាប់ត្រីបានចំនួន ៤ លានតោន ។ មានមនុស្សចំនួន ១ លាន ៤ សែននាក់ (១.៤០០.០០០ នាក់) បានប្រកបរបរនេសាទ ហើយប្រជាជនជប៉ុនម្នាក់ ៗ អាស្រ័យត្រីអស់ចំនួន ៣០ គីឡូក្នុងមួយឆ្នាំ ។ ផ្ទុយទៅវិញប្រជាជនជប៉ុនម្នាក់ ៗ អាស្រ័យសាច់អស់តែ ៤ គីឡូក្រោមទេក្នុងមួយឆ្នាំ ។ ត្រីនេសាទបាន មួយចំណែកសម្រាប់ធ្វើជាអាហារ, មួយចំណែកទៀតសម្រាប់ធ្វើជី ។ ការនេសាទដែលបានឲ្យលទ្ធផលល្អនេះ គឺបណ្តាលមកពីឆ្នេរសមុទ្រឥតចុះឥតឡើង ទឹងមកពីសមុទ្រមានត្រីច្រើន ។ ប៉ុន្តែសព្វថ្ងៃនេះ ដោយប្រជាជនជប៉ុនរករបរនេសាទច្រើនពេក, ឆ្នេរសមុទ្រស្ទើរតែនឹងចង់ក្រត្រី ។ ហេតុនេះហើយបានជាប្រជាជាតិជប៉ុនមានចំណងចង់ឲ្យសហភាពសូវៀតអនុញ្ញាតឲ្យប្រជាជនជប៉ុន ចាប់ត្រី

នៅក្នុងទឹកដីតកោះសាក្កាលីនបានផង ។

អ៊ិ ៣ ឧស្សាហកម្ម .— សម្បត្តិធម្មជាតិពុំសូវសម្បូណ៌ទេក្នុងប្រទេសជប៉ុន ។ ឯរោងឧស្សាហកម្មធំៗ ដែលបានកើតមានចំរើនឡើងក្នុងប្រទេសនេះ គឺដោយសារតែការចំរុងធ្វើការនៃប្រជាជនជប៉ុនតែប៉ុណ្ណោះ ។ ឧស្សាហកម្មជប៉ុនមានការប្លែកពីគេត្រង់ថា ឧស្សាហកម្មជាតិមានបែកជារោងជាងតូច ៗ ស្ថិតនៅពាយពាសពេញ, ទោះបីនៅទីជនបទក៏ដោយ ។ រោងការតូចៗ នេះ មួយ ៗ មានកម្មករដប់ប្រាំនាក់ ហើយធ្វើការដើម្បីសហគ្រាសធំៗ, គឺជាអ្នកទទួលការតពីគេ ។ រោងជាងតូច ៗ នេះធ្វើគ្រឿងតែអ្វីមួយយ៉ាងពិតប្រាកដ រួចផ្ញើទៅសហគ្រាសធំដើម្បីធ្វើការតំឡើង ឧបមាដូចជានៅក្នុងរោងឧស្សាហកម្មធ្វើទោចក្រយាន មានរោងជាងតូច ៗ ជាច្រើនធ្វើការសម្រាប់រោងឧស្សាហកម្មធំ គឺមួយធ្វើកង់, មួយធ្វើប្រវ៉ាក់, មួយទៀតធ្វើឈ្នាន់ ។ល។ របស់ទាំងនេះនឹងយកទៅតំឡើងនៅក្នុងសហគ្រាសធំ ។ មធ្យោបាយនេះមានប្រយោជន៍នឹងប្រមូលក្រុមកម្មករនៅស្រុកស្រែ ឲ្យចូលមកជួយដៃធ្វើការជាមួយនឹងរោងចក្រធំ ៗ ហើយកម្មករនៅស្រុកស្រែស៊ីឈ្នួលថោកផង ។ ប៉ុន្តែចំពោះរោងឧស្សាហកម្មណា ដែលត្រូវការសម្ភារៈសំខាន់និងដើមទុនយ៉ាងធំនោះ, ការប្រមូលកម្មករឲ្យបំពេញមុខងារនៅត្រង់កន្លែងតែមួយជាការចាំបាច់ (la concentration) ឧបមាដូចជានៅក្នុងរោងឧស្សាហកម្មស្ម

ដែក, កេនឧស្សាហកម្មធ្វើនាវ, កេនបក្រធ្វើក្រដាស, និងកេនឧស្សាហកម្មគីមីជាដើម ។ ចំពោះឧស្សាហកម្មទាំងនេះ គេអាចហៅថាសហជីពពួកផលិតករដើម្បីតំឡើងថ្លៃទំនិញ (trust) ក៏បាន ដែលជប៉ុនហៅថា ហៃបាត់ស៊ុយ (zaibatsu) ។ សហជីពដែលសំខាន់ជាងគេមានពីរគឺ មីតស៊ុយ (Mitsu) និងមីតស៊ុយប៊ុស៊ី (Mitsubishi) ។

ប៉ុន្តែ នៅពេលដែលប្រទេសជប៉ុនស្ថិតនៅក្រោមការកាន់កាប់នៃសហរដ្ឋអាមេរិក , សហរដ្ឋអាមេរិកបានបាត់វិធានការរំលាយសហជីពពួកផលិតករដើម្បីតំឡើងថ្លៃទំនិញនេះ តែដោយសារសង្គ្រាមត្រជាក់ នយោបាយនេះក៏ត្រូវគេបោះបង់ចោលទៅ ហើយសហជីពពួកផលិតករជប៉ុនដើម្បីតំឡើងថ្លៃទំនិញក៏កើតឡើងវិញដែរ ។

– ប្រភពនៃថាមពល : ប្រទេសជប៉ុនមានដុំលោហធាតុ (gisement) ធ្យូងថ្មតែកន្លែង ប្រកបដោយគុណភាពអន់ ពុំអាចយកមកធ្វើជាកូក (coke) បានទេ (កូកគឺជាឧស្ម័នយកចេញពីធ្យូងសម្រាប់ប្រើការដុតដាច់រលាយលោហធាតុដើម្បីធ្វើដែកថែប) ។ ដុំលោហធាតុនេះ មួយស្ថិតនៅខាងជើងក្យូ-ស្យូ, មួយទៀតនៅខាងត្បូងហុកកៃដូ ។ ផលិតកម្មទាំងអស់បានចំនួន ៤៧ លានតោន ។

ប្រទេសជប៉ុនមានប្រេងកាតបន្តិចបន្តួចដែរ នៅត្រង់ទិសពាយព្យនៃកោះហុងដូ ។ ក្នុងមួយឆ្នាំៗ គេយកប្រេងកាតបានចំនួន ៣៥០.០០០ តោន ។ ចំពោះអគ្គិសនីវិញ, ប្រទេសជប៉ុនសម្បូរណាស់ ។ ស្ទឹងទាំងឡាយមានបណ្ដាយខ្លីៗទេ, ប៉ុន្តែ មានទាំងជំរោតៗ ។ ៩/១០ នៃអគ្គិសនីបានមកពីរោងអគ្គិសនី (hydro électrique) ។ កន្លែងរោងអគ្គិសនីដែលសំខាន់ជាងគេ ហៅថាបឹង ប៊ីវ៉ា (lac Biva) , នៅខាងក្រោយអូសាកា ។

– សម្បត្តិនៃអណ្ដូងរ៉ែ ប្រទេសជប៉ុនមិនសូវសម្បូររ៉ែទេ គឺប្រទេសនេះគ្មានដែកសោះ ប៉ុន្តែ មានស្ពាន់ខ្លះ ( ១០០.០០០ តោន) ។ ផ្ទុយទៅវិញ ប្រទេសថ្ងៃរះសម្បូរខាងស្ពាន់ធ័រ ។ ដូច្នេះ គេសង្កេតឃើញថាតែដើមកូនប្រទេសជប៉ុន ពុំអាចញុំាងប្រទេសនេះឲ្យបង្កើតឧស្សាហកម្មធំៗ បានទេ ។ ប៉ុន្តែ ដោយភ័ព្វល្អ, ប្រទេសជប៉ុនសម្បូរកម្មករធ្វើការណាស់, ហើយកម្មករទាំងនោះសោតជាមនុស្សស្លូត ។ ងាយស្ដីប្រដៅ ហើយស៊ីប្រាក់ឈ្នួលថោកផង ។ អំពើទាំងនេះជាប្រពៃណីរបស់ជាតិគេ ។ ឧទាហរណ៍:ក្រុមកម្មករមួយពួកដែលគួរចង់ដឹង គឺកម្មករដែលធ្វើការក្នុងរោងចក្រវាយនភ័ណ្ឌ (indudrie textile) ។ ៨០ ភាគរយនៃកម្មករដែលធ្វើការក្នុងរោងចក្រនោះសុទ្ធតែជាស្រីកេទ ហើយសុទ្ធតែជាកញ្ញាមានអាយុយ៉ាងតិចត្រឹម ២០ ឆ្នាំ ។ គេជ្រើសរើសកម្មការិនីទាំង

នោះចូលធ្វើការដោយដាច់កិច្ចសន្យាការងារ ហើយនាងកញ្ញាទាំងនោះត្រូវនៅទទួលសំណាក់ក្នុងកន្លែងមួយ ដែលម្ចាស់ឧស្សាហកម្មបានសង់នៅក្បែរកន្លែងធ្វើការនោះ ដើម្បីកុំឲ្យកម្មការិនីទាំងនោះខាតពេលនឹងដើរទៅ-មកធ្វើការ ៗ នៅក្នុងកន្លែងសំណាក់នោះ មានកន្លែងសម្រាប់ទទួលទានដំណេក (dortoir) កន្លែងសម្រាប់ញុំាបាយ ៗ មិនតែប៉ុណ្ណោះ, គេមានទាំងបង្រៀនកម្មការិនីឲ្យចេះវិជ្ជាមេផ្ទះខ្លះទៀតផង ៗ ក្នុងមួយអាទិត្យ កញ្ញាទាំងនោះអាចចេញទៅលេងក្រៅបាន តែចំពោះថ្ងៃខ្លះប៉ុណ្ណោះ ៗ ម្ចាស់ឧស្សាហកម្មឥតបើកប្រាក់ឈ្នួលទាំងនោះ ៗ ប្រាក់ឈ្នួលទាំងនោះគេនឹងបើកឲ្យទាំងអស់នៅពេលណាដែលកិច្ចសន្យាការងារបានផុតលេត់ ទាំងនៅពេលណាដែលនាងកញ្ញាណាមួយត្រូវការឈប់ធ្វើការ ដើម្បីយកគូស្រករ ៗ ដូច្នេះ ប្រាក់ឈ្នួលធ្វើការរបស់នាងចាត់ទុកជាទ្រព្យខាងស្ត្រី (dot) ក្នុងពេលរៀបអាពាហ៍ពិពាហមង្គល ៗ

ឧស្សាហកម្មជប៉ុនប្រកបដោយគ្រឿងប្រដាប់យ៉ាងទំនើប និងរបៀបរៀបចំសម្រាប់ជំនួញយ៉ាងប្រសើរក្រៃលែង ៗ ដូច្នេះ ប្រទេសជប៉ុនមានរោងចក្រធំ ៗ សំខាន់ជាងគេទាំងអស់ក្នុងទ្វីបអាស៊ី ៗ

(នៅមានត)

# អនាគតសមាជទី ៦ នៃពុទ្ធិកសមាគម
# ពិភពលោកនៅក្រុងភ្នំពេញ

សហជីវិន ស៊្រូ. ណែម រៀបរៀង

---

ឆ្នាំទី ១៩៦១ នៃគ្រិស្តសករាជ ដែលត្រូវនឹងឆ្នាំទី ២៥០៤ នៃពុទ្ធសករាជ ជាឆ្នាំដែលប្រទេសកម្ពុជាបានទទួលមហាកិត្តិយសចំពោះមុខសាកលលោក គឺការស្វែងរកសន្តិភាពជូនមាតុប្រទេស ជូនប្រទេសជិតខាង និងជូនសាកលលោក ។ ការដែលសម្តេចព្រះនរោត្តមសីហនុ ជាព្រះប្រមុខរដ្ឋកម្ពុជាដ៏តូចនេះ បានទ្រង់យាងទៅបើកសម័យប្រជុំសន្និសីទនាក្រុងហ្សឺណែវ ស្តីអំពីបញ្ហាលាវ, ការដែលព្រះអង្គបានទាញមហាអំណាចជាគូប្រឆាំងឲ្យចូលមកអង្គុយជិតគ្នា, ការដែលព្រះអង្គបានបង្រួបបង្រួមបងប្អូនលាវនាក្រុងហ្សុយរិច, ការដែលព្រះរាជបញ្ញាញាណបានធ្វើឲ្យភ្លើងសង្គ្រាមនៅលាវ ដែលបំរុងនឹងឆេះឆាប ពលដាលគ្រប់ទិសទី បានរញលត់ទៅវិញ ការទាំងនេះជាព្រឹត្តិការណ៍វិសាមញ្ញមួយនៃប្រវត្តិសាស្ត្រអន្តរជាតិ ។

តែឆ្នាំ ១៩៦១ នេះ គឺពិតជាឆ្នាំដែលប្រទេសកម្ពុជាត្រូវទទួលកិត្តិយសធំមួយផ្សេងទៀត ដោយព្រះមហាករុណាទិគុណ នឹងព្រះរាជូបត្ថម្ភក៏ចំពោះព្រះពុទ្ធសាសនា នៃអង្គសម្តេចព្រះប្រមុខរដ្ឋដែលជាប្រធាននៃសង្គមរាស្ត្រនិយម ។ ព្រះអង្គបានទ្រង់អនុញ្ញាតជាលើកទី ២ ឲ្យធ្វើ

សមាជទី ៦ នៃពុទ្ធិកសមាគម ក្នុងខែវិច្ឆិកាខាងមុខនេះ នៅក្រុងភ្នំពេញ ។ សន្និសីទអន្តរជាតិនេះ ត្រូវរួមប្រជុំប្រទេសដែលកាន់ពុទ្ធនិយម ចំនួនប្រមាណជា ៤១ ប្រទេសគឺ :

១– ប្រទេស អូទ្រីស (Autriche)

២– – អង់គ្លេស (Angleterre)

៣– – អាល្លឺម៉ង់ខាងលិច (Allemagne de l'Ouest)

៤– – អូស្ត្រាលី (Australie)

៥– – ភូមា (Birmanie)

៦– – លង្កា (Ceylan)

៧– – កូរ៉េខាងជើង (Corée du Nord)

៨– – កូរ៉េខាងត្បូង (Corée du sud)

៩– – កាណាដា (Canada)

១០– – ដាណឺម៉ាក (Danemark)

១១– – អេស្តូនី (Estonie)

១២– – បារាំង (France)

១៣– – ហ្វាំងឡង់ (Finlande)

១៤– – ហុងគ្រី (Hongrie)

១៥– – ហុងកុង (Hongkong macao)

១៦- ប្រទេស ឥណ្ឌា (Inde)

១៧- — អ៊ីតាលី (Italie)

១៨- — ឥណ្ឌូណេស៊ី (Indonésie)

១៩- — ហ្វីលីពីន (Philippine)

២០- — ជប៉ុន (Japan)

២១- — លាវ (Laos)

២២- — លីទុយអានី (Lituanie)

២៣- — លិតូនី (Lettonie)

២៤- — ម៉ុងហ្គោលីក្រៅ (Mongolie extérieure)

២៥- — ម៉ុងហ្គោលីក្នុង (Mongolie intérieure)

២៦- — ម៉ាឡេស៊ី (Malaisie)

២៧- — ណេប៉ាល (Népal)

២៨- — ន័រវែស (Norvège)

២៩- — នូវែលហ្សេឡង់ (Nouvelle zélande)

៣០- — ប៉ាគីស្ថាន (Pakistan)

៣១- — ចិនប្រជាមានិត (Chine populaire)

៣២- — ស៊ុយអែត (Suède)

៣៣- — តង់ហ្គានីកា (Tanganyika)

៣៤- ប្រទេសថៃឡង់ដ៍ (Thailande)

៣៥- — ឆេកូស្លូវ៉ាគី (Tchécoslovaquie)

៣៦- — តៃវ៉ាន់ (Taivan)

៣៧- — សហរដ្ឋអាមេរិក (Etats Unis)

៣៨- — សហភាពសូវៀត (U.R.S.S.)

៤៩- — វៀតណាមខាងជើង (Aietnam Nord)

៤០- — វៀតណាមខាងត្បូង (Vietnam Sud)

រាជរដ្ឋាភិបាល ក្រោមព្រះបញ្ជាដ៏ខ្ពង់ខ្ពស់នៃសម្តេចសហជីវិន កំពុងចាត់ចែងរៀបចំសន្និសីទនេះដោយរួសរាន់ ៗ បានតាំងគណៈកម្មាធិការធំមួយ ដែលមានសម្តេចប៉ែន នុត ជាប្រធាន ។ គណៈកម្មាធិការនេះ បានប្រជុំគ្នាធ្វើការជាច្រើនលើកហើយ ក្រោមអធិបតីភាពនៃសហជីវិនទេព-ផន រដ្ឋមន្ត្រីទី ១ ស្តីទី (ដែលពេលសម្តេចជហ្វាក់ឌ៍មិននៅ) ហើយបានតាំងគណៈកម្មការរងជាច្រើន មានមុខការត្រូវប្រតិបត្តិជាច់ ៗ មុខ ៗ

សមាជទី ៦ នេះ នឹងយកសាលសន្និសីទធំនៅមុខព្រះបរមរាជវាំងជាទីប្រជុំ ។ រាជការមានសមត្ថកិច្ចកំពុងសំអិតសំអាងសាលសន្និសីទ គុបតែងទីលានទទ្យានជិតខាង នឹងបំរុងចំណតរថយន្ត ឲ្យជាទីមនោរម្យ ជូនគណៈប្រតិភូទាំងឡាយ ដែលនឹងចូលមកជំនុំ ៗ

យើងជឿជាក់ថា: ក្នុងពិធីដ៏ឧឡារិកខាងមុខនេះបព្វជិតក្តី គ្រហស្ថក្តី

ដែលជាសមាជិកនៃអនាគតសមាជទី ៦ ខាងពុទ្ធសាសនា មុខជានឹងលើកយកនូវបញ្ហាសំខាន់ ៗ ខ្លះមកពិភាក្សារកញែក រិះរកមធ្យោបាយដោះស្រាយជាពុំខាន ។

ព្រះធម៌គោលគឺទសន្សនវិជ្ជាដ៏ខ្ពង់ខ្ពស់ទូលាយ ដែលព្រះសក្យមុនីគោតមបានត្រាស់ទុកមកជាប្រាសាទ ជាមហាប្រាសាទនៃសីលធម៌ ។ យើងយល់ថា ប្រជាជាតិសាកលលោកអាចស្រង់យកពីក្នុងព្រះធម៌នេះដោយអន្លើ ៗ នូវចំណុចខ្លះ ដើម្បីជាមាគ៌ានៃការប្រកបការងារ ជាមាគ៌ានៃការរស់នៅ, ជាមាគ៌ានៃការទាក់ទងរវាងមនុស្សនឹងមនុស្ស, ប្រជាជាតិនឹងប្រជាជាតិ, រដ្ឋនឹងរដ្ឋ ។

ព្រះធម៌នេះ កាលបើយកទៅប្រៀបធៀបនឹងទ្រឹស្តីដទៃ ៗ ឃើញថាមានលក្ខណៈវិសេសវិសាលឥតគណនា, ជាសច្ចធម៌ (ធម៌សំដែងអំពីសេចក្តីពិត) ជាយុត្តិធម៌ (ធម៌សំដែងអំពីសេចក្តីត្រូវ) ប្រសិនបើបានផ្សាយហើយបានជ្រួតជ្រាបគ្រប់ល្អម ព្រះធម៌នៃព្រះសម្មាសម្ពុទ្ធ អាចនឹងកំចាត់បង់ដោយភាគច្រើន នូវចិត្តឃោរឃៅអាក្រក់ឬសព្រាមច្ចិរិយចិត្ត (ចិត្តកំណាញ់សូរទេន) នឹងបង្កើតឲ្យមានពិត ៗ នូវមេត្តាធម៌ករុណាធម៌, មុទិតាធម៌, គោលគឺព្រហ្មវិហារធម៌ ដែលជាលំនៅនៃចិត្តដ៏ប្រសើរ ។

ព្រះធម៌នេះនាំឲ្យវៀរចាកផុតពីសេចក្តីវិនាស ព្រោះលោក អាចសម្លាប់អាត្មានិយមដែលជាមូលដ្ឋាននៃមោហៈ (សេចក្តីវង្វេង) នៃទោសៈ

(សេចក្តីក្តៅក្រហាយមានវិប្បដិសារីជាដើម) នឹងតែងតែជាក្អកនៃភ្លើងរាំង នឹងភ្លើងសង្គ្រាម ។ ប្រទេសលាវ, វៀតណាម, កូរ៉េ, គុយបា, អង់គូឡា, កុងហ្គោ, កូវ៉ែត, អ៊ីរ៉ាក់, រុស្ស៊ី, នឹងសហរដ្ឋអាមេរិក ជាឧទាហរណ៍ស្រាប់ ។

ដោយព្រះពុទ្ធសាសនា ជាសាសនាផ្សាយនូវសេចក្តីកប់អាន, សេចក្តីអាណិត ទៅរកសព្វសត្វ ពុំប្រកាន់ជាន់ថ្នាក់, វណ្ណៈ បក្សពួក ។ ដោយព្រះពុទ្ធសាសនា ជាសាសនាផ្សាយអំណរទៅរកសព្វសត្វ ដែលបានសេចក្តីសុខ-ចំរើន គឺមានអំណរនឹងគេបានសុខ-ចំរើន ។ ព្រះពុទ្ធសាសនាអាចទុកជាមាគ៌ាសំរាប់សាកលលោក ឈានទៅចាប់យកសន្តិភាពបាន ។

អាស្រ័យដោយការយល់បែបនេះហើយ បានជាកាលសម្តេចព្រះប្រមុខរដ្ឋ កំពុងគង់នៅឯក្រុងហ្សឺណែវ មានវិញ្ញូជនបរទេសមួយរូបបានផ្ញើចុតហ្មាយមួយច្បាប់ទៅថ្វាយ សុំឲ្យព្រះអង្គបង្គាប់ទៅមហាប្រទេសទាំងឡាយ ឲ្យទទួលយកគោលនៃពុទ្ធនិយម ដើម្បីដោះស្រាយការវិវាទអន្តរជាតិ នឹងដើម្បីសន្តិភាពនៃពិភពលោក(១) ។

កម្លាំងនៃព្រះពុទ្ធសាសនា ស្ថិតនៅត្រង់ការពុំប្រឆាំងនឹងលទ្ធិ ឬទ្រឹស្តីដទៃទៀតទាំងអស់ ទោះជាចំពោះលទ្ធិមូលធននិយម ក៏ដូចជាចំពោះលទ្ធិសង្គមនិយម ឬ រួមសម្បត្តិនិយមដែរ ។ ហើយជាពិសេស

---

១– សូមរង់ចាំអានចុតហ្មាយនេះ នៅលេខក្រោយ ។

ពុំដំណាស់នឹងសេចក្ដីចំរើននៃលោកឡើយ ព្រោះព្រះធម៌ជាគ្រឿងអប់រំបញ្ញា, អប់រំចិត្ត (Développement de l'Intelligence, éducatoin de la volonté) ។ កាលណាបញ្ញាបានចំរើន, ចិត្តមានកម្លាំងបរិបូណ៌ ចិត្តនឹងនុះបានឈ្នះលើរូបកាយ, លើតណ្ហាហើយ (Discipliner la volonté) បញ្ញានឹងចិត្តនោះ ធ្វើឲ្យមនុស្ស ឲ្យលោកទទួលសេចក្ដីចំរើន ទទួលសុភមង្គលដូចប្រាថ្នាពុំខាន ។

ដូចអស់លោកបានជ្រាបស្រាប់ ព្រះពុទ្ធសាសនាជាទ្រឹស្ដីជាទស្សនវិជ្ជា ល្អប្រពៃយ៉ាងនេះក៏ដោយ . នៅតែបានទទួលស្គាល់បរាជ័យ បានស្គាល់សេចក្ដីវិនាសដ៏ធ្ងន់ធ្ងរជាទីបំផុត ក្នុងដំណើរវេងកាត់សតវត្សរ៍ទាំងឡាយ ដែលកន្លងទៅហើយនេះ ។ អ្នកទស្សនវិទូជាច្រើន បានរិះរក ហើយបានចង្អុលបង្ហាញនូវដើមហេតុដ៏ច្បាស់លាស់នៃបរាជ័យនេះ ។ យើងសូមលើកយកតែហេតុខ្លះ មកជូនអស់លោកជាពុទ្ធមាមកជន ទុកជាទីពិចារណាផ្ទាល់ ៗ តទៅ ។

ហេតុធំបំផុត ដែលនាំឲ្យព្រះពុទ្ធសាសនាក្ស័យរៀវខ្លាតចេញអំពីប្រទេសឥណ្ឌាដែលជាប្រទេសកំណើតក្ដី ដែលនាំឲ្យពុទ្ធនិយមពុំបានលូតលាស់ទាន់កាលសម័យក្ដី ក្នុងពិភពលោកក្ដី មានពីរយ៉ាង :

១ ការជ្រៀតជ្រែកនៃវត្ថុធាតុផ្សេង ៗ (Subversion d'éléments divers ) ។

២ ការខ្វះការរៀបចំ ខ្វះសហការ (Manque d'organisation, manque de coopération) ។

ក)- ការជ្រៀតជ្រែកនៃវត្ថុធាតុផ្សេង ៗ តាមប្រវត្តិសាស្ត្រនៃព្រះពុទ្ធសាសនា ដែលត្រូវបានខ្ចាត់ខ្ចាត់ចេញពីប្រទេសឥណ្ឌា មានដើមហេតុមកពីការជ្រៀតជ្រែកនៃជនបរទេស ។ ជនទាំងនេះ ដែលមានជោគជ័យ បានចូលមកកាត់ក្បាលជំរះជាន់ប្រទេសឥណ្ឌា បានបង្ខំឲ្យអ្នកស្រុកយកអារ្យធម៌តាមខ្លួន ឲ្យបោះបង់ព្រះពុទ្ធសាសនា ទៅប្រតិបត្តិតាមជំនឿខ្លួនវិញ ។ ជនបរទេសនេះ តែងខំយករបស់ស្រួយគ្រប់បែបយ៉ាងដើម្បីបំប៉នចិត្ត-គំនិតអ្នកស្រុក ឲ្យប្រែប្រួលឃ្លាតឆ្ងាយពីមាគ៌ាដ៏ប្រពៃ ដែលខ្លួនធ្លាប់ដើររៀងមក ។ ចំពោះការជ្រៀតជ្រែកនេះ ខេមរពុទ្ធសាសនិកជនយើងគឺគួរប្រមើលមើលយ៉ាងហ្មត់ចត់ ។ ការប្រើប្រាស់គ្រប់បែបយ៉ាងពុំមែនជាការលើស, ពុំមែនជាការឥតប្រយោជន៍ ឬ នាំឲ្យខូចប្រយោជន៍ណាឡើយ ។ ការប្រហែសធ្វេស, ការទុកចិត្តហួសប្រមាណ នឹងនាំមកនូវគ្រោះថ្នាក់ នូវសេចក្ដីវិនាស (Le trop de confiance attire le danger) ។

មាត្រា ៨ នៃរដ្ឋធម្មនុញ្ញព្រះរាជអាណាចក្រយើង បានចែងថា .

សេរីភាពខាងជំនឿត្រូវបើកឲ្យមានបរិបូណ៌ ។ សេរីភាពក្នុងការប្រតិបត្តិខាងផ្លូវសាសនា ក៏ត្រូវបើកឲ្យមានដូច្នេះដែរ បើនឹងបទុយខ្វះបាន

តែត្រង់ណាដែលនៅពុំបាន ដើម្បីកុំឲ្យខូចសេចក្ដីស្ងប់រៀបរយ ដល់មហាជន ។

ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ; ប្រែជាភាសាបារាំងថា :

«La liberté de conscience est absolue. Il en est de même que pour celle des cultes qui ne subit d'autres restrictions que celle qui sont nécessaires pour que l'ordre puplic ne puisse être troublé.

Le bouddhisme est la religion de l'Etat»

បើយើងយកអត្ថបទនៃមាត្រានេះមកត្រិះរិះមើល ក៏យើងនឹងយល់មិនខាន ។

ប្រទេសកម្ពុជាយើង ជាប្រទេសដែលមានអធ្យាស្រ័យល្អជិតពេក ព្រោះការដែលតាំងព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ ក៏គប្បីផ្ដល់ចំ-ពោះសាសនានេះនូវបុព្វសិទ្ធិនានាជាអតិបរមា មានបង្ខំខាងផ្លូវជំនឿជាដើមៗ យើងបានឃើញពិតថា ទោះជាប្រជាពលរដ្ឋភាគច្រើន បើមែនទែនសឹងទាំងអស់ (លើកលែងតែបងប្អូនដែលកាន់ខាងសាសនាឥស្លាមនឹងសាសនាកាតូលិក) ដោយមានព្រះមហាក្សត្រជាប្រមុខ ស្រឡាញ់នឹងគោ-រពជំនឿនេះយ៉ាងណាក៏ដោយ ក៏ខ្មែរពុំបង្ខំឲ្យខ្មែរកាន់តាម ឬឲ្យជនបរទេសអ្នកដទៃសោយសាសន៍ ស្រឡាញ់គោរពព្រះពុទ្ធសាសនាតាមឡើយ ។ ទុកសេរីភាពបរិបូណ៌ ខាងផ្នែកជំនឿនេះ ( អ្នកណាចង់ជឿក៏ជឿទៅ ) ហើយអនុញ្ញាតឲ្យប្រតិបត្តិខាងផ្លូវសាសនា ដ៏បរិបូណ៌ថែមទៀត ។

ហើយជាពិសេសបំផុត ដែលបង្ហាញនូវការពុំប្រកាន់ដ៏បរិសុទ្ធរបស់យើង ពិតមែនតែរដ្ឋធម្មនុញ្ញបានបង្អួលអំពីលក្ខណៈនៃព្រះពុទ្ធសាសនា ក៏ប្រជា-ជាតិយើងពុំដែលយកផ្លូវជំនឿជាគោលក្នុងការតែងតាំងវរជន ឲ្យកាន់មុខតំណែង ឲ្យកាន់អគ្គការធំរបស់រដ្ឋឡើយ ។

ការដែលយើងធ្វើល្អដាំងនេះ ពុំប្រាថ្នាអ្វីក្រៅពីការស្វែងរកសេចក្ដីសុខដុមជនរមជាតិរបស់យើង ដូនជនានុជន ដែលចូលមកជ្រកកោនក្រោមម្លប់ព្រះបារមីនៃព្រះមហាក្សត្រយើង ។ យើងពុំប្រាថ្នាជ្រៀតជ្រែកក្នុងជំនឿអ្នកដទៃ តែយើងពុំត្រូវការឲ្យអ្នកដទៃជ្រៀតជ្រែកក្នុងជំនឿរបស់ជាតិយើងដែរ ។

មិនមែនដូច្នោះទេ ក្នុងបច្ចុប្បន្នកាលនេះ ពុទ្ធសាសនិកខ្មែរដែលបានពិចារណាក្នុងបញ្ហានេះ មានសេចក្ដីបារម្ភជាច្រើនចំពោះដំណើរឯកភាពនៃសាសនារបស់ជាតិ (Unité de religion) ។ ឯកភាពដ៏វិសេសនេះដែលជាកេរ្តិ៍មតិករបស់បុព្វបុរសនៃយើង ជាគ្រឹះមួយក្នុងចំណោមគ្រឹះទាំងឡាយដែលបានទ្រទ្រង់ និងទ្រទ្រង់តទៅនូវជាតិមាតុប្រទេស ពុំឲ្យសាបសូន្យ ។ ការបារម្ភនេះកើតមកដោយបានសង្កេតសកម្មភាពខ្លាំងនៃអ្នកដឹកនាំសាសនាផ្សេង ៗ ហើយសកម្មភាពនេះមានសភាពកាន់តែប្លែក ៗ ឡើង ចាប់តាំងពីការឃោសនាតាមគ្រប់ច្រកល្ហកនៃជនបទ មានតាំងចូលដល់ទីវត្តអារាមព្រះសង្ឃពុទ្ធសាសនិកជនក៏មាន ដោយប្រើមធ្យោបាយ

ផ្សេង ៗ មានប្រើពាក្យខ្មែរ ប្រើឃោសនស័ព្ទ ការបញ្ចៀងការពា-យន្តអំពីសាសនា រហូតដល់ការដឹកនាំទង់ទាញយុវជន ដែលជាយុវជនអនាគតខ្មែរដោយហេស្យាបាយគ្រប់បែបយ៉ាង ៗ សាសនិកជនខ្លះបេះភាសាខ្មែរយើងស្អាតជំនាញណាស់ បានឆ្លើយថា ខ្លួនស្រឡាញ់ខ្មែរពិតអាណិតខ្មែរណាស់ បានជាជំនួយដឹកនាំខ្មែរខាងផ្សាយជំនឿ ឲ្យបានស្គាល់ខ្លឹមសារនៃ “អេវ៉ង់ហ្សីល” ឬនៃ “ប៊ិប” របស់ព្រះយេស៊ូ ឬដើម្បីឲ្យព្រះអាទិទេពដែលមានមហិទ្ធិឫទ្ធិបង្កបង្កើតលោក គាបស្រោបស្រង់ខ្មែរបានផង ហើយអ្នកសាសនិកនេះបញ្ជាក់ថា គ្រាន់តែបញ្ចុះបញ្ចូលឲ្យជឿទេតើ ពុំមែនធ្វើនយោបាយទេ ។

យើងពុំចាំបាច់អធិប្បាយទេ អំពីលក្ខណៈយ៉ាងណា បានហៅថាធ្វើនយោបាយ ឬក៏ពុំធ្វើនយោបាយ ៗ ម្យ៉ាងទៀត យើងក៏ពុំវែកញែកឲ្យវែងឆ្ងាយទៅទៀតទេ អំពីសកម្មភាពហួសអំណាចច្បាប់នៃបេសក-សាសនិកជនបរទេសទាំងនោះ ។

## ការខ្វះការរៀបចំ

ព្រះធម៌ជាវត្ថុដ៏មានថែងល្អិតល្អន់ក្រៃលែង តែនៅខ្វះរបៀបរៀបរយខាងការប្រតិបត្តិ ខាងការតាក់តាំងឲ្យមានរបៀបក្នុងពិភពលោកទៀង ៗ នគរ ប្រជាជាតិដែលកាន់ព្រះពុទ្ធសាសនានីមួយ ៗ មានអធិ-បតេយ្យដាច់ ៗ ពីគ្នា ពុំមានចំណង ហើយពុំប្រកបសកម្មភាពក្នុងការ

ផ្សាយព្រះធម៌ឲ្យសមល្មមសោះ ។

ចុះពុទ្ធិកសមាគមពិភពលោក មិនគឺអង្គការដែលរៀបចំមកដើម្បីឲ្យមានការរៀបរយ មានចំណងមានប្រកបសកម្មភាពស្របៗ គ្នានេះហើយ តើម្តេចក៏ថាគ្មានទៀត ? ការពិតពុទ្ធិកសមាគមនេះក៏ដោយ ដែលនឹងមកហាក់រៀបចំផ្តើមមហាសន្និបាតនៅក្រុងភ្នំពេញថ្ងៃមុខនេះ ក៏ពុំមានការចាត់តាំងរៀបចំឲ្យបានហ្មត់ចត់ មានការទាក់ទងរវាងគ្នានឹងគ្នា ឲ្យហូរហែ មានសកម្មភាពយ៉ាងណា ៗ នោះ ក៏ទេដែរ ។

អាស្រ័យដោយហេតុដែលយើងបានរៀបរាប់មក យើងថ្លែងសេចក្តីសង្ឃឹមយ៉ាងមុតមាំចំពោះសមាជទី ៦ ជាសាកលនៃពុទ្ធសាសនានេះថា មុខជានឹងសម្រេចដោះស្រាយបញ្ហាសំខាន់ ៗ ណាមួយពុំខាន ហើយយើងសូមជូនពរសព្ទសាធុការឲ្យសមាជសាកលនេះ ទទួលនូវជោគជ័យជាអតិបរមា ដើម្បីសេចក្តីចំរើននៃមនុស្សជាតិ ។

# រុក្ខជាតិល្ហុង នឹងអំពៅ

ដោយភិក្ខុ ហ៊ាប់-ងិល

សិស្សប្រឡងថ្នាក់ទី ៣ (ក) នៃពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រឹត

(ប្រឡងជាប់លេខ ២ ខាងរំទៀបទម្លាក់)

---

## រុក្ខជាតិល្ហុង

តាមការសង្កេតមើលនូវរុក្ខជាតិល្ហុង ដែលមានដុះនៅវត្តពោធិវង្ស (បុងពែ) ឃុំសៀងហ្វា ស្រុកបូវថាញ់ (សម្តេច) ខេត្តព្រះត្រពាំង នឹងបានពិនិត្យមើលនូវចម្ការដាំល្ហុងធំៗឯទៀត ព្រមទាំងធ្លាប់បានមើលឯកសារខ្លះទៀត ឃើញថា :

ល្ហុងជារុក្ខជាតិមួយមានសភាពទន់ ហើយដើមគ្មានមែកខ្នែងសាខា ដើមមូលវែងមានភាពមិនរាបស្មើ នៅខាងក្នុងដើមមានប្រហោង នៅខាងចុងមានស្លឹកដុះចេញជាកញ្ចុំធំៗ, ស្លឹកមួយ ៗ មានប្រវែងប្រហែល ៣០ សម ទទឹងប្រហែល ១៥ សម មានផ្កាទាំងល្ហុងឈ្មោលទាំងញី ផ្កាញីមានពងផ្នែកដូចផ្សិត ហើយមានខ្នាតធំៗ ។ ផ្កាឈ្មោលមានខ្នាតតូចជាងផ្កាញី ហើយទងវែងសំយុងចុះទៅក្រោម ។ ផ្កាកែមានស្រទាប់ពណ៌ស៊ីទួន ហើយកេសរលឿង ។ ដើមល្ហុងឈ្មោលឥតមានផ្លែទេ តែបើកាលដើមនៅតូច គេកាត់ចុងចោលម្តង ខ្លះហៅថាក្រៀវល្ហុង

ចំពោះល្ហុងឈ្មោលក៏មានផ្លែដែរ តែផ្លែតូចៗ ភ្ជាប់នឹងទងផ្កាជាបផ្កោមៗ ហើយផ្លែមូលៗ ដូចផ្លែត្របែក ផ្លែនេះគេមិនសូវប្រើការទេ ។ ជួនកាលនៅដើមជាមួយគ្នានេះ មានទាំងផ្លែឈ្មោលមានទាំងផ្លែញីផង ។ ផ្កាធ្លាក់កេសរចេញ បណ្ដាលបានជាផ្លែ ។ ផ្លែល្ហុងមានខ្នាតតូច-ធំ តាមពូជរបស់វា ។ ល្ហុងមានពូជច្រើនណាស់ ពូជខ្លះផ្លែវែង ខ្លះផ្លែខ្លី ខ្លះទៀតធំមូល ដូចជាល្ហុងមួយបែបដែលមានដុះនៅវត្តពោធិវង្ស (កម្ពុជាក្រោម) មានទំហំប៉ុនក្អានទឹក ។ ល្ហុងនេះគេហៅថា ល្ហុងបៀនហ្វា ពីព្រោះគេយកពូជមកពីខេត្តបៀនហ្វា នៅខាងលើក្រុងព្រៃនគរ ។ ព្រះតេជព្រះគុណវត្តនេះ កាលបើផ្លែល្ហុងទុំ តែងឲ្យក្មេងដាក់អង្រែក ដើម្បីរែកទៅប្រគេនចៅអធិការគ្រប់តែវត្តនៅក្នុងឃុំនោះ គឺល្ហុងមួយប្រគេនមួយវត្ត អាចឲ្យលោកឆាន់បាន ៧-៨ អង្គ ។

ល្ហុងនេះ កាលពីឆ្នាំ ១៩៥៦ ព្រះតេជព្រះគុណវត្តនេះ ឲ្យមេឃុំយកទៅតាំងពិពណ៌សេដ្ឋកិច្ច នៅខេត្តព្រះត្រពាំង បានជាប់លេខ ២ ។ មិនយូរប៉ុន្មាន មានល្បីល្បាញកេរ្តិ៍ឈ្មោះល្ហុងវត្តនេះ បណ្ដាលឲ្យអ្នកស្រុកជិតខាងមកសុំពូជយកទៅដាំ តែអ្នកខ្លះយកទៅដាំប៉ះនឹងដីដែលគ្មានដីជាតិ ក៏ត្រូវងាប់អស់ ខ្លះយកទៅដាំនៅលើដីមានដីជាតិល្អ នឹងប៉ះខ្យល់អាកាសច្រើនក៏បានដុះល្អឡើង ។

របៀបដាំល្ហុង — ល្ហុងជារុក្ខជាតិចូលចិត្តដុះនៅទីដីណាដែល

មានដីធូរទូលាយនិងខ្សាច់ផង និងដុះតាមជើងភ្នំ ឬបរិវេណទាប ដែលទឹកលិចមិនដល់ ហើយដីនោះស្អិតបន្តិច ។ ផង ព្រោះពូជល្ពៅមិនសូវត្រាំនឹងទឹកលិចទេ បើយើងដាំឲ្យទឹកលិច ឬ ដីមានទឹកលិចជោគជាំ ល្ពៅច្រើនតែត្រូវខ្យល់បក់លើដីគល់ ពុំនោះទេញារៀវស្រពោនមិនល្អឡើយ ។

ល្ពៅត្រូវដាំរើសរកចំការណា ដែលមានដីធូរ និងដីមានជាតិអាសូត (Azote) ច្រើនផង ពុំនោះទឹងដាក់ជីលាមកគោក្របីក៏បាន ។ ធ្វើដូច្នេះ ល្ពៅអាចផ្តល់ផ្លែមកបានធំ ៗ ល្អ ហើយមានរសជាតិផ្អែមផង ។

ល្ពៅគេច្រើនដាំនៅរដូវមានភ្លៀងជាដំបូង គឺជាខែឧសភា, មិថុនា, កក្កដា. ។ គេដាំល្ពៅគ្រាប់ គឺគេយកគ្រាប់ទៅបណ្តុះ កូនឲ្យបានកំពស់ប្រវែង ២០ ស ម-ឬ ១ ចំអាម ទើបគេដកយកទៅដាំនៅក្នុងចំការ ។ ធ្វើដូច្នេះ ជាការពិបាកណាស់ ព្រោះបើចំការធំ ១ ដល់ទៅ ៣-៤ គីឡូ-ម៉ែត្រធ្វើមិនងាយហើយទេ ។ ត្រូវយកគ្រាប់ទៅព្រោះក្នុងចំការវិញជាការងាយជាង ។ ការយកគ្រាប់នេះ គេអាចយកបានតាំងគ្រាប់ស្រស់តាំងគ្រាប់ស្ងួត ។ នៅក្នុងចំការ គេជីករណ្តៅប្រវែង ៣ ម៉ែត្រ ពីមួយទៅមួយ រួចគេដាក់គ្រាប់ ៤ ឬ ៦ គ្រាប់ទៅក្នុងរណ្តៅ ប្រយោជន៍ការ-ពារ ក្រែងត្រូវល្ពៅឈ្មោល គេនឹងដកចោលវិញ ។ នៅគ្រប់តែរណ្តៅ ត្រូវឲ្យមានទឹកសើមជានិច្ច ទំរាំកូនល្ពៅទាក់ឫសបានស្រួលបួល

សិន ៗ នៅដីណាមានដីជាតិល្អ ល្ហុងអាចផ្តល់ផ្លែក្នុងរវាង ៦ ខែ ឬ ៨ ខែប៉ុណ្ណោះ ៗ

ផលប្រយោជន៍នៃល្ហុង -- ផ្លែល្ហុងជាផ្លែឈើម្យ៉ាងមានវីតាមីន (vitamine) គេយកអាស្រ័យបានទាំងខ្ចី ទាំងចាស់ ទាំងទុំទៀតផង ។ ផ្លែនៅខ្ចីគេយកទៅស្លកកូរ ស្លបង់ប្រអួល-ស្លកគ្រឿងម្ទេស អាស្រ័យសម្លនេះទៅធ្វើឲ្យបេញញើសស្រួលខ្លួន ទាំងចេញទឹកនោមផង ៗ ផ្លែចាស់ ៗ ល្មមយកទៅចិតជាបន្ទះ ៗ ស្រុសហើយផ្សំនឹងទឹកជ្រលក់ ឬយកទៅកោសជាចំរៀកតូច ៗ ប្រឡាក់នឹងសាច់បង្គារ ឬ កំពឹស ៗ ផ្លែល្ហុងទុំគេយកទៅបរិភោគនៅពេលបាយរួច ឬដាក់ត្រាំនឹងទឹកកក បរិភោគទៅឲ្យឆាប់រំលួយអាហារ ទាំងមានវីតាមីនទៀតផង ៗ ឯផ្កាល្ហុងឈ្មោលក៏គេមិនបោលដែរ គេបេះផ្កានេះ យកទៅស្រុសឲ្យស្រពោនដើម្បីបញ្ចេញជាតិល្វីង រួចគេរកទឹកគ្រឿងមកផ្សំនឹងវា បង្កើតបានជាម្ហូប ១ មុខថ្មីទៀតទទួលទានជាមួយបាយ ដើម្បីដោះទាល់ពេលគ្រាក្រម្ហូបម្ហូល ៗ

ផលប្រយោជន៍នៃដើមល្ហុង -- តាមសេចក្តីដំណាលថា : នៅសម័យបុរាណ ពួកខ្លះយកជ័រល្ហុងបោកគក់ខោអាវជំនួសសាប៊ូ ព្រោះល្ហុងជាវុក្ខជាតិមានជ័រច្រើន ៗ

នៅសម័យបច្ចុប្បន្ន ពួកបច្ចេកទេសពិសោធមើលដឹងថា ល្ហុងជាវត្ថុធាតុមានប្រយោជន៍សំខាន់ណាស់ ៗ ទឹក ឬ ជ័រល្ហុង អាចជួយបំផ្លាញ

ព្រួនទៅក្នុងពោះយើងបាន ។ បើកាលណាគេត្រូវការស្ងោរសាច់ឲ្យបានផុយឆាប់ គេត្រូវដាក់ជ័រនេះបន្តិចទៅ ទើបសាច់ឆាប់ផុយល្ហួយ ។

**របៀបយកជ័រល្ហុង** ... ដើម្បីយកជ័រល្ហុងឲ្យបានស្រួលល្អ មិនឲ្យខូចផ្លែ យើងត្រូវទុកផ្លែឲ្យធំសិន ហើយយើងត្រូវឆូតផ្លែណាដែលចាស់គួរសមហើយ ។ តែកុំឲ្យចាស់ហួសពេកដែរ ព្រោះកាលបើចាស់ហួសពេក ល្ហុងនឹងផ្តល់ជ័រមិនបានល្អ ។ ជ័រកាលណាយើងយកទៅអប់ នឹងមានពណ៌ដូចស្ករត្នោតហើយស្ងួត យើងនឹងលក់ទៅមិនបានថ្លៃផង ។ បើយើងឆូតផ្លែចាស់ល្មមនោះ យើងនឹងបានទទួលនូវជ័រដ៏ល្អៗ ។ វិធីយកជ័រនេះ តាមឯកសារខ្លះប្រាប់ថា ត្រូវយកបន្ទះឫស្សី ធ្វើមុខឲ្យមុតទាំងសងខាងដូចកាំបិតយកទៅឆូតផ្លែល្ហុង មិនត្រូវយកប្រដាប់អ្វីដែលធ្វើអំពីលោហធាតុទេ ព្រោះលោហធាតុទាំងនេះ ធ្វើឲ្យជ័រមានពណ៌ខ្មៅ, ជាពិសេសជ័រល្ហុងកាលបើប៉ះនឹងលោហធាតុ ធ្វើឲ្យលោហធាតុមានច្រែះ ។

ការយកជ័រឲ្យបានល្អ គេមិនត្រូវឆូតឲ្យជ្រៅពេកទេ ពីព្រោះកាលបើប៉ះដល់សាច់ល្ហុង បណ្តាលឲ្យជ័រមានពណ៌ខ្មៅ ត្រូវឆូតផ្លែល្ហុងពីលើចុះមកក្រោមធ្វើឲ្យស្រាលដៃ កុំឲ្យប៉ះនឹងសាច់វា ។ ជ័រចេញហើយគេត្រូវយកបំពង់ឫស្សី ឬ ចានទៅត្រងពីក្រោម ដូចជារបៀបយកជ័រកៅស៊ូដែរ ។ តែប្រយ័ត្នកុំឲ្យធូលី ឬ សម្រាមចូលឲ្យសោះ វានាំឲ្យខូចគុណភាពជ័រ ។

របៀបឆូតយកជ័រនេះ គេត្រូវធ្វើនៅពេលព្រឹកចាប់តាំងពីម៉ោង ៦ ដល់ម៉ោង ៩ ឬ ១០ ព្រោះពេលព្រឹកត្រជាក់ បណ្ដាលឲ្យមានជ័រច្រើន ឬបើផ្លូវកៀនជ័ររឹតតែចេញច្រើនណាស់ទៀត ។

ការយកជ័រទៅប្រើការផ្សេងៗ.— ជ័រល្ហុងដែលបានមកនេះ គេយកទៅចាក់លើកញ្ចក់ រួចកៀសឲ្យរាបស្មើតាមផ្ទៃកញ្ចក់ ធ្វើឲ្យមានកម្រាស់ប្រហែល ១សម ៥០ ។ កញ្ចក់នេះ ត្រូវជូតឲ្យស្អាតជានិច្ច មុននឹងយកទៅប្រើការ ។

ការធ្វើឲ្យមានផ្ទៃរាបស្មើ ៗ តាមកញ្ចក់នេះ ប្រយោជន៍ដល់ពេលយកជ័រទៅហាលថ្ងៃ ឬអប់ធ្វើឲ្យជ័រស្ងួតព្រមគ្នា ។ កាលបើធ្វើដូច្នេះបាន ហើយត្រូវយកទៅដាក់សំដិលខ្យល់ ២ ឬ ៣ ថ្ងៃ ទើបជ័របានស្ងួតល្អ ។ បើគេប្រើដោយឆ្នាំងអប់វិញ ជ័រនឹងអាចស្ងួតបានយ៉ាងឆាប់ រវាង ៦ ឬ ៧ ម៉ោងប៉ុណ្ណោះ ហើយផ្ដល់ជ័រមកបានសល្អផង ។

ម្យ៉ាងទៀត នៅពេលយកជ័រចេញពីកញ្ចក់ ត្រូវពាក់ស្រោមដៃ ការពារកុំឲ្យជ័រកាត់ដៃ ។ ដើម្បីទុកជ័រនេះ ឲ្យបានយូរឆ្នាំ ត្រូវយកជ័រនេះ ទៅដាក់ក្នុងបំពង់ ឬកែវបិទឲ្យជិត កុំឲ្យខ្យល់ចូលបាន ។ ធ្វើដូច្នេះ អាចទុកបាន ៣ ឬ ៤ ឆ្នាំ ។

· ជ័រល្ហុងនេះ គេទុកយកទៅប្រកបការធ្វើថ្នាំផ្សេងៗ ដូចជាថ្នាំព្រូនក្នុងពោះវៀនជាដើម ។ ចប់ រុក្ខជាតិល្ហុង

(នៅមានត)

# ផ្នែកកំណត់ និង ប្រវត្តិការណ៍

## សេចក្តីរាយការណ៍សង្ខេប

ស្តីអំពីសន្និសីទសាកលលោកនៃអ្នកកាន់សាសនាទាំងឡាយ ដើម្បីសន្តិភាព
ដែលបានធ្វើនៅក្រុង ក្យូតូ (ប្រទេសជប៉ុន) ពីថ្ងៃ២៥-៧-៦១ ទៅទល់នឹងថ្ងៃ ២៨.៧.៦១
និងអំពីបូជនីយសចរណ៍កាត់តាមប្រទេសជប៉ុន

លោក ញ៉ែម-ទឹម ប្រែពីភាសាបារាំងមកជាភាសាជាតិ

---

កាលពីថ្ងៃ ១៩ មីនា ១៩៦១, គេបានបង្កើតអង្គការមួយនៅក្នុងប្រទេសជប៉ុនឲ្យឈ្មោះថា "សន្និសីទសាកលលោកនៃអ្នកកាន់សាសនាដើម្បីសន្តិភាព" ។ អង្គការនេះបង្កើតឡើងឥតសំដៅទៅលើសាសនាណាទេ, គឺសំដៅតែទៅរកសន្តិភាពសាកលលោកតែមួយប៉ុណ្ណោះ ។

តាមគោលការណ៍ សន្និសីទត្រូវបើកធ្វើពីថ្ងៃ ២៥ កក្កដា ទៅថ្ងៃ ២៨ កក្កដា ១៩៦១ រួមមានធ្វើបូជនីយសចរណ៍ ដើម្បីសន្តិភាព កាត់តាមប្រទេសជប៉ុន ក្នុងរយៈពេលមួយខែ ។

តាមសេចក្តីអញ្ជើញនៃព្រះសង្ឃព្រះនាម ស.អយកាវ៉ា និងអ្នកស្រី (ហា.ណូមីយ៉ា), ដែលជាប្រធាននៃគណៈកម្មាធិការរបស់អង្គការខាងលើនេះ ប្រទេសកម្ពុជាយើង ដែលតែងតែមានសេចក្តីពេញចិត្តនឹងចូលរួមធ្វើបាតុកម្មដើម្បីសន្តិភាព, ក៏បានចាត់គណៈប្រតិភូមួយឲ្យចូល

ទៅរួមប្រជុំមហាបាតុកម្មនោះ ។ ឯគណៈប្រតិភូប្រទេសកម្ពុជាមានសមាសភាពដូចតទៅនេះ ៖

សហជីវិន ស៊ិន-ប៊ុយឆោ, រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនសិក្សាធិការប្រធាន ។

សហជីវិន ហ៊យ-ល្មុត តំណាងរាស្ត្រ, ប្រធាននៃពុទ្ធិកសមាគមពិភពលោកមជ្ឈមណ្ឌលភូមិភាគកម្ពុជរដ្ឋ សមាជិក ។

សហជីវិន ឃួច-គីឡេង សាស្ត្រាចារ្យនៃពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ សមាជិក ។

គណៈប្រតិភូបានចេញពីភ្នំពេញ នៅថ្ងៃ ២២.៧.៦១ ម៉ោង ១០ និង ៣០នាទី ហើយបានទៅដល់តូក្យូ នៅថ្ងៃជាមួយគ្នា ពេលម៉ោង ២១ និង ៣០នាទី ។ នៅពេលចុះពីអាកាសយាន, គណៈប្រតិភូយើងបានទទួលការគួរសមពីឯ ឧ. ស៊ិម.វ៉ា, ឯកអគ្គរាជទូតប្រទេសកម្ពុជាប្រចាំប្រទេសជប៉ុន និងអំពីគណៈកម្មាធិការ ខាងការរៀបចំបដិសណ្ឋារកិច្ច តាមពិធីការយ៉ាងស្រួល គឺមានអយស្គរជានិមិត្តរូបនៃជនជាតិជប៉ុន ដែលកាន់ព្រះពុទ្ធសាសនា, ព្រមទាំងស្គរទះដៃជាច្រើនដង និងមានបាចផ្កាភ្លេជាតិនិងផ្កាក្រដាសជាច្រើនមកលើគណៈប្រតិភូយើង ។ល។

គណៈប្រតិភូយើងបានទៅសំណាក់នៅក្នុងសណ្ឋាគារមួយ ។

នៅថ្ងៃ ២៤-៧-៦១ គណៈប្រតិភូបានធ្វើដំណើរចេញពីរាជធានីតូក្យូ តាមរថភ្លើងតម្រង់ទៅទីក្រុងក្យូតូ ។ នៅទីនោះ គណៈប្រតិភូយើងបានទៅសំណាក់នៅក្នុងក្យូតូ-សណ្ឋាគារ ។

នៅថ្ងៃ ២៥ ៧-៦១, ចាប់ពីម៉ោង ៨ ទៅ មានការប្រជុំយ៉ាងឧឡារិក ដើម្បីបើកទ្វារសន្និសីទ ។

ក្រោយពីការសូត្រធម៌យ៉ាងវែង និងក្រោយពីសុន្ទរកថាជាពិធីការតាមរបៀបធម្មតានៃអ្នកចាត់ចែងធ្វើសន្និសីទ ដើម្បីសំដែងសេចក្ដីរីករាយដល់គណៈប្រតិភូទាំងឡាយ ដែលបានអញ្ជើញទៅរួមធ្វើសន្និសីទ,គណៈប្រតិភូផ្សេងៗក៏ឡើងថ្លែងការតាមលំដាប់អក្សរ ។ សេចក្ដីថ្លែងការទាំងប៉ុន្មាន បានចម្លងចូលក្នុងសៀវភៅមួយ ដែលមានឈ្មោះថា: "សន្និសីទសាកលលោកនៃអ្នកកាន់សាសនា ដើម្បីសន្តិភាព ពីថ្ងៃ ២៥-២៨ កក្កដា ១៩៦១ ក្យូតូ-ជប៉ុន" ។

នៅថ្ងៃ២៦-៧-៦១ នៅពេលព្រឹក ជាពេលបើកប្រជុំ បង្កើតគណៈកម្មការបួន មានការៈសិក្សាពិនិត្យនូវបញ្ហាទាំងឡាយ ដែលមានទាក់ទងទៅនឹងសន្តិភាព, ហើយជាពិសេស អំពីបញ្ហាបន្ថយសព្វាវុធទូទៅ អំពីការអន្តរាយបណ្ដាលមកពីគ្រាប់បែកបរមាណូ អ៊ីដ្រូហ្សែន និងអំពីបំបាត់អាវុធប្រល័យលោក (Dénucléarisation) ។

ប្រទេសកម្ពុជាយើងបានចូលក្នុងគណៈកម្មការទីបួន ។ នៅថ្ងៃ

ដដែលនោះ ពេលប្រជុំបានបើកនៅម៉ោង ១៣ និង ៤៥ នាទី; នៅពេលនោះ គេឃើញអ្នកតំណាងសមាគមផ្សេងៗ និងអង្គការផ្សេងៗ ក្នុងប្រទេសជប៉ុនឡើងថ្លែងការ, សមាគមនៃពួកអ្នកកាន់សាសនាគ្រិស្តដើម្បីសន្តិភាព, ពុទ្ធិកសមាគមនៃប្រទេសជប៉ុន, អ្នកតំណាងយុវជនកាតូលិក, សមាគមនិស្សិតអ្នកកាន់ព្រះពុទ្ធសាសនា ។ល។

នៅវេលាល្ងាចនៃថ្ងៃដដែលនោះ, លោកចៅហ្វាយក្រុងក្យូតូ បានរៀបចាត់ចែងធ្វើបដិសណ្ឋារកិច្ចចំពោះគណៈប្រតិភូទាំងអស់ នៃសន្និសីទ នៅក្នុងសណ្ឋាគារក្យូតូ ។

នៅថ្ងៃ ២៧ ៧.៦១ ពីម៉ោង ៩ ទៅម៉ោង ១២, គណៈប្រតិភូប្រទេសកម្ពុជា បានចូលរួមប្រជុំពិនិត្យកិច្ចការ ដែលគណៈកម្មាធិការទីបួនត្រូវបំពេញ ។

ប្រតិភូទាំងឡាយដែលបានចូលរួមប្រជុំ បានបញ្ចេញយោបល់ផ្សេងៗ ដែលគេអាចបំប្រួញឲ្យខ្លីមកមានដូចតទៅនេះ៖

–ការបង្កើតចលនាប្រឆាំងនឹងការប្រើគ្រាប់បែកបរមាណូ, ដោយអនុវត្តន៍តាមគោលការណ៍របស់សាសនានៃប្រទេសនីមួយៗ ។

– ការបំបាត់ចោលនូវមូលដ្ឋានយោធា

– ការបន្ថយសព្វាវុធទូទៅ

គណៈប្រតិភូប្រទេសកម្ពុជា បានទាញសម្បជញ្ញៈគណៈកម្មាធិការ អំពីគោលបំណងនៃសន្និសីទនេះ ដែលផ្អែកលើមូលដ្ឋានសាសនា ហើយគាំទ្រពេញទំហឹងនូវការបន្ថយសព្វាវុធទូទៅ ដោយយោងយកតាមគោលការណ៍ ដែលអង្គការសហប្រជាជាតិបានកំណត់ទុកមក នឹងគាំទ្រនូវបេក្ខជនភាពនៃប្រទេសចិនប្រជាមានិត ក្នុងការសុំចូលជាសមាជិកនៃអង្គការសហប្រជាជាតិ ។ ប្រទេសកម្ពុជា ក្នុងឋានៈជារដ្ឋអព្យាក្រិត, សូមអំពាវនាវដល់រដ្ឋបុរសនៈយោបាយអ្នកដឹកនាំប្រទេសទាំងឡាយ សូមឲ្យលោកទាំងនោះ រើសយកនយោបាយអព្យាក្រិតពិតប្រាកដទៀងទាត់មកអនុវត្តន៍ ។ ប្រទេសកម្ពុជាសូមផ្សាយសេចក្ដីអត់ឱន នឹងភាតរភាព ។

នៅថ្ងៃ ២៨-៧-៦១, សហជីវិន ស៊ុង-ប៊ុយកោ ជាប្រធាននៃគណៈប្រតិភូយើង បានត្រូវគេជ្រើសតាំងជាប្រធានកិត្តិយសនៃសម័យប្រជុំ ។

ក្រោយពីបានឈរស្ងឹងស្ងាត់អស់ពេលចំនួនមួយវិនាទី គោរពដល់វិញ្ញាណក្ខន្ធនៃអ្នករងគ្រោះនៅក្រុងហ៊ីរ៉ូហ្ស៊ីម៉ា, នឹងស្ដាប់សេចក្ដីរាយ-ការណ៍ដោយសង្ខេបរបស់គណៈកម្មាធិការទាំងបួន នឹងសមាគមស្ត្រី, ព្រមទាំងការធ្វើអន្តរាគមខ្លះ នៃបណ្ដាគណៈប្រតិភូផ្សេង ៗ ទីប្រជុំក៏បានជ្រើសតាំងគណៈកម្មាធិការតែងសេចក្ដីមួយ ផ្ដើមកត់ត្រាចម្លងឲ្យ

បានត្រឹមត្រូវនូវសេចក្ដីសម្រេចចិត្តជាអវសាន (សូមអាន សេចក្ដីសម្រេចចិត្តជាអវសាននេះ នៅលេខក្រោយ) ។ អត្ថបទដែលគណៈកម្មការតែងសេចក្ដីបានផ្ញើមក បានត្រូវគេអនុមតិទទួលយល់ព្រមជាឯកច្ឆន្ទក្រោយពីមានការកែតម្រូវខ្លះពីគណៈប្រតិភូប្រទេសកម្ពុជា និងប្រទេសយូហ្គោស្លាវី ។

នៅម៉ោង ១៤ ទៅម៉ោង ១៧, គេមានធ្វើពិធីបិទសម័យប្រជុំនៃសន្និសីទនៅក្នុងសាលមហោស្រពមួយនៃសាលាក្រុងក្យូតូ ។

នៅលើវេទិកាមួយ ដែលលំអទៅដោយក្លួផ្កាផ្សេងៗ សមាជិកនៃគណៈកម្មការខាងការរៀបចំធ្វើសន្និសីទ បានឡើងថ្លែងសុន្ទរកថាដ៏វែងជាបន្តបន្ទាប់គ្នា ។ សេចក្ដីថ្លែងការណ៍បានទទួលការទះដៃអបអរសាទរជាខ្លាំងពីទីប្រជុំ ។

(នៅមានត)

ក្នុងពិភពលោក ។ ក្នុងការប្រជុំនេះ ក្រោយដែលមានថ្លែងការរៀងពល់ប្រទេសរួចហើយ គណៈប្រតិភូគ្រប់ប្រទេស ដែលទៅរួមប្រជុំនៅទីនោះ បានធ្វើសេចក្ដីសម្រេចចិត្តមួយ សុំឲ្យអ្នកកាន់អំណាចគ្រប់ប្រទេសតូចធំក្នុងពិភពលោក គិតគូរឲ្យមានសន្តិភាពសាកលលោកឡើង ។

គណៈប្រតិភូយើងបានបញ្ជាក់ថា នៅក្នុងសេចក្ដីសម្រេចចិត្តរួមនេះ គេបានថ្លែងសរសើរដល់ប្រទេសជាច្រើន មានប្រទេសកម្ពុជាយើងជាដើម ដែលនិយមកាន់អព្យាក្រិត ។ ព្រោះអព្យាក្រិតភាពនេះ ជាមូលដ្ឋាននៃសុខសន្តិភាពក្នុងសាកលលោក ។

សូមអញ្ជើញអាននៅក្នុងផ្នែកកំណត់ នឹងប្រវត្តិការណ៍នៃទស្សនាវដ្ដីនេះ នឹងបានជ្រាបនូវពត៌មានយ៉ាងពិស្ដារ ។

---

## ព្រះអំណោយនៃសម្ដេចព្រះប្រមុខរដ្ឋ

---

កាលពីពេលព្រឹកថ្ងៃទី ៧ សីហា ១៩៦១, សម្ដេចសហជីវិនជាព្រះប្រមុខរដ្ឋ ទ្រង់ព្រះបរមពជានុញ្ញាត ឲ្យព្រះភិក្ខុនាម យ៉ៃ-ថៃ ប៉ា ជាអាហារូបករណិកនៃផែនការ "កូឡុមបូ" ចូលគាល់ដើម្បីបំរើនព្រះពរលាព្រះអង្គ ទៅបំពេញវិជ្ជានៅប្រទេសសេរីលង្កា (សៃឡង់) ។ សម្ដេចសហជីវិនទ្រង់បានស្ដេចប្រគេនបច្ច័យ ៤០០០ʼ០០ ជាជំនួយដល់ការចំណាយផ្សេង ៗ ក្នុងការរៀបចំដំណើរចំពោះព្រះភិក្ខុអង្គនេះ ។